សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីអនុវត្តដោយបង្ខំ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ចាប ទិរៈ**
**ឡុង គួរ៉ូ**

សាស្ត្រាចារ្យណែនាំ
ឯកឧត្តម **ច័ន្ទ តារាវុស្សី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលរៀន ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំបាទ **ចាប ទិរៈ** និង **ឡុង តូរ៉ូ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១ ឆ្នាំសិក្សា២០១៧-២០២១។ សូមសម្តែងនូវគារវកិច្ចគោរពថ្លែងអំណរអរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖

**លោកឪពុកនិងអ្នកម្តាយ** របស់យើងខ្ញុំដែលលោកទាំងទ្វេបានធ្វើការខិតខំចិញ្ចឹម និងបីបាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌ និងសង្គហៈធម៌លះបង់អស់កម្លាំងកាយចិត្តក្នុងការថែរក្សាតាំងពីតូចរហូតដល់ធំ ព្រមទាំងផ្តល់នូវក្តីស្រលាញ់ និងការអប់រំទូន្មានប្រដៅកូនៗឲ្យប្រព្រឹត្តិអំពើល្អ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំគ្រប់កម្រិត មិនតែប៉ុណ្ណោះតែងតែផ្តល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងបច្ច័យទាំងបួន ផ្នែកសម្ភារៈសិក្សា និងខាងសតិស្មារតី រហូតយើងខ្ញុំទាំងពីរនាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះទាំងមូល ឲ្យកូនក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គម។

**មាតុភូមិកំណើតកម្ពុជា រាជរដ្ឋាភិបាល ក្រសួងអប់រំ និងឯកឧត្តមសាកលវិទ្យាធិការ ឯក-ឧត្តមសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យគ្រប់ៗរូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំពង្រឹងវិស័យអប់រំ បណ្តុះមូលធនខាងបញ្ញាឲ្យដំណើរការប្រកបដោយនិរន្តរភាពនិងប្រសិទ្ធិភាពខ្ពស់និងបង្ហាត់បង្រៀនដោយយកចិត្តទុកដាក់ស្មោះអស់ពីកម្លាំងកាយចិត្តក្នុងការផ្តល់ និងផ្ទេរនូវពុទ្ធិ ដើម្បីឲ្យយើងខ្ញុំបានសិក្សាក្រេបយកនូវចំណេះដឹងទាំងនេះជ្រាបបានយ៉ាងប្រត្យក្សប្រកបដោយបទពិសោធន៍ និងសមត្ថភាព។

លោកសាស្ត្រាចារ្យ **ចន្ទ័ តារារស្មី** ដែលជាសាស្ត្រាចារ្យដឹកនាំការស្រាវជ្រាវ និងរៀបចំសារណានេះឲ្យចេញជារូបរាងឡើង ជាពិសេសចំពោះការខិតខំប្រឹងប្រែងជួយពន្យល់ណែនាំរែកញ៉ែកអត្ថាធិប្បាយនូវខ្លឹមសារយ៉ាងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តដល់យើងខ្ញុំដោយផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃជាមនោសញ្ចេតនាមួយដែលយើងខ្ញុំមិនអាចកាត់ថ្លៃនិងបំភ្លេចបាន ។

ជាចុងបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងអស់ ឯកឧត្តម ព្រឹទ្ធ-បុរស សាស្ត្រាចារ្យ សិស្ស-និស្សិត កល្យាណមិត្ត និងបងប្អូនប្រុស-ស្រី ទាំងអស់គ្នាឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈសុខៈពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

សៀវភៅសារណាស្តីពី "**នីតិវិធីអនុវត្តដោយបង្ខំ**" ដែលយើងខ្ញុំបានរៀបចំចងក្រងជាសៀវភៅនេះឡើង គឺដើម្បីធ្វើការវាស់ស្ទង់នូវសមត្ថភាពរបស់យើងខ្ញុំ ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេលបួនឆ្នាំកន្លងមកនេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នៅក្នុងឱកាសនេះដែរ យើងខ្ញុំក៏បានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវ សរសេរចងក្រងជាឯកសារនេះឡើង គឺទុកជាសារៈប្រយោជន៍ សម្រាប់ឱ្យសិស្ស-និស្សិតបងប្អូន ក៏ដូចជាប្រជាពលរដ្ឋទូទៅដែលមានឆន្ទៈចង់សិក្សាស្រាវជ្រាវឈ្វេងយល់បន្ថែមទាក់ទងទៅនឹងខ្លឹមសារនៃប្រធានបទខាងលើមួយនេះផងដែរ។ ម្យ៉ាងវិញទៀត គឺដើម្បីទុកជាស្នាដៃសម្រាប់ជូនដល់សាកលវិទ្យាល័យ និងទុកសម្រាប់តម្កល់ទុកនៃការបញ្ចប់ការសិក្សារបស់យើងខ្ញុំផងដែរ។ អត្ថបទសារណាមួយនេះមិនមែនជាការសិក្សាស្រាវជ្រាវដែលមានលក្ខណៈល្អឥតខ្ចោះនោះទេគឺយើងខ្ញុំធ្វើទៅតាមកម្រិតសមត្ថភាពនៃចំណេះដឹងដែលយើងខ្ញុំបានសិក្សាឈ្វេងយល់នាពេលកន្លងមកតែប៉ុណ្ណោះ។ ហើយសារណានេះទៀតសោត គឺត្រូវបានរៀបចំធ្វើការសិក្សាស្រាវជ្រាវដោយយើងខ្ញុំដែលត្រូវជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២១ លើឯកទេសនីតិសាស្ត្រនៃមហាវិទ្យាល័យនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការណែនាំអំពីលោកសាស្ត្រាចារ្យ **ចន្ទ័ តារាស្មី** ផងដែរ។ ហើយកិច្ចការស្រាវជ្រាវនេះ ត្រូវបានចងក្រងឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីខ្លឹមសារសំខាន់ៗនៅក្នុងដំណាក់កាលនីមួយៗ និងលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំនាពេលបច្ចុប្បន្នដែលមាន នៅក្នុងច្បាប់នីតិវិធីរដ្ឋប្បវេណី។ បន្ថែមពីលើនេះទៀត ក្នុងអត្ថន័យខ្លឹមសារក៏ពន្យល់យ៉ាងស៊ីជម្រៅផងដែរទៅលើនីតិវិធីនីមួយៗដែលបានចង្អុលបង្ហាញនូវច្បាប់នានាដែលជាប់ពាក់ព័ន្ធទៅនឹងការអនុវត្តដោយបង្ខំលើផ្នែកនីមួយៗ យ៉ាងលម្អិតព្រមទាំងមានភ្ជាប់នូវឧទាហរណ៍មួយចំនួនខ្លះៗផងដែរ។ ជាការពិតណាស់ ក្នុងការតាក់តែងសរសេរនូវអត្ថបទសារណាមួយនេះមិនអាចល្អឥតខ្ចោះនោះទេ គឺតែងតែមានចំណុចខ្វះខាតខ្វះចន្លោះជាក់ជាពុំខាន ហើយក៏មានបញ្ហាមួយចំនួនខ្លះដែលរាំងស្ទះដល់ការបកស្រាយ និងអនុវត្តនីតិវិធីនេះផងដែរ។

ជាអវសានយើងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះនឹងផ្តល់ជាអត្ថប្រយោជន៍ដល់បងប្អូនមិត្តនិស្សិតក៏ដូចជាប្រិយមិត្តអ្នកអានទាំងឡាយ ដើម្បីជាប្រយោជន៍យល់ដឹងនិងទុកជាឯកសារយោងផងដែរ។ ជាពិសេស យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដោយការភ្លាំងភ្លាត់ ឬដោយអចេតនាលើបញ្ហាអក្ខរាវិរុទ្ធ និងអត្ថន័យប្រការឯណានីមួយនោះ សូមមេត្តាអធ្យាស្រ័យអភ័យទោសសន្តោសដល់យើងខ្ញុំផង។ របស់យើងខ្ញុំរង់ចាំស្វាគមន៍យ៉ាងកក់ក្តៅបំផុតក្នុងការរិះគុណ នៅក្នុងន័យស្ថាបនាក្នុងគោលបំណងដើម្បីកែលម្អឡើងវិញ និងឈានទៅមុខឱ្យមានភាពល្អប្រសើរជាក់លាក់ និងប្រត្យក្ស។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃនីតិវិធីអនុវត្តដោយបង្ខំ**

**ផ្នែកទី១៖ គោលបំណងនៃការអនុវត្តដោយបង្ខំ** ........ ៣

**កថាខណ្ឌទី១៖ និយមន័យ** ........ ៣

**កថាខណ្ឌទី២៖ មូលហេតុនៃការអនុវត្តដោយបង្ខំ** ........ ៣

**ផ្នែកទី២៖ ស្ថាប័នអនុវត្ត** ........ ៣

**កថាខណ្ឌទី១៖ តុលាការអនុវត្ត** ........ ៣

១. អត្ថន័យ ........ ៣

២. សមត្ថកិច្ចរបស់តុលាការអនុវត្ត ........ ៤

៣.ទម្រង់នៃសេចក្តីសម្រេច ........ ៤

**កថាខណ្ឌទី២៖ អាជ្ញាសាលា** ........ ៥

១.អត្ថន័យ ........ ៥

២. តួនាទីសមត្ថកិច្ចរបស់អាជ្ញាសាលា ........ ៥

៣. ការបំពេញការងាររបស់អាជ្ញាសាលា ........ ៥

**ផ្នែកទី៣៖ ភាគីនៃការអនុវត្ត និងអ្នកតំណាង** ........ ៧

**កថាខណ្ឌទី១៖ ភាគីអនុវត្ត** ........ ៧

**កថាខណ្ឌទី២៖ អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីអនុវត្តដោយបង្ខំ** ........ ៧

**ផ្នែកទី៤៖ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ** ........ ៧

**កថាខណ្ឌទី១៖ គោលការណ៍** ........ ៨

**កថាខណ្ឌទី២៖ វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ** ........ ៨

**កថាខណ្ឌទី៣៖ ការស្រាវជ្រាវទ្រព្យសម្បត្តិទទួលខុសត្រូវ** ........ ៩

**កថាខណ្ឌទី៤៖ ការទទួលខុសត្រូវដោយមានកម្រិត** ........ ១០

**ជំពូកទី២**

**លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ**

ផ្នែកទី១៖ ការរៀបចំដាក់ពាក្យសុំ ...... ១២
កថាខណ្ឌទី១៖ ការចរចារ ការជ្រើសរើស និងការស្រាវជ្រាវ ...... ១២
កថាខណ្ឌទី២៖ ការសរសេរពាក្យសុំអនុវត្តដោយបង្ខំ ...... ១២
កថាខណ្ឌទី៣៖ ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ ...... ១២
ផ្នែកទី២៖ ការរៀបចំឯកសាររបស់ម្ចាស់បំណុល ...... ១៣
កថាខណ្ឌទី១៖ លិខិតចម្លងយថាតថនៃលិខិតអនុវត្តដែលមានអានុភាព ...... ១៣
កថាខណ្ឌទី២៖ លិខិតអនុវត្ត ...... ១៤
កថាខណ្ឌទី៣៖ រូបមន្តអនុវត្ត ...... ១៥
១.គោលគំនិតនៃរូបមន្តអនុវត្ត ...... ១៥
២.ភាពចំបាច់នៃរូបមន្តអនុវត្ត ...... ១៧
៣.នីតិវិធីផ្តល់នៃផ្តល់ការរូបមន្តអនុវត្ត ...... ១៨
៤. ការសង្គ្រោះសម្រាប់ម្ចាស់បំណុល ...... ២៣
៥. ការសង្គ្រោះសម្រាប់កូនបំណុល ...... ២៤

ជំពូកទី៣

លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំ

ផ្នែកទី១៖ ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងឲ្យជាប្រាក់ ...... ២៨
កថាខណ្ឌទី១៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ...... ២៨
១. ការរឹបអូស ...... ២៨
២. វិធីនៃការរឹបអូស ...... ៣០
៣. ការប្តូរជាប្រាក់ ...... ៣១
៤. ការចែកចំណែក ...... ៣១
កថាខណ្ឌទី២៖ ការអនុវត្តចំពោះអចលនវត្ថុ ...... ៣២
១. វិធីនៃការអនុវត្ត ...... ៣២
២. ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ...... ៣២
៣. នីតិវិធីនៃការលក់ ...... ៣៤
៤. អានុភាពនៃការលក់ ...... ៣៦
កថាខណ្ឌទី៣៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ...... ៣៨

១. អត្ថន័យ ....................................................................................................................៣៨
២. ការរឹបអូសសិទ្ធិលើបំណុល ....................................................................................៣៨
៣. ការប្តូរជាប្រាក់នូវសិទ្ធិលើបំណុលដែលបានរឹបអូស.................................................... ៤០
៤.ការចែកចំណែក ......................................................................................................... ៤០
**ផ្នែកទី២៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលចំណងឲ្យសងជាប្រាក់**............................................................................................................................៤០
**កថាខណ្ឌទី១៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុរូបី**.............. ៤១
១.ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុជាអាទិ៍ ........................................................ ៤១
២.ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ .................................................................... ៤២
**កថាខណ្ឌទី២៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើ ឬមិនឱ្យសកម្មភាពអ្វីមួយ** ..........................................................................................................................៤២
១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ ..................................៤២
២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ ............................. ៤៤
**ផ្នែកទី៣៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ**............................................ ៤៥
**កថាខណ្ឌទី១៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ** ........................................ ៤៦
១. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុតាមរយៈការលក់ដោយបង្ខំ ........................ ៤៦
២.ការអនុវត្តសិទ្ធិប្រាតិភោគដោយការអនុវត្តដោយខ្លួនឯង(ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប).៤៧
**កថាខណ្ឌទី២៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**.......................................................................................................៤៧
**កថាខណ្ឌទី៣៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ**...................................... ៤៨
១. ការរឹបអូសអចលនវត្ថុ............................................................................................ ៤៨
២.ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ............................................. ៤៩
**កថាខណ្ឌទី៤៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា**.................................................. ៥០
១. កំណត់សំគាល់ទូទៅ............................................................................................... ៥០
២. ការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគ ...................................................................... ៥០
៣. នីតិវិធីអនុវត្ត ........................................................................................................ ៥១
**សេចក្តីសន្និដ្ឋាន**...........................................................................................................៥៣

**អនុសាសន៍**........................................................................................................................ ៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយដែលប្រកបទៅដោយសក្តានុពល និងសកលភាវូបនីយកម្ម មានទាំងសេដ្ឋកិច្ច សង្គមពាណិជ្ជកម្ម វប្បធម៌អរិយធម៌ ព្រមទាំងសេដ្ឋកិច្ចទីផ្សារសេរីដែលមានគតិយុត្តច្បាប់សម្រាប់ដោះស្រាយបញ្ហាវិវាទផ្សេងៗទៀតផងដែរ។ ដោយសារប្រទេសកម្ពុជាមានការអភិវឌ្ឍជាបន្តបន្ទាប់ និងរីកចម្រើនជាលំដាប់ និងជាប្រទេសមួយដែលប្រកាន់យកនូវរបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយបានគោរពទៅលើសិទ្ធិ និងសេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្មព្រមទាំងឧស្សាហកម្ម និងសិទ្ធិសម្រាប់ធ្វើសកម្មភាពទាំងឡាយរបស់ប្រជាពលរដ្ឋ ដើម្បីធានាបាននូវជីវភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងសមភាព ភាតរភាព និងភាពសុខសាន្តនៅក្នុងសង្គម ហើយព្រមទាំងទទួលស្គាល់នូវកម្មសិទ្ធិរបស់ឯកជនផងដែរ។ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិ-ឯកជនដោយប្រើអំណាចរបស់រដ្ឋ។ យើងបានដឹងហើយថា នីតិវិធីរដ្ឋប្បវេណី មានគោលបំណងផ្តល់ទៅឱ្យភាគីឯកជនដែលមានសិទ្ធិដែលបានកំណត់ដោយច្បាប់នូវការការពារសិទ្ធិទាំងនោះ។[1] ដើម្បីការពារដល់សិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះ ត្រឹមតែការកំណត់ដោយតុលាការអំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម ឬសាលដីកានៅមិនទាន់គ្រប់គ្រាន់ទេ។ បន្ថែមពីលើនេះ ត្រូវមានការផ្តល់តាវកាលិក ជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ (ឧទាហរណ៍ដូចជាការបង់ប្រាក់តាមចំនួនកំណត់ណាមួយ ការប្រគល់ចលនវត្ថុណាមួយជាក់លាក់ ជាដើម) ឬការផ្តល់តាវកាលិកជាប្រាក់ ដែលជាគោលបំណងនៃសិទ្ធិទាមទារឱ្យសងជាប្រាក់ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគយ៉ាងជាក់ស្តែងផងដែរ ។ ឧទាហរណ៍ៈ ក្នុងករណីដែល A មានសិទ្ធិទាមទារចំពោះ B ឱ្យ B ប្រគល់រថយន្តដែលជាកម្មវត្ថុនៃការលក់ទិញមកឱ្យខ្លួន នោះទោះបីជាតុលាការបានចេញសាលក្រម ឬសាលដីកាកំណត់អំពីអត្ថិភាពនៃសិទ្ធិនោះហើយក៏ដោយ ក៏សិទ្ធិទាមទារនោះ នៅមិនទាន់បានទទួលការការពារយ៉ាងពេញលេញនៅឡើយ រហូតទាល់តែរថយន្តត្រូវបានប្រគល់ដោយជាក់ស្តែងទៅឱ្យ A ។ ស្រដៀងគ្នានេះដែរ ឧទាហរណ៍ថានៅពេល C មានហ៊ីប៉ូតែកលើអចលនវត្ថុរបស់ D ដែល D បានដាក់ដើម្បីធានាបំណុលរបស់ខ្លួនលើទឹកប្រាក់ចំនួន ១០លានរៀល ចំពោះ C នោះបើទោះណាជាតុលាការបានចេញសាលក្រម ឬសាលដីកាកំណត់អំពីអត្ថិភាពនៃហ៊ីប៉ូតែកនោះហើយក៏ដោយ ក៏ការការពារចំពោះសិទ្ធិប្រាតិភោគនោះ នៅមិនទាន់គ្រប់គ្រាន់ដែរ រហូតទាល់តែមានការសងប្រាក់ចំនួន ១០លានរៀល។ ហេតុនេះហើយ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ។ ក្នុងករណី

[1] មាត្រា ២ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគតាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ញារបស់រដ្ឋ។ អ្វីដែលត្រូវបានរៀបចំឡើងដើម្បីបំពេញភាពចំបាច់នេះ គឺការអនុវត្តដោយបង្ខំ។

អាស្រ័យហេតុច្នេះហើយទើប ព្រះរាជាណាចក្រកម្ពុជាយើងបានបង្កើតច្បាប់ជាច្រើនដើម្បីការពារនូវផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូបឱ្យមានភាពល្អប្រសើរឡើងវិញ។ នៅក្នុងនោះផងដែរ ក៏មានក្រមនីតិវិធីរដ្ឋ-ប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលមានចំនួន៩គន្ថី។ នៅក្នុងចំណោមគន្ថីទាំង៩នោះ គឺគន្ថីទី៦ បាននិយាយអំពីការអនុវត្តដោយបង្ខំ គឺចាប់ពីបញ្ញត្តិមាត្រា៣៣៤ រហូតដល់មាត្រា៥៣០។

ដូច្នេះយើងត្រូវដឹងជាមុនថា តើសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំមានលក្ខណៈពិសេសយ៉ាងណាខ្លះ?

តើស្ថាប័នណាខ្លះដែលមានសិទ្ធិអនុវត្តការចំពោះការអនុវត្តដោយបង្ខំទាំងនោះ?

តើនីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវមានលក្ខខណ្ឌ និងលំហូរនីតិវិធីប្រព្រឹត្តិទៅយ៉ាងដូចម្ដេច?

ដើម្បីឱ្យជ្រាបកាន់តែច្បាស់ទៅលើប្រធានបទ និងបានជាទឡ្ហីករណ៍ក្នុងការសិក្សាឈ្វេងយល់ និងឈានដល់ការបកស្រាយនូវខ្លឹមសារទាំងមូលឱ្យបានក្បោះក្បាយនិងស៊ីជម្រៅ យើងខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធទាំងនោះ ដោយធ្វើការបកស្រាយនៅក្នុងប្រធានបទសារណានេះដែលបានធ្វើការបែងចែកជាបីជំពូកធំៗដូចខាងក្រោមនេះ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃនីតិវិធីអនុវត្តដោយបង្ខំ**

**ជំពូកទី២៖ លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ**

**ជំពូកទី៣៖ លំហូរនីតិវិធីនៃការអនុវត្ត**

# ជំពូកទី១

# សញ្ញាណទូទៅនៃនីតិវិធីអនុវត្ត

# ដោយបង្ខំ

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីអនុវត្តដោយបង្ខំ

## ផ្នែកទី១៖ គោលបំណងនៃការអនុវត្តដោយបង្ខំ

### កថាខណ្ឌទី១៖ និយមន័យ

នីតិវិធីអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលអនុវត្តដោយបង្ខំតាមផ្លូវតុលាការ ដើម្បីសម្រេចបាននូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត[2] មានន័យថា គឺជានីតិវិធីនៃការទាមទារឲ្យបានសម្រេចនូវសិទ្ធិ ដោយការអនុវត្តដោយបង្ខំចំពោះបុគ្គលដែលមានទំនាក់ទំនងគតិយុត្តនៃនីតិឯកជនដោយការប្រើប្រាស់អំណាចរបស់រដ្ឋ ។

### កថាខណ្ឌទី២៖ មូលហេតុនៃការអនុវត្តដោយបង្ខំ

នីតិវិធីអនុវត្តដោយបង្ខំមួយដែលធ្វើឡើងដើម្បីឲ្យបុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេង អាចទាមទារឲ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី។[3] ដែលក្នុងនោះមានគោលបំណងយកសិទ្ធិលើបំណុល ឬសម្រេចចុងក្រោយបង្អស់នូវសិទ្ធិទាមទាររបស់ភាគីបុគ្គលឯកជន ដែលជាការចាំបាច់ដល់ការគិតគូរដល់ការការពារផលប្រយោជន៍របស់ភាគីជាម្ចាស់បំណុលនៃការអនុវត្ត និងសិទ្ធិរបស់គាត់ដោយធ្វើយ៉ាងណាឲ្យនីតិវិធីនេះធ្វើឡើងដោយងាយស្រួល និងមានភាពឆាប់រហ័សចំពោះការសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ។

## ផ្នែកទី២៖ ស្ថាប័នអនុវត្ត

ការអនុវត្តដោយបង្ខំ ជានីតិវិធីមួយដែលត្រូវធ្វើឡើងដោយស្ថាប័នមួយជាស្ថាប័នអនុវត្ត ដែលជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័ននេះត្រូវបានបែងចែកជាពីរ គឺតុលាការអនុវត្ត និងស្ថាប័នអាជ្ញាសាលាដែលជាស្ថាប័នមួយមានលក្ខណៈខុសគ្នា ដោយអាស្រ័យទៅលើកម្មវត្ថុនៃការងនុវត្ត និងប្រភេទនៃការអនុវត្តដោយបង្ខំ។ បន្ទាប់នេះយើងនឹងធ្វើការបកស្រាយទៅលើស្ថាប័នទាំងពីរនេះនៅចំណុចខាងក្រោម ។

### កថាខណ្ឌទី១៖ តុលាការអនុវត្ត

#### ១. អត្ថន័យ

តុលាការអនុវត្ត គឺជាតុលាការដែលមានភារកិច្ចអនុវត្តដោយបង្ខំ ឬដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ដោយតុលាការដែលបានកំណត់ថាជាតុលាការអនុវត្តនេះ គឺជាសាលាដំបូង។ មានន័យថា

[2] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគី២,ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ឆ្នាំ២០០៨

[3] មាត្រា ៣៣៤នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

សាលាដំបូង គឺជាតុលាការអនុវត្តដែលមានភារកិច្ចអនុវត្តដោយបង្ខំ ដោយការសម្រេចសេចក្តីដោយចៅក្រមដែលជាអង្គភាពរបស់រដ្ឋ ។

## ២. សមត្ថកិច្ចរបស់តុលាការអនុវត្ត

តុលាការអនុវត្តអាចបំពេញតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់បាន គឺអាស្រ័យទៅតាមប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនប៉ុណ្ណោះ។ ចំពោះប្រភេទនៃនីតិវិធីនៃការអនុវត្តការអនុវត្តដោយបង្ខំដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការរួមមាន ៖

- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត (មាត្រា ៤០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ (មាត្រា៤១៨ នៃក្រមនីតិវិធីរដ្ឋ-ប្បវេណី)

- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា (មាត្រា៤៥៦នៃក្រមនីតិវិធីរដ្ឋប្បវេណី)

- ការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុ ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជន (មាត្រា ៥២៦នៃក្រមនីតិវិធីរដ្ឋប្បវេណី)

-ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឲ្យធ្វើ ឬមិនឲ្យធ្វើនូវសកម្មភាពណាមួយ (មាត្រា៥២៧ និង ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## ៣.ទម្រង់នៃសេចក្តីសម្រេច

ជាគោលការណ៍ ការសម្រេចសេចក្តីរបស់តុលាការជាទម្រង់នៃសេចក្តីសម្រេចជាសាលក្រម សាលដីកា ឬដីកាសម្រេច។ ចំពោះការសម្រេចសេចក្តីរបស់តុលាការអនុវត្ត គឺត្រូវធ្វើឡើងដោយដីការម្រេច[4] ។ ជាទូទៅនៅពេលដែលតុលាការធ្វើការចាត់ចែងនីតិវិធីអនុវត្តដែលជាសមត្ថកិច្ចរបស់តុលាការអនុវត្ត ត្រូវធ្វើឡើងក្រោមទម្រង់ជាដីកាសម្រេច។ នីតិវិធីនៃដីកាសម្រេច គឺជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តាមឆន្ទៈស្មគ្រចិត្ត មានន័យថា តុលាការធ្វើការទាញហេតុផលដោយផ្ទាល់មាត់ក៏បាន ឬមិនធ្វើក៏បានដែរ។ ហើយក្នុងករណីដែលយល់ឃើញថាចាំបាច់នៅពេលធ្វើការចាត់ចែងការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬជនផ្សេងទៀតដែលពាក់ព័ន្ធបាន[5] ។ នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ តុលាការអនុវត្តអាចពង្រីកវិសាលភាពនៃអ្នកដែលតុលាការអាចសួរបាន ចំពោះជនដែលទាក់ទងនឹងប្រយោជន៍ដែលតុលាការអាចធ្វើការសាកសួរបន្ថែមទៀតពីការសាកសួរភាគីបាន ។

[4] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[5] មាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

## កថាខណ្ឌទី២៖ អាជ្ញាសាលា

### ១.អត្ថន័យ

អាជ្ញាសាលា គឺជាស្ថាប័នមួយដែលមានយុត្តាធិការឯករាជ្យ ដែលទទួលបន្ទុកការងារអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធមួយចំនួនដែលច្បាប់បានកំណត់[6] ។ ស្ថាប័នយុត្តាធិការនេះស្ថិតនៅក្រោមក្រសួងយុត្តិធម៌ និងមានសមាសភាពជាមន្ត្រីរាជការ ដែលមិនមែនជាស្ថាប័នជំនួយឲ្យតុលាការអនុវត្តនៅទេ តែត្រូវបំពេញការងារនៅសាលាដំបូងតាមការបង្គាប់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### ២. តួនាទីសមត្ថកិច្ចរបស់អាជ្ញាសាលា

អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួននៅតំបន់នៃសមត្ថកិច្ចរបស់សាលាដំបូងដែលខ្លួនបំពេញការងារ។[7] ការកម្រិតទីតាំងលើតំបន់នៃការបំពេញមុខនាទីនេះ មានឥទ្ធិពលដោយប្រយោលទៅលើការកំណត់ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា។ ដោយក្នុងនោះការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យក្នុងនាមជាស្ថាប័នអនុវត្តរួមមាន ៖

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ
- ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ
- ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ
- ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ ។

ក្នុងនីតិវិធិអនុវត្តដោយបង្ខំដែលតុលាការអនុវត្តជាអ្នកទទួលបន្ទុកក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំណុចមួយចំនួនដូចជា ការថែរក្សាគ្រប់គ្រងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ការងអនុវត្តការលក់ និងការដកហូតលិខិតបញ្ជាក់សញ្ញាតិនាវាជាអាទិ៍ ។

### ៣. ការបំពេញការងាររបស់អាជ្ញាសាលា

ការបំពេញការងាររបស់អាជ្ញាសាលា គឺធ្វើទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល កូនបំណុល និងតតិយជន និងការធ្វើទំនាក់ទំនងជាមួយតុលាការអនុវត្ត។ សកម្មភាពរបស់អាជ្ញាសាលា គឺជាការប្រើប្រាស់អំណាចរដ្ឋនោះមន្ត្រីទទួលបន្ទុកការអនុវត្ត មិនមែនជានិយោជិតរបស់ម្ចាស់បំណុលនោះទេ ហើយប្រសិនបើអាជ្ញាសាលាបង្កឲ្យមានការខូចខាតដល់កូនបំណុល ឬតតិយជនដោយសារការធ្វើសកម្មភាពអនុវត្តដោយបង្ខំ នោះម្ចាស់បំណុលមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងនាមជានិយោជកឡើយ ។ លើកលែងតែម្ចាស់បំណុលមានចេតនា ឬដោយមានការធ្វេសប្រហែសឲ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវ ហើយបង្កឲ្យមាន

---

[6] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌, ឆ្នាំ២០០៧

[7] មាត្រា ៧ នៃសេចក្តីព្រាងច្បាប់អាជ្ញាសាលា

ការខូចខាតដល់អ្នកដទៃ នោះម្ចាស់បំណុលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលកើតឡើងដោយចេតនាទុច្ចរិតដោយផ្ទាល់ខ្លួន ។

នៅពេលដែលបំពេញការងារនៃការអនុវត្តដោយបង្ខំ អាជ្ញាសាលាត្រូវអនុវត្តទៅតាមវិធានទូទៅកំណត់ដោយច្បាប់ដូចខាងក្រោម៖

**-ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ:** នៅពេលបំពេញការងារ អាជ្ញាសាលាត្រូវយកតាមនូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬលក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនោះ នៅចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍បើជននោះទាមទារ[8] ។

**-ការអនុវត្តសិទ្ធិឆែកឆេរ:** អាជ្ញាសាលាអាចចូលទៅក្នុងកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូសនៅក្នុងទំហំចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ។ ក្នុងករណីដែលមានភាពចាំបាច់ក្នុងការអនុវត្ត អាជ្ញាសាលាអាចឲ្យកូនបំណុលនៃការអនុវត្តនោះបើកទ្វារដែលចាក់សោរ ទូដែក និងប្រអប់ផ្សេងទៀតបាន ហើយប្រសិនបើកូនបំណុលនៃការអនុវត្តបដិសេធមិនព្រមធ្វើតាម នោះអាជ្ញាសាលាអាចចាត់វិធានការចាំបាច់ដើម្បីធ្វើការបើករបស់ទាំងនោះដោយប្រើកម្លាំង និងឧបករណ៍បាន[9] ។

**-ការបំបាត់នូវការប្រឆាំង:** នៅពេលដែលធ្វើការអនុវត្ត ប្រសិនបើអាជ្ញាសាលាបានជួបប្រទះនឹងការប្រឆាំងក្នុងការបំពេញក្នុងមុខនាទីរបស់ខ្លួននោះអាជ្ញាសាលាអាចប្រើកម្លាំង ឬអាចស្នើសុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ចដើម្បីលុបបំបាត់ចំពោះការប្រឆាំងនឹងការអនុវត្តនោះ[10] ។

**-អ្នកសង្កេតការណ៍**: នៅពេលដែលចូលទៅទីកន្លែងដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបប្រទះនឹងម្ចាស់នៃទីកន្លែងរស់នៅ អ្នកតំណាងរបស់អ្នកនោះ ញាតិដែលរស់នៅជាមួយ អ្នកបម្រើ ឬអ្នកផ្សេង ដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេនោះ អាជ្ញាសាលាត្រូវរកអ្នកសង្កេតការណ៍ដែលអាចជា មន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬអ្នកដទៃទៀតដែលយល់ឃើញថាសមរម្យអាចធ្វើជាអ្នកសង្កេតការណ៍បាន ។[11]

**-ការអនុវត្តក្នុងថ្ងៃឈប់សម្រាក ឬពេលយប់:** ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅរបស់ជនណាម្នាក់នៅថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ឬពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងប្រាំមួយព្រឹកនៃថ្ងៃបន្ទាប់បាន ដោយទទួលបានការអនុញ្ញាតពីសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ

[8] មាត្រា ៣៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[9] មាត្រា ៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[10] មាត្រា ៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[11] មាត្រា ៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

ឬតាមដីការបង្គាប់របស់តុលាការ ហើយនៅពេលដែលអនុវត្ត អាជ្ញាសាលាត្រូវបង្ហាញលិខិតដែលបញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតនោះផងដែរ ។[12]

**-ការធ្វើកំណត់ហេតុ:** អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្ដីពីការបំពេញមុខនាទីរបស់ខ្លួន[13] ព្រមទាំងត្រូវរក្សា ទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងរឿងក្ដីអនុវត្តដោយបង្ខំ ដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ ។[14]

ម្យ៉ាងវិញទៀត ក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាតិ ឬមានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងទៀតជាមួយនឹងភាគីជាអាជ្ញាសាលា នោះត្រូវដកហូតចេញពីការអនុវត្តមុខការរបស់ខ្លួនដើម្បីជៀសវាងមន្ទិលសង្ស័យអំពីភាពមិនត្រឹមត្រូវក្នុងការបំពេញមុខនាទីនោះ [15]។

## ផ្នែកទី៣៖ ភាគីនៃការអនុវត្ត និងអ្នកតំណាង

### កថាខណ្ឌទី១៖ ភាគីអនុវត្ត

ភាគីនៅក្នុងរឿងក្ដីអនុវត្តដោយបង្ខំដែលបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ហៅថា**ភាគីម្ចាស់បំណុលនៃការអនុវត្ត** ចំណែកឯភាគីម្ខាងទៀតហៅថា **ភាគីកូនបំណុលនៃការអនុវត្ត** ។[16] នៅពេលដែលម្ចាស់បំណុលបានឲ្យកូនបំណុលរបស់ខ្លួនអនុវត្តកាតព្វកិច្ចដែលមានចំពោះខ្លួន ប៉ុន្តែកូនបំណុលមិនព្រមអនុវត្តតាមសម្រួល នោះម្ចាស់អាចដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំទៅស្ថាប័នអនុវត្តបាន ដើម្បីធ្វើការអនុវត្តដោយបង្ខំទៅលើកូនបំណុលតាមរយៈការប្រើប្រាស់អំណាចរដ្ឋ ។ កូនបំណុលក្នុងនោះត្រូវរាប់បញ្ចូលទាំងតតិយជនដែលដាក់វត្ថុ ឬសិទ្ធិដើម្បីធានាបំណុលរបស់កូនបំណុលក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគផងដែរ ។

### កថាខណ្ឌទី២៖ អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីអនុវត្តដោយបង្ខំ

អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីទាក់ទងនឹងការអនុវត្តដោយបង្ខំ គឺខុសគ្នាពីអ្នកតំណាងក្នុងនីតិវិធីនៃបណ្ដឹង ដោយហេតុថាក្នុងនីតិវិធីនៃបណ្ដឹង អ្នកតំណាងដោយអាណត្តិតម្រូវឲ្យជាចាំបាច់ជាមេធាវី ។ ប៉ុន្តែនៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ អ្នកតំណាងដោយអាណត្តិមិនតម្រូវជាចាំបាច់ជាមេធាវីនោះទេ ដោយសារតែនីតិវិធីអនុវត្តដោយបង្ខំគ្រាន់ជាការអនុវត្តតាមសាលក្រម ដែលចូលជាស្ថាពរ ឬលិខិតយថាភូតតែប៉ុណ្ណោះ ។

ដោយឡែកក្នុងករណីចាំបាច់នៃនីតិវិធីនៃការចេញសាលក្រម នីតិវិធីត្រូវធ្វើដោយហ្មត់ចត់ក្នុងការចេញសាលក្រមនេះ ។ ក្នុងចំណោមនៃការចេញដីកាសម្រេចនោះអ្នកតំណាងដោយអាណត្តិត្រូវមានលក្ខណៈសម្បត្តិ

[12] មាត្រា ៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[13] មាត្រា ២០ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា

[14] មាត្រា ៣៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[15] មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា

[16] មាត្រា ៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

ដូចដែលបានកំណត់ក្នុងមាត្រា៥៣ កថាខណ្ឌទី១ ស្តីពីលក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ។ ចំពោះនីតិវិធីដែលតុលាការត្រូវទទួលបន្ទុកការកំណត់ទទួលស្គាល់នូវវិសាលភាពនៃអ្នកតំណាងដោយអាណត្តិ មានភាពទូលាយជាងលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា៥៣ កថាខណ្ឌទី១ ដោយកំណត់ឲ្យតុលាការអនុវត្ត ឬសាលាដំបូងអាចធ្វើការកំណត់ដោយឆន្ទានុសិទ្ធិរបស់ស្ថាប័នអនុវត្ត ។[17] ម្យ៉ាងទៀត ចំពោះនីតិវិធីដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកវិញ ការកំណត់ ឬជ្រើសរើសអ្នកតំណាង ច្បាប់បានផ្តល់សិទ្ធិឲ្យភាគីដែលជាអ្នកមានសិទ្ធិក្នុងការជ្រើសរើសដោយឆន្ទៈសេរី ដោយគ្មានកំណត់លក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិឡើយ បានសេចក្តីថា អ្នកណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ ក្នុងនីតិវិធីដែលជាបន្ទុករបស់ស្ថាប័នអាជ្ញាសាលា ។[18]

## ផ្នែកទី៤៖ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ

### កថាខណ្ឌទី១៖ គោលការណ៍

កម្មវត្ថុនៃការអនុវត្ត គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ ហើយគោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីឲ្យម្ចាស់បំណុលទទួលបាននូវភាពស្ងប់ចិត្ត តាមរយៈការប្រើអំណាចរបស់រដ្ឋ ដូចគ្នានឹងករណីដែលកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរ ។ ដូច្នេះ ត្រូវធ្វើការអនុវត្តទៅលើទ្រព្យសម្បត្តិដែលទទួលខុសត្រូវដែលជាទ្រព្យសម្បត្តិដែលអាចធ្វើឲ្យសម្រេចគោលបំណងនេះបាន ។ ក្នុងករណីនៃការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដោយអនុវត្តទៅលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុល ។ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគវិញ ទ្រព្យសម្បត្តិដែលអនុវត្ត គឺជាទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដែលពាក់ព័ន្ធ ។

### កថាខណ្ឌទី២៖ វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ

ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ ជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។ ដោយអនុវត្តចំពោះទ្រព្យសម្បត្តិទាំងអស់ ទាំងរូបទ្រព្យ[19] និងអរូបទ្រព្យ[20] ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត ។[21] ប៉ុន្តែ ដោយមានហេតុផលពិសេស វត្ថុ ឬសិទ្ធិរបស់កូនបំណុលមួយចំនួនត្រូវបានដកចេញពីទ្រព្យសម្បត្តិដែលទទួលខុសត្រូវរបស់កូនបំណុល គឺជាទ្រព្យសម្បត្តិដែលច្បាប់ហាមឃាត់មិនឲ្យធ្វើការ

[17] មាត្រា ៣៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[18] មាត្រា ៣៤៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[19] រូបទ្រព្យ សំដៅលើទ្រព្យដែលមានរូបជាក់ស្តែងជាចលនវត្ថុ ឬអចលនវត្ថុ ។

[20] អរូបទ្រព្យ សំដៅលើទ្រព្យដែលគ្មានរូបជាក់ស្តែង តែត្រូវទទួលស្គាល់ថាទ្រព្យដែរដូចជា កម្មសិទ្ធិបញ្ញា សិទ្ធិ ភាគហ៊ុន ជាដើម ។

[21] មាត្រា ៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

រឹបអូស (មាត្រា ៣៨០ ចលនវត្ថុដែលហាមឃាត់មិនឲ្យធ្វើការរឹបអូស ) ។ ហើយទ្រព្យសម្បត្តិ និងសិទ្ធិរបស់តតិយជន មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវនៅទេ ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិទាំងឡាយដែលកូនបំណុលនៃការអនុវត្តបានធ្វើអនុប្បទានដោយស្របច្បាប់ ដែលអនុប្បទានិកបានបំពេញគ្រប់លក្ខខ័ណ្ឌតតាំងរួចរាល់នៅមុនពេលចាប់ផ្ដើមអនុវត្តដោយបង្ខំនោះ ទ្រព្យសម្បត្តិដែលអនុប្បទាននោះមិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលទៀតនោះទេ ។ ប៉ុន្តែ ប្រសិនបើកូនបំណុលបានធ្វើអនុប្បទាននូវទ្រព្យសម្បត្តិ របស់ខ្លួនទាំងដឹងថា អនុប្បទាននោះនឹងនាំឲ្យមានការខូចខាតដល់ម្ចាស់បំណុល នោះម្ចាស់បំណុលអាចលុបចោលអនុប្បទានទុច្ចរិតនោះបានដើម្បីធ្វើបដិទាននូវទ្រព្យសម្បត្តិទទួលខុសត្រូវនឹងដាក់ទ្រព្យសម្បត្តិនោះ ជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយប្រើសិទ្ធិលុបចោលនូវអំពើដែលនាំឲ្យខូចខាតផលប្រយោជន៍របស់ម្ចាស់បំណុល ។[22]

ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឲ្យប្រគល់វត្ថុ កម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺជាវត្ថុដែលកូនបំណុលនៃការអនុវត្តកាន់កាប់ ឬសិទ្ធិទាមទារឲ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជន ។ ករណីដែលកម្មវត្ថុនៃការទាមទារឲ្យអនុវត្តនោះមានមនុស្សរស់នៅ អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចត្រូវធ្វើការរំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្តតាមនីតិវិធី ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបានការកាន់កាប់លើវត្ថុនោះ ដោយឲ្យម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះបញ្ហាញខ្លួនភ្លាមនៅកន្លែងអនុវត្ត ។[23] ដោយឡែកចំពោះការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុជាកម្មវត្ថុដែលត្រូវបានកាន់កាប់ដោយតតិយជន ហើយតតិយជននោះមានករណីកិច្ចត្រូវប្រគល់វត្ថុនោះទៅឲ្យកូនបំណុលនៃការអនុវត្ត នោះការអនុវត្តដោយបង្ខំនេះត្រូវធ្វើតាមនីតិវិធីតុលាការ ដោយត្រូវធ្វើការរឹបអូសសិទ្ធិទាមទារឲ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្តអាចអនុវត្តទាមទារសិទ្ធិនោះបាន ។[24] មួយវិញទៀតចំពោះ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការទទួលខុសត្រូវគឺជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដែលពាក់ព័ន្ធ ។

### កថាខណ្ឌទី៣៖ ការស្រាវជ្រាវទ្រព្យសម្បត្តិទទួលខុសត្រូវ

ការស្រាវជ្រាវអំពីវត្ថុដែលជាទ្រព្យសម្បត្តិទទួលខុសត្រូវ គឺដើម្បីធ្វើការកំណត់ថាទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិដែលត្រូវទទួលខុសត្រូវ ។ ជាគោលការណ៍ គឺធ្វើការកំណត់នៅតាមច្បាប់សារធាតុ ប៉ុន្តែជាបញ្ហាការដែលឲ្យស្ថាប័នអនុវត្ត ជាពិសេសអាជ្ញាសាលាធ្វើការកំណត់ទៅលើបញ្ហានេះទៅតាមច្បាប់សារធាតុនៅក្នុង

[22] មាត្រា ៤២៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៧

[23] មាត្រា ៥២៤ កថាខណ្ឌទី១និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[24] មាត្រា ៥២៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

នីតិវិធីនៃការអនុវត្តដោយបង្ខំនោះ មិនមែនជារឿងសមរម្យនោះទេ ហើយប្រសិនបើឲ្យស្ថាប័នអនុវត្តទទួលបន្ទុកលើការកំណត់នេះ វាអាចនឹងធ្វើឲ្យស្ថាប័នអនុវត្តមានការរារាំងក្នុងការអនុវត្តដោយបង្ខំដែលនាំឲ្យមានការលំបាកនៅក្នុងការចាប់ផ្តើមអនុវត្តដោយបង្ខំឲ្យបានឆាប់រហ័ស ។ ដូច្នេះហើយ បានជាក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឲ្យស្ថាប័នអនុវត្តអាចធ្វើសកម្មភាពដោយគ្រាន់តែផ្អែកទៅលើស្ថានភាពដែលសមរម្យ និងសមល្មមក្នុងការគិតឲ្យបានច្បាស់លាស់ថា តើទ្រព្យសម្បត្តិណាមួយដែលជាកម្មវត្ថុនៃការទទួលខុសត្រូវ ។ ជាក់ស្តែង ដូចជាការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ករណីដែលកូនបំណុលធ្វើការកាន់កាប់វត្ថុដោយជាក់ស្តែងនោះគឺជាលក្ខខណ្ឌមួយក្នុងការកំណត់ថាចលនវត្ថុនោះ គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ ។[25] ដោយឡែកចំពោះអចលនវត្ថុវិញ លិខិតបញ្ជាក់ ដូចជាលិខិតចម្លងយថាភូតមួយនៃការចុះបញ្ជីអចលនវត្ថុដោយដាក់ឈ្មោះកូនបំណុល ជាអាទិ៍ នោះក៏ជាលក្ខខ័ណ្ឌមួយគ្រាប់គ្រាន់ ។[26]មួយវិញទៀត ក្នុងករណីការអនុវត្តចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតវិញ គឺស្ថាប័នអនុវត្តធ្វើការកំណត់អំពីអត្ថិភាពនៃសិទ្ធិ ឬម្ចាស់បំណុលនោះ ដោយផ្អែលើការរៀបរាប់ជាលាយលក្ខណ៍អក្សរនៅក្នុងពាក្យសុំឲ្យអនុវត្តដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ ។[27] ដូច្នេះ ស្ថាប័នអនុវត្តអាចចាប់ផ្តើមអនុវត្តដោយបង្ខំដោយពុំចាំបាច់ធ្វើការស្រាវជ្រាវថា តើទ្រព្យសម្បត្តិនោះពិតជាទ្រព្យសម្បត្តិរបស់កូនបំណុលតាមច្បាប់សារធាតុដែរឬយ៉ាងណានោះទេ ។

**កថាខណ្ឌទី៤៖ ការទទួលខុសត្រូវដោយមានកម្រិត**

នៅក្នុងការអនុវត្តដោយបង្ខំ ជាគោលការណ៍ដើម្បីសម្រេចឲ្យបាននូវសិទ្ធិដែលមានគោលបំណងសងជាប្រាក់ ម្ចាស់បំណុលមានសិទ្ធិធ្វើការជ្រើសរើសទ្រព្យសម្បត្តិដើម្បីរឹបអូសបាននៅក្នុងចំណោមទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុល ។ ប៉ុន្តែចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ មិនត្រូវអនុវត្តឡើយ ហើយចំពោះប្រភេទសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវបានកម្រិត ឬទ្រព្យសម្បត្តិជាក់លាក់ណាមួយនៅក្នុងទំហំមួយជាក់លាក់ ហើយការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបានឡើយ ចំពោះទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុល ។

ការទទួលខុសត្រូវដោយមានកម្រិត គឺជាកាដាក់កម្រិតទៅលើទ្រព្យសម្បត្តិទទួលខុសត្រូវ ដោយទាញចេញពីលក្ខណៈរបស់សិទ្ធិទាមទារ ហើយមិនមែនជាការផាត់ចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវដោយផ្អែកលើមូលហេតុដែលកំណត់ក្នុងច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ដូចជាទ្រព្យសម្បត្តិដែលហាមឃាត់មិនឲ្យរឹបអូស ហើយបញ្ហានេះមិនមែនជារឿងដែលស្ថាប័នអនុវត្តត្រូវធ្វើការស្រាវជ្រាវនៅពេលធ្វើការអនុវត្តដោយបង្ខំនោះ

[25] មាត្រា ៣៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[26] មាត្រា ៤១៧ កថាខណ្ឌទី៣ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[27] មាត្រា ៤០៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

ទេ ។ ក្នុងករណីដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអនុភាពអនុវត្តមិនបញ្ជាក់អំពីចំណុច នេះទេ ហើយការអនុវត្តនោះធ្វើឡើងចំពោះទ្រព្យសម្បត្តិក្រៅពីទ្រព្យសម្បត្តិទទួលខុសត្រូវ នោះនាំឲ្យការអនុវត្ត នោះមិនមែនជាការអនុវត្តដោយខុសច្បាប់ទេ ។ ប៉ុន្តែ ដោយសារតែច្បាប់មិនអនុញ្ញាតឲ្យធ្វើការអនុវត្តដោយបង្ខំ ចំពោះទ្រព្យសម្បត្តិក្រៅពីទ្រព្យសម្បត្តិទទួលខុសត្រូវនោះទេ ដូច្នេះ តតិយជនដែលអះអាងថាខ្លួនមានសិទ្ធិលើ ទ្រព្យសម្បត្តិនោះ អាចទាមទារឲ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិរបស់ខ្លួនបាន តាមរយៈ បណ្តឹងតវ៉ារបស់តតិយជន ។[28] លើសពីនេះ ប្រសិនបើនៅក្នុងដំណើរការនៃនីតិវិធីចេញសាលក្រម ឬសាលដីកា មានភាពច្បាស់លាស់ថាទ្រព្យសម្បត្តិទទួលខុសត្រូវ ដើម្បីសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឲ្យសង ជាប្រាក់របស់ម្ចាស់បំណុលត្រូវបានកម្រិតត្រឹមវត្ថុ ឬទ្រព្យជាក់លាក់ណាមួយនៅក្នុងទំហំជាក់លាក់ នោះកូន បំណុលអាចដាក់មធ្យោបាយការពារខ្លួន ដោយបង្ហាញអំពីការទទួលខុសត្រូវដោយមានកម្រិតនៅក្នុងអំឡុង ពេលនៃនីតិវិធីនោះបាន ។ ប្រសិនបើ តុលាការយល់ឃើញអង្គហេតុតវ៉ាមានភាពត្រឹមត្រូវនោះ តុលាកាត្រូវចេញ សាលក្រម ឬសាលដីកាបញ្ជាក់អំពីការកម្រិតនោះនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬសាលដីកា ។ មួយវិញទៀត ប្រសិនបើមានមូលហេតុណាមួយដែលនាំឲ្យមានកាទទួលខុសត្រូវដោយមានកម្រិតកើតឡើងនៅ ពេលក្រោយ ពេលដែលបណ្តឹងត្រូវបានបញ្ចប់ នោះកូនបំណុលអាទទួលសាលក្រម តាមរយៈបណ្តឹងតវ៉ាចំពោះ ការទាមទារ[29]ដោយការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនេះ ត្រូវបានអនុញ្ញាតតែក្នុងទំហំនៃការ ទទួលខុសត្រូវដែលមានតែប៉ុណ្ណោះ ។

[28] មាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[29] មាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

# ជំពូកទី២
# លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

# ជំពូកទី២

# លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

## ផ្នែកទី១៖ ការរៀបចំដាក់ពាក្យសុំ

### កថាខណ្ឌទី១៖ ការចរចារ ការជ្រើសរើស និងការស្រាវជ្រាវ

ជាទូទៅ ម្ចាស់បំណុលព្យាយាមចង់អោយមានការអនុវត្តដោយស្ម័គ្រចិត្ត តែការចរចារនេះមិនមានចែងនៅក្នុងច្បាប់ទេ ប៉ុន្តែការអនុវត្តជាក់ស្តែងម្ចាស់បំណុលតែងតែធ្វើការចរចារជាមុនជាមួយកូនបំណុល ហើយនេះក៏ជាគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនផងដែរ ។ ប្រសិនបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបឈានដល់ការអនុវត្តដោយបង្ខំ បានសេចក្តីថា បើកូនបំណុលដែលជាអ្នកត្រូវអនុវត្តមិនព្រមបំពេញកាតព្វកិច្ចខ្លួនឲ្យទៅម្ចាស់បំណុលនោះទេ ទើបជាហេតុនាំឲ្យឈានដល់ការអនុវត្តដោយបង្ខំទៅតាមនីតិវិធីច្បាប់ ។

### កថាខណ្ឌទី១៖ ការសរសេរពាក្យសុំអនុវត្តដោយបង្ខំ

ចំពោះការសរសេរពាក្យសុំអនុវត្តដោយបង្ខំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ទៅស្ថាប័នអនុវត្ត ដោយក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរនោះត្រូវបំពេញនូវចំណុចដូចខាងក្រោម៖

-ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

-សញ្ញាណនៃលិខិតអនុវត្ត ។

-សេចក្តីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល ។

-សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំ ដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ។

-ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។ [30]

### កថាខណ្ឌទី៣៖ ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ ចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច តុលាការអនុវត្ត ឬអាជ្ញាសាលា។[31]

[30] មាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[31] មាត្រា ៣៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

នៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរ ត្រូវមានបញ្ជាក់អំពីប្រភេទនៃការអនុវត្តដោយបង្ខំដែលសុំឱ្យធ្វើការអនុវត្ត (ការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬការបង្ខំដោយប្រយោល) ។ ក្នុងករណីដែលសុំឱ្យអនុវត្តតាមរយៈការបង្ខំដោយផ្ទាល់ ត្រូវបញ្ជាក់ផងដែរលើលិខិតនោះនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ (ចលនវត្ថុ អចលនវត្ថុ ឬសិទ្ធិលើបំណុល ជាអាទិ៍) ហើយក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬ ការអនុវត្តដោយបង្ខំដោយប្រយោលត្រូវបញ្ជាក់នូវខ្លឹមសារនៃសេចក្តីសម្រេចដែលទាមទារឱ្យមានការអនុវត្តនោះ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តផងដែរ។[32]

បន្ថែមពីលើនេះ អាស្រ័យទៅតាមប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំដែលសុំឱ្យធ្វើនៅក្នុងករណីមួយចំនួនមានការតម្រូវឱ្យសរសេររៀបរាប់ក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរអំពីចំណុចដើម្បីកំណត់ដោយជាក់លាក់នូវកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ក៏ដូចជាការតម្រូវឱ្យដាក់ឯកសារបញ្ជាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងកម្មវត្ថុនោះផងដែរ ។ ដូចជា ដីកាសម្រេចរឹបអូស[33] នៅពេលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំម្ចាស់បំណុលត្រូវបង់ពន្ធដាក់ពាក្យសុំទៅស្ថាប័នអនុវត្ត [34]ឬត្រូវបង់ប្រាក់កម្រៃជាមុនជាដើម ។[35] ហើយលើសពីនេះ ក៏ត្រូវបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តដោយបង្ខំផងដែរ ។[36]

## ផ្នែកទី២៖ ការរៀបចំឯកសាររបស់ម្ចាស់បំណុល

### កថាខណ្ឌទី១៖ លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាព

លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ត្រូវភ្ជាប់មកជាមួយនឹងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។ ជាគោលការណ៍ គឺជាលិខិតចម្លងយថាភូតនៃលិខិតអនុវត្ត[37]ដែលភាគីម្ចាស់បំណុលនៃការអនុវត្តមានហើយដែលបានទទួលនូវការផ្តល់រូបមន្តអនុវត្តនៅផ្នែកខាងក្រោមនៃលិខិតនោះ ។[38] ប៉ុន្តែ ចំពោះសាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន និងដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នវិញ ពុំចាំបាច់មានរូបមន្តអនុវត្តទេ ឱ្យតែការអនុវត្តដោយបង្ខំនោះធ្វើឡើងរវាងភាគីដែល

[32] មាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[33] មាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[34] មាត្រា៣៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[35] ជំពូកទី៦ កម្រៃនិងសោហ៊ុយ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា
[36] មាត្រា ៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦ និង មាត្រា៣៣ថ្មី នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា
[37] មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[38] មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

បានកំណត់នៅក្នុងលិខិតអនុវត្តនោះ ពោលគឺថាលិខិតចម្លងយថាភូតទាំងនោះត្រូវចាត់ទុកជាលិខិតចម្លងយថាភូតដែលមានអានុភាពអនុវត្តតែម្តង ។[39]

ម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើការបញ្ជាក់អំពីអត្ថិភាព និងអត្ថន័យនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ (អត្ថន័យនៃសិទ្ធិទាមទាររបស់ម្ចាស់សិទ្ធិ និងកូនបំណុល) និងដែលត្រូវសម្រេចដោយការអនុវត្តដោយបង្ខំ តាមវិធីនៃការដាក់លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តដែលខ្លួនមានទៅឱ្យស្ថាប័នអនុវត្ត ។ សិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុត្រូវបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ហើយអានុភាពអនុវត្តនៃលិខិតអនុវត្តនោះត្រូវបានបញ្ជាក់តាមទម្រង់យថាភូតដោយការផ្តល់រូបមន្តអនុវត្តដែលជាសេចក្តីសរសេរបន្ថែមនៅក្នុងលិខិតនោះ ។ តាមរយៈវិធីនេះវាធ្វើឱ្យមានភាពប្រាកដថា ម្ចាស់បំណុលនៃការអនុវត្តមានសិទ្ធិទាមទារចំពោះអាជ្ញាធររដ្ឋឱ្យធ្វើការអនុវត្តដោយបង្ខំ(សិទ្ធិនេះ ហៅថា "**សិទ្ធិទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំ**") និងថាម្ចាស់បំណុលនោះមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីប្រើសិទ្ធិនោះ ។

ក្នុងន័យនេះ សិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុត្រូវបានបញ្ជាក់នៅក្នុងឯកសារមួយដែលហៅថា **លិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត** ហើយឯកសារនេះនឹងក្លាយទៅជាមូលដ្ឋាននៃនីតិវិធីនៃការអនុវត្តដោយបង្ខំ ។ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីមួយដែលធ្វើឡើងដើម្បីសម្រេចនូវសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សារធាតុ ។ ប៉ុន្តែ ស្ថាប័នអនុវត្តពុំធ្វើការសម្រេចសេចក្តីដោយផ្ទាល់ទៅលើអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលកំណត់ដោយច្បាប់សាធាតុទេ គឺគ្រាន់តែទទួលស្គាល់ដោយប្រយោល និងជាទម្រង់នូវអត្ថិភាពនៃសិទ្ធិនោះតាមរយៈលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្តប៉ុណ្ណោះ ហើយការទទួលស្គាល់នេះ គឺជាការបើកផ្លូវសម្រាប់នីតិវិធីជាបន្តទៀត ។[40]

### កថាខណ្ឌទី២៖ លិខិតអនុវត្ត

ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្ត ។[41] លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ដែលកំណត់នៅក្រោមនីតិឯកជនហើយឯកសារនោះអាចសម្រេចនូវសិទ្ធិទាមទារតាមរយៈការអនុវត្តដោយបង្ខំ ។ លិខិតអនុវត្តរួមមាន សេចក្តីសម្រេចរបស់តុលាការ ជាប្រភេទសាលក្រម សាលដីកា ឬ ដីកាសម្រេចកំណត់ហេតុផ្សេងៗ តាមផ្លូវតុលាការដែលមាន

[39] មាត្រា ៣៥៤ កថាខណ្ឌទី១ វាយ្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[40] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២

[41] មាត្រា ៣៥០កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

អានុភាពតាមសេចក្តីសម្រេចតុលាការ លិខិតយថាភូតដែលធ្វើឡើងដោយសារការីដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី ហើយបានបំពេញគ្រប់លក្ខខណ្ឌទាមទារមួយចំនួន និងការចាត់ចែងរបស់ក្រឡាបញ្ជីស្តីពីការកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី ។[42] ទោះបីជាទទួលបានលិខិតអនុវត្តក៏ដោយ ក៏លិខិតនេះពុំមានអានុភាពអាចយកទៅអនុវត្តដោយបង្ខំបានទេ ។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត លើកលែងតែសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិចជាអាទិ៍។[43]

## កថាខណ្ឌទី៣៖ រូបមន្តអនុវត្ត

### ១. គោលគំនិតនៃរូបមន្តអនុវត្ត

` រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬសារការីសរសេរបញ្ជាក់បន្ថែមផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងនត្ថិភាពនៃអំណាចបង្ខំឱ្យអនុវត្តនៃលិខិតអនុវត្តនោះ ។ ដើម្បីទទួលបានរូបមន្តអនុវត្តម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ហើយត្រូវសរសេរនូវចំណុចមួយចំនួន ដូចមានចែងនៅក្នុងមាត្រា៣៥៥ កថាខណ្ឌទី១ ប៉ុន្តែប្រសិនបើ លិខិតអនុវត្តនោះជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាព ពោលគឺមិនចូលជាស្ថាពរម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយនឹងលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ លិខិតបញ្ជាក់សាលក្រមស្ថាពរ ជាអាទិ៍ដែលអនុវត្តតាមមាត្រា២៥៨ កថាខណ្ឌទី១ ។ [44]

ផ្ទុយទៅវិញ ប្រសិនបើសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ឬការអនុវត្តដោយបង្ខំកំណត់យកបុគ្គលផ្សេងក្រៅពីបុគ្គលដែលបានកំណត់នៅក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត ក្នុងករណីនេះចាំបាច់ត្រូវមានរូបមន្តអនុវត្តផ្សេងទៀត ហៅថា **រូបមន្តអនុវត្តពិសេស។** [45]

ជាគោលការណ៍ រូបមន្តអនុវត្តត្រូវបានប្រគល់ឱ្យតែមួយច្បាប់ប៉ុណ្ណោះ ប៉ុន្តែក្នុងករណីដែលគោលបំណងនៃការអនុវត្តអាចសម្រេចពេញលេញបាន លុះត្រាតែការអនុវត្តនោះត្រូវធ្វើឡើងតាមវិធីជាច្រើនដូចជា នៅទីកន្លែងច្រើន ឬចំពោះចលនវត្ថុផង អចលនវត្ថុផង ដោយផ្អែកលើលិខិតអនុវត្តតែមួយ ជាអាទិ៍ ម្ចាស់បំណុលមានភាពចាំបាច់ត្រូវតែសុំផ្តល់រូបមន្តអនុវត្តច្រើន ។[46]

---

[42] មាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧

[43] មាត្រា ៣៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧

[44] មាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧

[45] មាត្រា ៣៥៦ កថាខណ្ឌទី១-ទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧

[46] មាត្រា ៣៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧

ហេតុផលនៃការតម្រូវឱ្យដាក់បន្ថែមនូវរូបមន្តអនុវត្តទៅនឹងលិខិតអនុវត្តមានដូចតទៅ ៖ **ទីមួយ** ដោយសារថា ស្ថាប័នអនុវត្តមិនមែនជាតុលាការនៃបណ្តឹងទេ ដូច្នេះ វាមិនមែនជាការសមស្របទេ បើឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើអានុភាពអនុវត្តនៃលិខិតអនុវត្ត នៅពេលណាមានពាក្យសុំឱ្យអនុវត្តដោយបង្ខំម្តងៗ ដែលការណ៍នេះនឹងនាំឱ្យមានការយឺតយ៉ាវនៅក្នុងការអនុវត្តដោយបង្ខំ ។ **ទីពីរ** នៅក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវធ្វើឡើងចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត នោះចាំបាច់ត្រូវធ្វើការពិនិត្យស្រាវជ្រាវថា តើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តដែរឬទេ (បុគ្គលនោះមានលក្ខណៈក្នុងការធ្វើជាភាគីនៃការអនុវត្តដោយបង្ខំដែរឬទេ) ហើយប្រសិនបើបុគ្គលនោះ ជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តមែន នោះត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្តដោយធ្វើការរៀបរាប់អំពីចំណុចនោះនៅក្រោមទម្រង់ជារូបមន្តអនុវត្ត ។ អត្ថិភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ ។ ម៉្យាងទៀត ប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តហើយនោះ ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយមិនបាច់ពិនិត្យពិចារណាលើខ្លឹមសារនៃលិខិតអនុវត្តនោះទេ ។ ហេតុនេះហើយ ទោះបីជាឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តខុសគ្នាពីលិខិតអនុវត្តច្បាប់ដើម ឬប្រសិនបើរូបមន្តអនុវត្តនោះត្រូវបានផ្តល់ដើម្បីជាផលប្រយោជន៍ ឬទៅឱ្យបុគ្គលណាម្នាក់ដែលពុំមានលក្ខណៈជាភាគីនៃការអនុវត្តដោយបង្ខំក៏ដោយ ឬទោះបីជាលិខិតអនុវត្តនោះបានបាត់បង់អានុភាពក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះនៅតែជាការអនុវត្តស្របតាមច្បាប់ស្តីពីការអនុវត្តដោយបង្ខំដែរ ។

ចំពោះឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តមានអានុភាពនៅគ្រប់ទីកន្លែងទាំងអស់ដែលស្ថិតនៅក្រោមសិទ្ធិជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំនៅទីកន្លែងណាមួយក៏បានដោយផ្អែកលើឯកសារចម្លងយថាភូតនោះ ។ ជាងនេះទៅទៀត អានុភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនេះពុំមានការកម្រិតអំឡុងពេលដែលមានអានុភាពនោះទេ ។[47]

### ២.ភាពចំាបាច់នៃរូបមន្តអនុវត្ត

ជាគោលការណ៍ ទោះបីជាមានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ប៉ុន្តែដើម្បីអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគបាន ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូប

[47] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២

មន្តអនុវត្តជាមុនសិន ។ ទោះបីជាលិខិតអនុវត្តដែលម្ចាស់បំណុលមានសេចក្តីប្រកាសថាការអនុវត្តដោយបង្ខំអាចធ្វើទៅបានដោយផ្អែកលើលិខិតនោះ ដូចជាករណីនៃសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន[48] ឬលិខិតដែលបញ្ជាក់ឲ្យអនុវត្ត [49]ជាអាទិ៍ ក៏ដោយក៏ចាំបាច់ត្រូវតែបានទទួលការផ្តល់រូបមន្តអនុវត្តជាមុនសិនដែរ ។

ជាករណីលើកលែង ប្រសិនបើលិខិតអនុវត្តគឺជាសាលក្រមរឿងក្តីចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបញ្ចាំងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យ អនុវត្តជាបណ្តោះអាសន្ននោះពុំចាំបាច់មានរូបមន្តអនុវត្តទេ ។[50] ដោយសារថា គោលបំណងនៃនីតិវិធីដែលនាំទៅដល់ការចេញលិខិតអនុវត្តទាំងនេះ គឺដើម្បីផ្តល់នូវលិខិតអនុវត្តដោយងាយស្រួល និងឆាប់រហ័ស ដូច្នេះប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតទាំងនេះ ហើយចាំបាច់ម្ចាស់បំណុលត្រូវតែអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតទាំងនោះបានភ្លាម ។ ក៏ប៉ុន្តែ ទោះបីជាក្នុងករណីនៃការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តទាំងនេះក៏ដោយ ប្រសិនបើ ការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថា ជាម្ចាស់បំណុលនៃការអនុវត្ត ឬប្រសិនបើមានការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិអនុវត្តថា ជាកូនបំណុលនៃការអនុវត្តនោះចាំបាច់ត្រូវទទួលបាននូវរូបមន្តអនុវត្តពិសេស ។[51]

សរុបសេចក្តីទៅ គេអាចដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តមួយចំនួនដូចបានរៀបរាប់ខាងលើ ដោយពុំចាំបាច់មានរូបមន្តអនុវត្តបានតែក្នុងករណីដែលភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តនោះ គឺជាម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ។[52]

## ៣. នីតិវិធីផ្តល់នៃការរូបមន្តអនុវត្ត

### ៣.១. ស្ថាប័នផ្តល់រូបមន្តអនុវត្ត

ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រម ឬសាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្ត (ស្ថាប័នផ្តល់រូបមន្តអនុវត្ត) គឺក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនៃបណ្តឹងដែលនាំទៅ

[48] មាត្រា ៣៥០ កថាខណ្ឌទី ២ វាយ្យខ័ណ្ឌ ខ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[49] មាត្រា ៣៥០ កថាខណ្ឌទី ៦ វាយ្យខ័ណ្ឌ ច ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[50] មាត្រា ៣៥៤ កថាខណ្ឌ ១ វាក្យខណ្ឌ ២ និង ចំណុច ក ដល់ ត ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[51] មាត្រា ៣៥៦ កថាខណ្ឌ ២ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[52] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២

ដល់ការចេញសាលក្រម ឬសាលដីកានោះ។[53] មូលហេតុនៃការយកទីកន្លែងដែលទុកសំណុំរឿងធ្វើជាលក្ខខណ្ឌ ដើម្បីកំណត់ថា តើក្រឡាបញ្ជីនៃតុលាការណាមួយដែលត្រូវដើរតួនាទីជាស្ថាប័នផ្តល់រូបមន្តអនុវត្តនោះ ពីព្រោះថា ឯកសារចាំបាច់បំផុតសម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃសាលក្រម ឬសាលដីកាដែលជាលិខិតអនុវត្តនោះ មានអត្ថិភាព ឬនត្ថិភាពនៃអានុភាពអនុវត្តជាអាទិ៍ក្នុងសំណុំរឿងនៃបណ្តឹងនោះ ។ ដោយហេតុនេះ វាជាការសមស្របបំផុតដែលឱ្យក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះធ្វើជាស្ថាប័នផ្តល់រូបមន្តអនុវត្ត ។ ដូចគ្នានេះដែរ ចំពោះករណីដែលលិខិតអនុវត្តគឺជាសេចក្តីសម្រេចផ្សេងទៀត កំណត់ហេតុរបស់តុលាការ ឬការចាត់ចែងរបស់ក្រឡាបញ្ជី ហើយស្ថាប័នផ្តល់រូបមន្តអនុវត្ត គឺក្រឡាបញ្ជីដែលរក្សាទុកសំណុំរឿងដែលជាឯកសារចាំបាច់សម្រាប់ការស្រាវជ្រាវអំពីអានុភាពនៃលិខិតអនុវត្តនោះ ។[54]

ក្នុងករណីដែលលិខិតអនុវត្ត គឺជាលិខិតបញ្ជាក់អនុវត្ត នោះសារការីដែលជាអ្នករក្សាទុកនូវច្បាប់ដើមនៃលិខិតបញ្ជាក់នោះ គឺជាស្ថាប័នផ្តល់រូបមន្តអនុវត្ត ។[55]

### ៣.២. ចំណុចដែលត្រូវធ្វើការស្រាវជ្រាវ

ចំណុចដែលស្ថាប័នផ្តល់រូបមន្តអនុវត្តត្រូវធ្វើការស្រាវជ្រាវនៅពេលផ្តល់រូបមន្តអនុវត្ត គឺចំណុចដែលនឹងរៀបរាប់ពីចំណុច (ក) ដល់ចំណុច (ច) ខាងក្រោម៖

**(ក).សុពលភាពនៃឯកសារជាលិខិតអនុវត្ត:** ប្រសិនបើជាសាលក្រម ឬសាលដីកាត្រូវតែជាសាលក្រម ឬសាលដីកាដែលត្រូវបានប្រកាស និងដែលមិនបាត់បង់អានុភាពដោយសារការលុបចោលនៅក្នុងការជំនុំជម្រះនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬការជំនុំជម្រះសាជាថ្មី ។

**(ខ) ភាពសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃខ្លឹមសារនៃលិខិតអនុវត្ត**: បើជាសាលក្រម ឬ សាលដីកាដែលត្រូវតែជាសាលក្រម ឬ សាលដីកាដែលកំណត់ជាស្ថាពរនូវករណីយកិច្ចផ្តល់តាវកាលិកដែលអាចអនុវត្តបាន ។ ប៉ុន្តែ បើជាលិខិតបញ្ជាក់អនុវត្តវិញ ត្រូវបំពេញគ្រប់ល័ក្ខខ័ណ្ឌទាមទារដើម្បីក្លាយជាលិខិតអនុវត្ត ។[56]

**(គ) ការកើតឡើង និងមានអត្ថិភាពនៃអានុភាពអនុវត្តរបស់លិខិតអនុវត្ត:** សាលក្រម ឬសាលដីកាត្រូវតែជាសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរជាដើម ។[57] ប៉ុន្តែ បើជាសាលក្រម ឬសាលដីកាដែលមិនទាន់ចូលជាស្ថាពរគឺត្រូវមានភ្ជាប់មកជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ហើយអានុភាពនៃការ

[53] មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[54] មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[55] មាត្រា ៣៥៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[56] មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[57] មាត្រា ១៩៣ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ មិនបានរលត់នាពេលក្រោយដោយសារការលុបចោលការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នជាដើមនោះទេ ។[58]

**(ឃ) ការបានបំពេញគ្រប់ល័ក្ខខ័ណ្ឌបង្អង់:** ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ និងការមកដល់នូវពេលកំណត់ក្នុងករណីដែលសិទ្ធិទាមទារនោះមានពេលកំណត់មិនពិតប្រាកដ ។[59] ហើយល័ក្ខខ័ណ្ឌបង្អង់ត្រូវតែជាល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ហើយដែលម្ចាស់បំណុលត្រូវបញ្ជាក់អំពីការបានបំពេញលក្ខខណ្ឌនោះ ។ នៅក្នុងករណីបែបនេះ រូបមន្តអនុវត្តដែលបានផ្ដល់ក្រោយនៅពេលដែលការបានបំពេញលក្ខខណ្ឌបង្អង់ ឬការមកដល់នៃពេលកំណត់មិនពិតប្រាកដនោះ ត្រូវបានទទួលស្គាល់ត្រូវហៅថា **រូបមន្តអនុវត្តពិសេស ឬរូបមន្តអនុវត្តបន្ថែម** ។ ក្នុងករណីដែលក្រឡាបញ្ជីផ្ដល់រូបមន្តអនុវត្តពិសេសក្រឡាបញ្ជីនោះ ត្រូវទទួលសេចក្ដីការអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន ។[60] ដោយឡែក ចំពោះហេតុដែលថាសិទ្ធិទាមទារមានភ្ជាប់ជាមួយនឹងលក្ខខណ្ឌ តែលក្ខខណ្ឌនោះមិនបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត ឬចំពោះករណីដែលកូនបំណុលត្រូវបញ្ជាក់អំពីលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតអនុវត្ត (ឧទាហរណ៍ ល័ក្ខខ័ណ្ឌរំលាយ) ហេតុដែលថាសិទ្ធិទាមទារនេះមានភ្ជាប់ជាមួយនឹងលក្ខខណ្ឌ ឬថាសិទ្ធិទាមទារនោះបានរលត់ដោយសារការបានបំពេញលក្ខខណ្ឌរួចទៅហើយ ទាំងនេះគឺជាចំណុចដែលកូនបំណុលត្រូវលើកមកអះអាងដោយការដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារនោះ ពោលគឺវាមិនមែនជាចំណុចដែលត្រូវធ្វើការស្រាវជ្រាវនៅពេលផ្ដល់រូបមន្តអនុវត្តទេ ។ មួយវិញទៀត ក្នុងករណីដែលមានការដាក់លក្ខខណ្ឌដែលតម្រូវឱ្យដាក់ប្រាតិភោគ ឬតម្រូវឱ្យផ្ដល់តាវកាលិកតបដើម្បីអាចអនុវត្តដោយបង្ខំបាន ស្ថានភាពទាំងនោះត្រូវតែស្រាវជ្រាវដោយស្ថាប័នអនុវត្ត[61] ពោលគឺវាមិនមែនជាចំណុចដែលត្រូវធ្វើការស្រាវជ្រាវនៅពេលផ្ដល់រូបមន្តអនុវត្តទេ ។

**(ង) ក្នុងករណីដែលបុគ្គលផ្សេងពីភាគី**: ដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តជាអ្នកសុំឱ្យផ្ដល់រូបមន្តអនុវត្តដើម្បីយកទៅដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំដោយតាំងខ្លួនជាម្ចាស់បំណុលនៃការអនុវត្ត ឬក្នុងករណីដែលមានការសុំឱ្យផ្ដល់រូបមន្តអនុវត្តដើម្បីយកទៅដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះបុគ្គលផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តដោយចាត់ទុកបុគ្គលនោះជាកូនបំណុលនៃការអនុវត្ត នោះអានុភាពអនុវត្តនៃលិខិតអនុវត្តដែលពាក់ព័ន្ធនោះត្រូវមានឥទ្ធិពលលើបុគ្គលទាំងនោះ ។[62]

[58] មាត្រា ១៩៧ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[59] មាត្រា ៣៥៦ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[60] មាត្រា ៣៥៦ កថាខណ្ឌ៤ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[61] មាត្រា ៣៦១ កថាខណ្ឌទី២ និងទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[62] មាត្រា ៣៥៦ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

**(ច) ភាពចាំបាច់ ឬមិនចាំបាច់ក្នុងការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់:** គឺនៅក្នុងករណីដែលមានការសុំឱ្យផ្តល់រូបមន្តអនុវត្តច្រើនសម្រាប់លិខិតអនុវត្តតែមួយ ដោយការផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតច្រើនច្បាប់ជាដើម ។[63]

នៅក្នុងករណីដែលគោលបំណងនៃការអនុវត្តដោយបង្ខំ អាចសម្រេចបានពេញលេញលុះត្រាតែការអនុវត្តនោះត្រូវបានធ្វើឡើងតាមវិធីជាច្រើន ដូចជាករណីដែលការអនុវត្តដោយបង្ខំត្រូវធ្វើឡើងនៅកន្លែងជាច្រើន ឬត្រូវធ្វើឡើងចំពោះអចលនវត្ថុផង និងចលនវត្ថុផង ដោយផ្អែកលើលិខិតអនុវត្តតែមួយជាអាទិ៍ នោះម្ចាស់បំណុលនៃការអនុវត្តមានភាពចាំបាច់ត្រូវតែសុំឱ្យផ្តល់រូបមន្តអនុវត្ត លើឯកសារចម្លងយថាភូតជាច្រើនច្បាប់នៃលិខិតអនុវត្ត ។ ម្យ៉ាងទៀត ក្នុងករណីដែល បាត់លិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះចាំបាច់ត្រូវសុំលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តមួយទៀត ។ ក៏ប៉ុន្តែ ប្រសិនបើផ្តល់រូបមន្តអនុវត្តនៅលើឯកសារចម្លងយថាភូតជាច្រើនច្បាប់ដោយហួសពីភាពចាំបាច់ នោះកូនបំណុលនៃការអនុវត្តអាចនឹងទទួលការអនុវត្តដោយបង្ខំម្តងហើយម្តងទៀត ដែលការណ៍នេះនឹងនាំឱ្យមានហានិភ័យ ដោយហេតុថាការផ្តល់តាវកាលិកដោយបង្ខំនឹងសម្រេចបានច្រើនជាងចំនួនដែលត្រូវផ្តល់ពីដំបូង ។ អាស្រ័យហេតុនេះហើយ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ នោះត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្តអំពីហេតុការណ៍ និងមូលហេតុនោះ និងចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត។[64]

ការស្រាវជ្រាវអំពីចំណុចខាងលើទាំងនេះត្រូវធ្វើឡើងដោយស្ថាប័នផ្តល់រូបមន្តអនុវត្ត ដោយផ្អែកលើសំណុំរឿងនៃបណ្តឹង និងលិខិតបញ្ជាក់ដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ ជាអាទិ៍ ជាពិសេសអំពីការផ្តល់រូបមន្តអនុវត្តពិសេស ។[65]

ដោយឡែក ចំពោះអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារវិញ ស្ថាប័នផ្តល់រូបមន្តអនុវត្តមិនបាច់ធ្វើការស្រាវជ្រាវទេ ពីព្រោះថា រូបមន្តអនុវត្តគ្រាន់តែបញ្ជាក់ជាផ្លូវការនូវអានុភាពអនុវត្តនៃលិខិតអនុវត្តតែប៉ុណ្ណោះ គឺមិនបញ្ជាក់ជាផ្លូវការ អំពីអត្ថិភាពនៃសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតនោះទេ ។ ម៉្យាងទៀត ស្ថាប័នផ្តល់រូបមន្តអនុវត្តមិនបាច់ធ្វើការស្រាវជ្រាវអំពីចំណុចដែលស្ថាប័នអនុវត្តត្រូវស្រាវជ្រាវនៅពេលធ្វើការអនុវត្តដោយបង្ខំនោះទេ ។[66]

---

63 មាត្រា ៣៥៨ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

64 មាត្រា ៣៥៨ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

65 មាត្រា ៣៥៦ កថាខណ្ឌទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

66 មាត្រា ៣៦១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

### ៣.៣. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត

ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តត្រូវរៀបរាប់ពីឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តលិខិតអនុវត្ត ព្រមទាំងខ្លឹមសារនៃរូបមន្តអនុវត្តដែលសុំឱ្យផ្តល់ ។[67] ម្ចាស់បំណុលនៃការអនុវត្តត្រូវបញ្ជាក់អំពីចំណុចនានាដែលស្ថាប័នផ្តល់រូបមន្តអនុវត្តត្រូវស្រាវជ្រាវ ប្រសិនបើមានការចាំបាច់ ។ ឧទាហរណ៍ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា ប្រសិនបើពុំមានភាពច្បាស់លាស់នៅក្នុងសំណុំរឿងថា តើសាលក្រម ឬសាលដីកានោះបានចូលជាស្ថាពរហើយ ឬនៅ (មាត្រា ៣៥៥ កថាខណ្ឌទី២) ឬត្រូវបញ្ជាក់អំពីការផ្ទេរសមត្ថភាពធ្វើជាភាគីនៃការអនុវត្តដោយបង្ខំ ដោយដាក់លិខិតបញ្ជាក់នៃអនុប្បទានសិទ្ធិលើបំណុលជាអាទិ៍។ [68]

ក្រឡាបញ្ជី ឬសារការីត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាពនៃលក្ខខណ្ឌទាមទារនានា សម្រាប់ការផ្តល់រូបមន្តអនុវត្ត ដោយធ្វើការសម្រេចដោយឯករាជ្យ និងដោយឆន្ទានុសិទ្ធិ ថាតើគួរផ្តល់រូបមន្តអនុវត្តតាមពាក្យសុំ ឬមិនផ្តល់ ។ ក៏ប៉ុន្តែ ដើម្បីផ្តល់រូបមន្តអនុវត្តពិសេស[69] ក្រឡាបញ្ជីត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន (មាត្រា ៣៥៦ កថាខណ្ឌទី៣) ។ នៅពេលសរសេរបន្ថែមនូវរូបមន្តអនុវត្តនៅក្នុងឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ក្រឡាបញ្ជី ឬសារការីត្រូវសរសេរអំពីហេតុការណ៍នៃការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ នៅក្នុងច្បាប់ដើមនៃលិខិតអនុវត្តនោះដូចខាងក្រោមនេះ៖

- ហេតុការណ៍នៃការផ្តល់រូបមន្តអនុវត្ត ថ្ងៃ ខែ ឆ្នាំដែលផ្តល់ និងចំនួនឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត ។
- ទំហំដែលអាចអនុវត្តដោយបង្ខំបាន ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តចំពោះតែមួយផ្នែកនៃសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ។
- ហេតុការណ៍ និងឈ្មោះ ឬនាមករណ៍របស់ម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ។[70]

[67] មាត្រា ៣៥៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[68] មាត្រា ៣៥៦ កថាខណ្ឌទី២ និងទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[69] មាត្រា៣៥៦ កថាខណ្ឌទី១ និងទី២ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[70] មាត្រា ៣៥៩ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ជាគោលការណ៍ ការផ្តល់រូបមន្តអនុវត្តមិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្តនៅក្នុងលិខិតចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ត្រូវជូនដំណឹងអំពីហេតុនោះទៅកូនបំណុលនៃការអនុវត្តឱ្យបានដឹង ។[71]

### ៣.៤.វិញ្ញត្តិនៃរូបមន្តអនុវត្ត

នៅក្នុងរូបមន្តអនុវត្ត ត្រូវសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ។[72] នៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្តត្រូវសរសេរបញ្ជាក់អំពីបុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបានដោយលិខិតអនុវត្តនោះ និងភាគីម្ខាងទៀត ។ ឧទាហរណ៍ ក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដែលមាន A ជាដើមបណ្តឹង និង B ជាចុងចម្លើយ នោះនៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្តត្រូវសរសេរថា "ដើមចោទ A អាចធ្វើការអនុវត្តដោយបង្ខំ ចំពោះចុងចម្លើយ B ដោយផ្អែកលើសាលក្រមនេះ" ។ នៅក្នុងរូបមន្តអនុវត្តដែលផ្តល់ឱ្យជាផលប្រយោជន៍សម្រាប់បុគ្គលផ្សេងក្រៅពីភាគី ឬទល់នឹងបុគ្គលផ្សេងក្រៅពីភាគី ត្រូវរៀបរាប់អំពីឈ្មោះ ឬនាមករណ៍របស់បុគ្គលនោះ ព្រមទាំងលក្ខណៈដែលអាចឱ្យបុគ្គលនោះក្លាយជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត ។[73] ឧទាហរណ៍ នៅក្នុងករណីខាងលើ ប្រសិនបើរូបមន្តអនុវត្តត្រូវបានផ្តល់ឱ្យជាផលប្រយោជន៍សម្រាប់ C ដែលជាសន្តតិជនរបស់ដើមចោទ A និងទល់នឹង D ដែលជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុ នោះនៅក្នុងរូបមន្តអនុវត្តត្រូវសរសេរថា C ដែលជាសន្តតិជន (ប្រតិសិទ្ធិ) របស់ដើមចោទ A អាចធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមនេះ ចំពោះ D ដែលជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុសម្រាប់ចុងចម្លើយ B បាន ។[74]

ប្រសិនបើ រូបមន្តអនុវត្តត្រូវបានផ្តល់សម្រាប់តែសិទ្ធិទាមទារណាមួយជាក់លាក់នៅក្នុងចំណោមសិទ្ធិទាមទារច្រើនដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ឬចំពោះតែភាគីណាមួយជាក់លាក់ នៅក្នុងចំណោមភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត នោះត្រូវរៀបរាប់ចំណុចនោះឱ្យបានច្បាស់លាស់នៅក្នុងវិញ្ញត្តិនៃរូបមន្តអនុវត្ត ។[75] មួយវិញទៀត ប្រសិនបើផ្តល់រូបមន្តអនុវត្តនៅក្នុងឯកសារចម្លងយថាភូតច្រើនច្បាប់ ឬក៏នៅក្នុងលិខិតចម្លងយថាភូតដែលបានចេញសារជាថ្មី ក៏ត្រូវរៀបរាប់ចំណុចនោះឱ្យបានច្បាស់លាស់ផងដែរ ។[76]

[71] មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[72] មាត្រា ៣៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[73] មាត្រា ៣៥៧ កថាខណ្ឌទី១ វាក្យខណ្ឌ ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[74] មាត្រា ៣៥១ កថាខណ្ឌទី១ វាក្យខណ្ឌ គ និង កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[75] មាត្រា៣៥៧ កថាខណ្ឌទី១ វាក្យខណ្ឌ គ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[76] មាត្រា ៣៥៧ កថាខណ្ឌទី១ វាក្យខណ្ឌ ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

## ៤. ការសង្គ្រោះសម្រាប់ម្ចាស់បំណុល

### ៤.១. ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍

ក្នុងករណីដែលក្រឡាបញ្ជីបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ ដើម្បីធ្វើឧបាស្រ័យទៅនឹងការចាត់ចែងនេះ ។[77] ដោយឡែកក្នុងករណីដែលសារការីបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃការិយាល័យរបស់សារការីនោះបាន ។ ប្រសិនបើមានការដាក់ពាក្យសុំតវ៉ាបែបនេះតុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវនៃការតវ៉ានោះដោយដីកាសម្រេច ។[78] ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ានោះមិនមានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវចេញដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ានោះ ។ ម្ចាស់បំណុលនៃការអនុវត្តមិនអាចដាក់ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចនេះបានឡើយ។ ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យស្ថាប័នផ្តល់រូបមន្តអនុវត្តផ្តល់នូវរូបមន្តអនុវត្តនោះ ។ ប្រសិនបើមានដីកាសម្រេចបង្គាប់ដូចនេះក្រឡាបញ្ជី ឬសារការីត្រូវផ្តល់រូបមន្តអនុវត្តនោះតាមការបង្គាប់របស់តុលាការ ។[79]

### ៤.២.ការដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ប្រសិនបើស្ថាប័នផ្តល់រូបមន្តអនុវត្តបដិសេធមិនផ្តល់រូបមន្តអនុវត្តពិសេស ដោយមូលហេតុថាលក្ខខណ្ឌនោះមិនទាន់បានបំពេញ ឬពេលកំណត់នោះមិនទាន់មកដល់ (មាត្រា ៣៥៦ កថាខណ្ឌទី១) នោះបើទោះបីជាម្ចាស់បំណុលនៃការអនុវត្តមិនពេញចិត្តនឹងការចាត់ចែងនេះក៏ដោយ ក៏ម្ចាស់បំណុលនោះមិនត្រូវបានអនុញ្ញាតឱ្យប្រើវិធីពិសេសនៃឧបាស្រ័យណាផ្សេង ក្រៅពីវិធីនៃការដាក់ពាក្យសុំតវ៉ាដែលបានរៀបរាប់ខាងលើដែរ ។ មូលហេតុនៃការកំណត់បែបនេះ ព្រោះថានៅក្នុងករណីបែបនេះម្ចាស់បំណុលនៃការអនុវត្តអាចសម្រេចគោលបំណងរបស់ខ្លួនដោយដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក តាមវិធីធម្មតាដោយធ្វើការអះអាង និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌ ឬការមកដល់នៃពេលកំណត់មិនពិតប្រាកដនោះ ហើយទទួលសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដោយគ្មានលក្ខខណ្ឌបាន ។ ស្រដៀងគ្នានេះដែរ ក្នុងករណីដែលបុគ្គលណាម្នាក់ផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តសុំឱ្យផ្តល់រូបមន្តអនុវត្ត ឬករណីដែលមានការសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះបុគ្គលណាផ្សេងពីភាគីដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត តែស្ថាប័នផ្តល់រូបមន្តអនុវត្តបដិសេធ

[77] មាត្រា ៣៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[78] មាត្រា ៣៦២ កថាខទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

[79] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២

មិនផ្តល់តាមការសុំនោះ ដោយមានមូលហេតុថាពុំមានភាពច្បាស់លាស់ ថាការអនុវត្តដោយបង្ខំអាចធ្វើទៅបាន ដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ហើយពុំមានការបញ្ជាក់ការអះអាងអំពីចំណុចនេះទេ (មាត្រា ៣៥៦ កថាខណ្ឌទី២ និងទី៣) នោះបុគ្គលដែលមានបំណងធ្វើការអនុវត្តដោយបង្ខំដោយតាំងខ្លួនជាម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកតាមវិធីធម្មតា ដោយយកបុគ្គលដែលខ្លួនគិតថាជាកូនបំណុលធ្វើជាចុងចម្លើយ និងដោយអះអាងអំពីហេតុនៃការស្នងឋានៈជាភាគី ដូចជាអនុប្បទានសិទ្ធិទាមទារសន្តតិកម្ម ជាអាទិ៍ រួចទាមទារឱ្យចេញសាលក្រមថ្មីដែលបង្គាប់ឱ្យផ្តល់តាវកាលិក ។ ក្នុងករណីធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានទទួលថ្មីនេះគេគ្រាន់តែចាំបាច់ត្រូវទទួលការផ្តល់រូបមន្តអនុវត្តធម្មតាជាការគ្រប់គ្រាន់ ។[80]

## ៥. ការសង្គ្រោះសម្រាប់កូនបំណុល

### ៥.១. ការដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍

#### ៥.១.១ មូលហេតុនៃការតវ៉ា

ការតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ជាអាទិ៍ ដែលបានរៀបរាប់ខាងលើនេះក៏ត្រូវបានអនុញ្ញាតចំពោះកូនបំណុលនៃការអនុវត្តផងដែរ ដើម្បីធ្វើឧបាស្រ័យទៅនឹងការផ្តល់រូបមន្តអនុវត្តក្នុងករណីដែលស្ថាប័នផ្តល់រូបមន្តអនុវត្តបានផ្តល់រូបមន្តអនុវត្ត ។[81] ប្រសិនបើរូបមន្តអនុវត្តត្រូវបានផ្តល់ឱ្យដើម្បីធ្វើការអនុវត្តចំពោះកូនបំណុលនៃការអនុវត្តណាម្នាក់ កូនបំណុលនោះអាចដាក់ពាក្យសុំតវ៉ាទៅតុលាការដើម្បីសុំការសង្គ្រោះបាន ។ ចំណុចដែលអាចលើកយកមកអះអាងធ្វើជាមូលហេតុនៃការតវ៉ាបាន គឺហេតុដែលធ្វើឱ្យការផ្តល់រូបមន្តអនុវត្តនោះខុសច្បាប់ពោល គឺហេតុនៃការខ្វះក្នុងការស្រាវជ្រាវចំណុចណាមួយដែលស្ថាប័នទទួលបន្ទុកផ្តល់រូបមន្តអនុវត្តត្រូវធ្វើការស្រាវជ្រាវ ។ ក្នុងករណីដែលការផ្តល់រូបមន្តអនុវត្តមានភាពស្របច្បាប់នៅពេលផ្តល់ ប៉ុន្តែ ក្រោយមកក្លាយជាខុសច្បាប់ទៅវិញ ដូចជាករណីដែលសាលក្រម ឬសាលដីកាដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបានបាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹងនៅក្រោយពេលផ្តល់រូបមន្តអនុវត្ត នោះក៏អាចដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្តបានដែរ ។ ផ្ទុយទៅវិញ ទោះបីជាការផ្តល់រូបមន្តអនុវត្តមិនស្របច្បាប់នាពេលផ្តល់ក៏ដោយ តែបើបច្ចុប្បន្នវាបានក្លាយជាស្របច្បាប់វិញ ដូចជាករណីដែលលក្ខខណ្ឌទាមទារនានា ត្រូវបានបំពេញនាពេលក្រោយមក នោះការតវ៉ាអំពីការផ្តល់រូបមន្តអនុវត្តនឹងត្រូវបានលើកចោល ។ ម៉្យាងវិញទៀត ចំណុចសារធាតុដែលពាក់ព័ន្ធនឹងសិទ្ធិទាមទារដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្ត (ឧទាហរណ៍ ការរលត់សិទ្ធិទាមទារដោយសារការសង ជាអាទិ៍) ត្រូវលើកមកអះអាងជាមូលហេតុនៃការតវ៉ានៅក្នុងបណ្តឹងតវ៉ា

[80] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២

[81] មាត្រា ៣៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

ចំពោះការទាមទារ[82] ពោលគឺមិនត្រូវលើកជាមូលហេតុនៃការតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តទេ ។ ទោះបីជាក្នុងករណីដែលរូបមន្តអនុវត្តត្រូវបានផ្ដល់តាមរយៈដីកាសម្រេចរបស់តុលាការ ដោយផ្អែកលើពាក្យសុំតវ៉ារបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះការមិនផ្ដល់រូបមន្តអនុវត្តរបស់ស្ថាប័នផ្ដល់រូបមន្តអនុវត្តក៏ដោយ ក៏កូនបំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តនោះបានដែរ ឱ្យតែមានមូលហេតុដែលនាំឱ្យការផ្ដល់នោះខុសច្បាប់ ។

### ៥.១.២ ពេលនៃការដាក់ពាក្យសុំតវ៉ា

ពាក្យសុំតវ៉ាអាចដាក់បានបន្ទាប់ពីរូបមន្តអនុវត្តត្រូវបានផ្ដល់ ទោះជាពេលនោះការអនុវត្តដោយបង្ខំមិនទាន់ត្រូវបានចាប់ផ្ដើមក៏ដោយ។ ប៉ុន្តែ នៅក្រោយពេលបញ្ចប់ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តដែលពាក់ព័ន្ធ ពេលនោះផលប្រយោជន៍ក្នុងការដាក់ពាក្យសុំតវ៉ាត្រូវរលត់ហើយ ។

### ៥.១.៣ នីតិវិធី

ប្រសិនបើ ក្រឡាបញ្ជីជាអ្នកផ្ដល់រូបមន្តអនុវត្ត តុលាការដែលមានសមត្ថកិច្ចគឺតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ តែប្រសិនបើសារការីជាអ្នកផ្ដល់រូបមន្តអនុវត្តវិញ តុលាការដែលមានសមត្ថកិច្ចពីសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលការិយាល័យរបស់សារការីនោះស្ថិតនៅ ។[83]

តុលាការត្រូវធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្តនោះ ដោយការចេញដីកាសម្រេច ។[84] ចំពោះដីកាសម្រេចលើកចោលពាក្យសុំតវ៉ាដោយពុំមានមូលហេតុត្រឹមត្រូវ កូនបំណុលនៃការអនុវត្តមិនអាចធ្វើឧបាស្រ័យទៀតបានឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលរូបមន្តអនុវត្តពិសេសត្រូវបានផ្ដល់ឲ្យតាមបញ្ញត្តិនៃមាត្រា៣៥៦ នោះកូនបំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តដោយឡែកបាន ។[85] ប្រសិនបើការដាក់ពាក្យបណ្ដឹងតវ៉ានេះត្រូវបានទទួលស្គាល់ថាមានមូលហេតុត្រឹមត្រូវនោះនឹងមានដីកាសម្រេចប្រកាសថាលុបចោលរូបមន្តអនុវត្ត និងថាការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះមិនត្រូវបានអនុញ្ញាតទេ ។ ម្ចាស់បំណុលនៃការអនុវត្តមិនអាចធ្វើឧបាស្រ័យចំពោះដីកាសម្រេចនេះបានទេ ។ កូនបំណុលនៃការអនុវត្តអាចទាមទារឱ្យផ្អាក ឬ លុប

[82] មាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[83] មាត្រា៣៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[84] មាត្រា ៣៦២ កថាខណ្ឌទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[85] មាត្រា ៣៦៤ ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧

ចោលនូវការអនុវត្ត ដោយបង្ខំដោយដាក់ដីកាសម្រេចដែលហាមឃាត់ការអនុវត្តដោយបង្ខំនេះ ជូនទៅស្ថាប័នអនុវត្ត ។[86]

ការចាត់ចែងមួយរយៈចំពោះការអនុវត្តដោយបង្ខំ : ទោះបីជាកូនបំណុលនៃការអនុវត្តដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះមិនត្រូវបានផ្អាកដោយឯកឯងដែរ ។ ហេតុដូចនេះហើយ ដូចជាការពន្យល់ដែលបានរៀបរាប់ពីខាងដើម អំពីករណីដែលមានការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន និងការដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារដែរ ។ នៅក្នុងករណីបែបនេះ ប្រសិនបើយល់ឃើញថាចាំបាច់តុលាការអាចធ្វើការចាត់ចែងមួយរយៈដោយបង្គាប់ឱ្យផ្អាកការអនុវត្តសិន តាមពាក្យសុំរបស់កូនបំណុលដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ រហូតដល់ពេលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ារបស់កូនបំណុលនៃការអនុវត្តនោះ ។[87] នៅក្នុងករណីបែបនេះ តុលាការមិនអាចបង្គាប់ឱ្យលុបចោលការអនុវត្តដោយបង្ខំនៅក្នុងការចាត់ចែងមួយរយៈនោះទេ ។

### ៥.២.បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

គោលគំនិតនៃបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តមាត្រា៣៦៤ គឺជាបណ្តឹងពិសេសដែលអាចធ្វើទៅបាននៅក្នុងករណីដែលមានការផ្តល់រូបមន្តអនុវត្តពិសេសតាមបញ្ញត្តិនៃមាត្រា ៣៥៦ ដើម្បីឱ្យកូនបំណុលនៃការអនុវត្តអាចផាត់ចេញនូវការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ ដោយឈរលើមូលហេតុថា លក្ខខណ្ឌចាំបាច់សម្រាប់ការផ្តល់រូបមន្តអនុវត្តពិសេសនោះមិនត្រូវបានបំពេញ ។ រូបមន្តអនុវត្តពិសេសត្រូវបានផ្តល់ឱ្យ (ក) ក្នុងករណីដែលសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្តភ្ជាប់ជាមួយនឹងលក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬការមកដល់នៃពេលវេលាមិនពិតប្រាកដនោះ ។ (ខ) ក្នុងករណីដែលការអនុវត្តដោយបង្ខំប្រុងនឹងធ្វើឡើង ដោយយកបុគ្គលផ្សេងក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ប្រសិនបើមានភាពច្បាស់លាស់ថា បុគ្គលនោះស្ថិតនៅក្នុងវិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា៣៥១ (ឬ អាចហៅម្យ៉ាងទៀតបានថា បុគ្គលដែលទទួលអានុភាពនៃលិខិតអនុវត្ត) ហើយដោយហេតុនេះមានភាពច្បាស់លាស់ថា ការអនុវត្តដោយបង្ខំអាចធ្វើទៅបានដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ឬប្រសិនបើម្ចាស់បំណុលនៃការអនុវត្តបានធ្វើការបញ្ជាក់អំពីហេតុនោះ ។ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត គឺជាបណ្តឹងដែលកូនបំណុលនៃការអនុវត្តទាមទារឱ្យផាត់ចេញនូវការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិត

[86] មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[87] មាត្រា៣៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

អនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តពិសេស (ក) ដោយលើកវិវាទអំពីការបំពេញលក្ខខណ្ឌ ឬការមកដល់នៃពេលវេលាមិនពិតប្រាកដ (ខ) ដោយផ្អែកលើមូលហេតុថា បុគ្គលដែលត្រូវបានកំណត់នៅក្នុងរូបមន្តអនុវត្ត ថាជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តនោះ មិនមែនជាបុគ្គលដែលស្ថិតនៅក្នុងវិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃមាត្រា ៣៥១ ទេ (ឧទាហរណ៍ បុគ្គលនោះមិនមែនជាអ្នកទទួលបន្តសិទ្ធិ ឬករណីយកិច្ច ដូចមានចែងក្នុងមាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច ត ទេ) ហើយដោយហេតុនេះ ការអនុវត្តដោយបង្ខំដោយផ្អែកលើលិខិតអនុវត្តនោះ មិនអាចធ្វើទៅបានដោយយកបុគ្គលនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តឡើយ ។[88]

[88] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ២

# ជំពូកទី៣
# លំហូរនីតិវិធីនៃការអនុវត្តដោយ
# បង្ខំ

# ជំពូកទី៣
# លំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំ

## ផ្នែកទី១៖ ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងឲ្យជាប្រាក់

លំហូរនៃនីតិវិធីនៃការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ គឺជាការរឹបអូសដើម្បីសម្រេចគោលបំណងឲ្យសងជាប្រាក់ដោយការប្តូរជាប្រាក់ និងចែកចំណែក ។ ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់នេះ ត្រូវធ្វើការអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល រួមមាន ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងការអនុវត្តចំពោះនាវា ។

### កថាខណ្ឌទី១៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

#### ១. ការរឹបអូស

ការរឹបអូស ជាការដកហូតយកវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ការរឹបអូសជាសកម្មភាពនៃការប្រើប្រាស់អំណាចទុកដាក់ទ្រព្យសម្បត្តិជាក់លាក់ណាមួយទៅតាមស្ថានភាពនៃការអនុវត្តដែលមានបំណងដើម្បីធានាទ្រព្យសម្បត្តិនោះ ។ ការរឹបអូសត្រូវគោរពនូវគោលការណ៍ និងនីតិវិធីនៃការរឹបអូស ដើម្បីជៀសវាងនូវការអនុវត្តដោយខុសច្បាប់ ។

##### ១.១. គោលការណ៍សំខាន់ៗនៃការរឹបអូស

##### ១.១.១ វត្ថុដែលអាចរឹបអូសបាន

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត ។[89] ទ្រព្យសម្បត្តិដែលអាចក្លាយជាកម្មវត្ថុនៃការរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ គឺទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលលើកលែងតែទ្រព្យសម្បត្តិមួយចំនួនដែលច្បាប់មានហាមឃាត់ ។

##### ១.១.២ វត្ថុដែលហាមឃាត់មិនឲ្យរឹបអូស

ទោះបីជាការរឹបអូសអាចរឹបអូសបានទាំងរូបទ្រព្យ ឬអរូបទ្រព្យរបស់កូនបំណុលក្តី មានទ្រព្យសម្បត្តិខ្លះទោះបីជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលក៏ដោយ ក៏ត្រូវបានហាមឃាត់មិនឲ្យធ្វើការរឹបអូសផងដែរ ពោលគឺវាស្ថិតនៅក្រោមករណីលើកលែងដែលបានបញ្ញត្តិនៅក្នុងមាត្រា ៣៧៩ នៃក្រមនីតិវិធិរដ្ឋប្បវេណី ។ ក្នុងនៅទ្រព្យសម្បត្តិដែលហាមឃាតមិនឲ្យធ្វើការរឹបអូស រួមមានទាំងចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស និង

[89] មាត្រា ៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

សិទ្ធិលើបំណុលដែលត្រូវបានហាមឃាត់មិនឲ្យរឹបអូស ។ ចំពោះចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូសច្បាប់បានកំណត់នូវទ្រព្យសម្បត្តិដែលហាមឃាត់នោះរួមមានដូចជា[90]៖

- ទ្រព្យសម្បត្តិទ្រទ្រង់ជីវភាពប្រចាំថ្ងៃ ( ចំណុច ក ដល់ចំណុច ឃ)
- ទ្រព្យសម្រាប់បន្តមុខរបរ (ចំណុច ង ដល់ចំណុច ឆ)
- ទ្រព្យសម្រាប់វប្បធម៌ (ចំណុច ជ ដល់ចំណុច ឋ)
- ទ្រព្យសម្រាប់ផ្នែកសង្គម (ចំណុច ឌ ដល់ចំណុច ឍ) ។

ដោយឡែក ចំពោះសិទ្ធិលើបំណុលដែលហាមឃាត់មិនឲ្យរឹបអូសវិញ គឺបានកំណត់ចាប់ពី (ចំណុច ក ដក់ចំណុច ច) កថាខណ្ឌទី១ នៃមាត្រា៣៨២ និងកថាខណ្ឌទី២ ដែលជាសិទ្ធិដែលត្រូវបានហាមឃាត់មិនឲ្យធ្វើការរឹបអូស ។ ការធ្វើបែបនេះក្នុងគោលបំណងដើម្បីសង្គម និងសុខមាលភាព និងដើម្បីធានានូវការចិញ្ចឹមជីវិតរបស់កូនបំណុល ។

### ១.២ ការប្តូរទំហំនៃវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស

ទោះបីជាមានចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស និងសិទ្ធិលើបំណុលដែលហាមឃាត់មិនឲ្យរឹបអូសក៏ដោយ ប៉ុន្តែ អាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់កូនបំណុល ឬម្ចាស់បំណុល ដែលពេលខ្លះចាំបាច់ត្រូវបង្រួម ឬពង្រីកទំហំនៃទ្រព្យសម្បត្តិដែលហាមឃាត់មិនឲ្យរឹបអូសនេះបានដែរ ។[91]

### ១.៣ ការដាក់កម្រិតទៅលើការរឹបអូស

ការរឹបអូសត្រូវបានហាមឃាត់មិនឲ្យធ្វើការរឹបអូសហួសប្រមាណ ឬកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តនោះឡើយ ។ ប្រសិនបើ ដឹងច្បាស់ថា ការរឹបអូសលើសកម្រិតដែលបានកម្រិត ឬហួសប្រមាណក្រោយពេលដែល បានរឹបអូសរួចហើយ នោះអាជ្ញាសាលាត្រូវលុបចោលការរឹបអូសត្រឹមផ្នែកដែលហួសកម្រិតនោះ ។[92]

មួយវិញទៀត អាជ្ញាសាលាមិនត្រូវធ្វើការរឹបអូសឡើយ ប្រសិនបើប៉ាន់ស្មានឃើញថាចំនួនទឹកប្រាក់ដែលបានមកពីលក់ទ្រព្យសម្បត្តិដែលបានរឹបអូសនោះ គ្មានសេសសល់ក្រោយពីបានសងសោហ៊ុយនីតិវិធីរួចហើយ ។[93] លើសពីនេះ អាជ្ញាសាលាអាចលុបចោលការរឹបអូសវត្ថុដែលត្រូវបានរឹបអូស ហើយនោះបានក្នុង

[90] មាត្រា ៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦
[91] មាត្រា ៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦
[92] មាត្រា ៣៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦
[93] មាត្រា ៣៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

លក្ខខណ្ឌដែលបានអនុវត្តការលក់តាមនីតិវិធីសមរម្យក៏ដោយ ក៏នៅតែមិនអាចលក់បាន ហើយប៉ាន់ប្រមាណឃើញថានៅតែមិនអាចលក់បាននៅពេលអនាគត ។[94]

### ២. វិធីនៃការរឹបអូស

#### ២.១ ចំពោះចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត

ចំពោះចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាអាចធ្វើការរឹបអូសបានដោយគ្រាន់តែផ្អែកលើការកាន់កាប់របស់កូនបំណុល ដោយពុំចាំបាច់ស្រាវជ្រាវចលនវត្ថុនោះថាជាកម្មសិទ្ធិរបស់អ្នកណានោះទេ លើកលែងតែមានភស្តុតាងច្បាស់លាស់ថាជារបស់តតិយជន ។ នៅពេលរឹបអូសអាជ្ញាសាលាត្រូវចូលទៅកាន់ទីកន្លែងរបស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយអាចធ្វើការឆែកឆេររកចលនវត្ថុដែលអាចធ្វើការរឹបអូសបាន ។ ក្នុងករណីចាំបាច់ ឬមានឧបសគ្គ អាជ្ញាសាលាអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទ ទូដែក និងប្រអប់ផ្សេងទៀតដែលបិទជិតបាន ។ អំឡុងពេលធ្វើការជ្រើសរើសចលនវត្ថុដែលត្រូវរឹបអូសអាជ្ញាសាលាត្រូវគិតពិចារណាដល់ប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្ត ។ មួយវិញទៀត ការរឹបអូសត្រូវធ្វើឡើងតាមរយៈការកាន់កាប់វត្ថុដែលរឹបអូសនោះដោយអាជ្ញាសាលាដែលជាអ្នកទទួលខុសត្រូវកាន់កាប់នេះ ឬក្នុងករណីយល់ឃើញថា សមរម្យអាជ្ញាសាលាអាចឲ្យកូនបំណុលនៃការអនុវត្តថែរក្សា និងគ្រប់គ្រងវត្ថុដែលរឹបអូសនោះ ។ ករណីនេះ ត្រូវមានផ្លាកបញ្ជាក់ឲ្យដឹងពីចលនវត្ថុដែលត្រូវបានរឹបអូសដោយការបិទស្លាក ឬដាក់សញ្ញារឹបអូសដោយវិធីផ្សេងដោយការបិទភ្ជាប់លើចលនវត្ថុនោះជាដើម ។[95]

#### ២.២ ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយម្ចាស់បំណុលនៃការអនុវត្ត

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត ជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុលដោយខ្លួនឯងនោះ ម្ចាស់នៃការអនុវត្តគ្រាន់តែប្រគល់ចលនវត្ថុដែលខ្លួនកាន់កាប់នោះដោយស្ម័គ្រចិត្តទៅឲ្យអាជ្ញាសាលា ដើម្បីធ្វើការរឹបអូស ។[96] ហើយការរឹបអូសនេះអនុវត្តដូចគ្នានឹងចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តដូចបានរៀបរាប់ខាងលើនេះផងដែរ ។

#### ២.៣ ការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយតតិយជន

ក្នុងករណីដែលចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសកាន់កាប់ដោយតតិយជន ការរឹបអូសអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមប្រគល់ឲ្យទើបអាជ្ញាសាលាអាចធ្វើការរឹបអូសបាន ។ ក្នុងករណីដែលតតិយ

[94] មាត្រា ៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦
[95] មាត្រា ៣៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦
[96] មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

ជននោះមិនយល់ព្រមប្រគល់ចលនវត្ថុនោះដើម្បីធ្វើការរឹបអូសទេ គឺមានតែយកសិទ្ធិទាមទារឲ្យប្រគល់ចលនវត្ថុដែលកូនបំណុលនោះមានមកប្រើក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិលើបំណុលដើម្បីធ្វើការរឹបអូសយកវត្ថុនោះ ។[97]

**៣. ការប្តូរជាប្រាក់**

ក្រោយពីការរឹបអូស អាជ្ញាសាលាត្រូវលក់វត្ថុដែលរឹបអូសបាននោះតាមនីតិវិធីលក់ឡាយឡុង គឺលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ ។[98]

ការលក់ឡាយឡុងដោយផ្ទាល់មាត់ ត្រូវធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ត្រូវទិញ ហើយអាជ្ញាសាលានឹងប្រកាសអំពីការអនុញ្ញាតឲ្យទិញចំពោះអ្នកស្នើដែលហ៊ានឲ្យថ្លៃខ្ពស់ជាងគេ ។ ចំណែកឯការលក់ដោយស្រោមសំបុត្រវិញ គឺធ្វើឡើងតាមនីតិវិធីដែលអ្នកសុំទិញដាក់ពាក្យសុំទិញជាលាយលក្ខណ៍អក្សរ បន្ទាប់មកអាជ្ញាសាលានឹងបើកស្រោមសំបុត្រភ្លាមក្រោយពីបិទការដេញថ្លៃ រួចប្រកាសឈ្មោះ និងថ្លៃដេញរបស់អ្នកដែលហ៊ានឲ្យថ្លៃខ្ពស់ជាងគេ ព្រមទាំងការអនុញ្ញាតឲ្យបុគ្គលនោះទិញ ។

**៤. ការចែកចំណែក**

ពេលដែលអាជ្ញាសាលាបានធ្វើការប្តូរជាប្រាក់នូវចលនវត្ថុដែលបានរឹបអូសរួចហើយ អាជ្ញាសាលាត្រូវធ្វើការចែកចំណែកទៅឲ្យម្ចាស់បំណុល ។ ហើយម្ចាស់បំណុលដែលត្រូវទទួលចំណែកគឺ ម្ចាស់បំណុលនៃ ការអនុវត្ត ម្ចាស់បំណុលដែលបានការទាមទារឲ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្តី និងម្ចាស់បំណុល ដែលបានធ្វើការទាមទារឲ្យចែកចំណែក ។[99]

**៤.១ ការចែកចំណែកដោយអាជ្ញាសាលា**

អាជ្ញាសាលាត្រូវយកប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលបានមកពីការរឹបអូសសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់ ដោយអាជ្ញាសាលាត្រូវធ្វើការចែកចំណែកទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ។ ក្រោយពេលប្រគល់រួចហើយ បើនូវមានប្រាក់សេសសល់ត្រូវប្រគល់ទៅឲ្យកូនបំណុលនៃការអនុវត្តវិញ ដោយមិនចាំបាច់កំណត់កាលបរិច្ឆេទនៃការចែកចំណែកឡើយ ។[100] ប៉ុន្តែប្រសិនបើ ប្រាក់ដែលបានមកពីការលក់ ឬរឹបអូសបាននោះ ពុំគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលរបស់កូនបំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទេនោះ អាជ្ញាសាលាត្រូវធ្វើការកំណត់កាលបរិច្ឆេទក្នុងអំឡុងពេល២សប្តាហ៍ ដើម្បីធ្វើការពិភាក្សាគ្នាអំពីការចែកចំណែកនៃប្រាក់ដែលបានមកដោយជូនដំណឹងអំពីពេល

---

[97] មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[98] មាត្រា ៣៩៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[99] មាត្រា ៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[100] មាត្រា ៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

វេលា និងទីកន្លែងទៅកាន់ម្ចាស់បំណុលនីមួយៗ ហើយប្រសិនបើម្ចាស់បំណុលនីមួយៗនោះបានពិភាក្សាគ្នាដាច់ស្រេចហើយ នោះអាជ្ញាសាលាត្រូវធ្វើការចែកចំណែកផ្អែកតាមការពិភាក្សានោះ ។[101] ដោយឡែក ប្រសិនបើការពិភាក្សានោះមិនដាច់ស្រេច អាជ្ញាសាលាត្រូវជូនដំណឹងអំពីហេតុការណ៍នេះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ។[102]

### ៤.២ ការចែកចំណែកដោយតុលាការ

ក្រោយពីអាជ្ញាសាលា ជូនដំណឹងអំពីហេតុការណ៍អំពីការពិភាក្សារបស់ម្ចាស់បំណុលនីមួយៗនោះដែលពុំបានដាច់ស្រេចនោះ តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការចែកចំណែក រួចធ្វើការចែកចំណែកទៅឲ្យម្ចាស់បំណុលនីមួយៗនោះ ។

## កថាខណ្ឌទី២៖ ការអនុវត្តចំពោះអចលនវត្ថុ

### ១. វិធីនៃការអនុវត្ត

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជានីតិវិធីមួយដែលមានលក្ខណៈស្មុគស្មាញជាងគេ ដោយហេតុថា ក្នុងនោះអចលនវត្ថុដែលត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូស រួមមាន ដី អគារដែលត្រូវបានចុះបញ្ជី និងចំណែកនៃកម្មសិទ្ធិអវិភាគ ឬអគារនោះ និងសិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកសិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលជាសិទ្ធិរួម ។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុត្រូវធ្វើឡើងតាមនីតិវិធីលក់ដោយបង្ខំតាមផ្លូវតុលាការដោយដីកាសម្រេចចាប់ផ្តើម ។

### ១.១ អចលនវត្ថុដែលត្រូវបានចុះបញ្ជី

នៅពេលដែលធ្វើការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី គឺត្រូវភ្ជាប់ជាមួយនឹងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី ។ ប្រសិនបើ ករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្តត្រូវបានចុះបញ្ជីក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថាអចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។[103]

### ១.២ អចលនវត្ថុដែលពុំបានចុះបញ្ជី

ការអនុវត្តចំពោះដីដែលពុំបានចុះបញ្ជី គឺត្រូវភ្ជាប់ជាមួយនឹងឯកសារដែលបញ្ជាក់ថាដីនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។[104]

---

[101] មាត្រា ៣៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[102] មាត្រា ៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[103] មាត្រា ៤១៧ កថាខណ្ឌទី៣ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[104] មាត្រា ៤១៧ កថាខណ្ឌទី៣ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

## ២. ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ

### ២.១ ដីកាសម្រេចចាប់ផ្ដើម

នៅពេលចាប់ផ្ដើមនីតិវិធីលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុនោះក្នុងដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយត្រូវធ្វើការបញ្ជូនដីកាសម្រេចនោះទៅកាន់កូនបំណុលនៃការអនុវត្ត ។[105]ក្រោយពីពេលដែលដីកាសម្រេចត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាច់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេច ។ ក្នុងករណីនេះ ស្ថាប័នដែលមានសមត្ថកិច្ចត្រូវផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះទៅក្រឡាបញ្ជី ។ ប្រសិនបើជា ដី ដែលពុំត្រូវបានចុះបញ្ជីត្រូវបានចាប់ផ្ដើមលក់ដោយបង្ខំ ស្ថាប័នដែលមាសមត្ថកិច្ចជាដំបូងគឺត្រូវចុះបញ្ជីនូវអត្តសញ្ញាណដីនោះ និងចុះបញ្ជីរក្សាទុកកម្មសិទ្ធិដីនោះ ហើយត្រូវចុះបញ្ជីអំពីការរឹបអូស ។[106]

### ២.២. អានុភាពនៃការរឹបអូស

ជាគោលការណ៍ អានុភាពនៃការរឹបអូសកើតឡើងនៅពេលដែលដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត ។ ប៉ុន្តែប្រសិនបើ ការចុះបញ្ជីអំពីការរឹបអូសនោះត្រូវបានធ្វើឡើងនៅមុនពេលបញ្ជូនដីការសម្រេចចាប់ផ្ដើម នោះនាំឲ្យអានុភាពកើតឡើងនៅពេលក្រោយ គឺនៅពេលដែលបានចុះបញ្ជី ។ លើសពីនោះ វាមានអានុភាពទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងផ្នែកមួយចំនួននៃអចលនវត្ថុ ព្រមទាំងវត្ថុចំណុះ និងសិទ្ធិចំណុះនៃអចលនវត្ថុនោះផងដែរ ។ ហើយការរឹបអូសពុំមានអានុភាពរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬអាស្រ័យផលពីអចលនវត្ថុនោះ តាមវិធីប្រើធម្មតានោះទេ តែវាមានអានុភាពមិនឲ្យធ្វើការចាត់ចែងលើអចលនវត្ថុនោះ ។[107]

### ២.៣ ដីការសម្រេចចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក

ក្រោយពេលដែលការរឹបអូសបង្កើតអានុភាព តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ដោយគិតពិចារណានូវរំឡុងពេលចាំបាច់សម្រាប់ផ្ញើឯកសារលំអិតអំពីវត្ថុ លើកលែងតែក្នុងករណីដែលដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំចេញត្រួតគ្នា ។ បន្ថែមពីនេះ តុលាការអនុវត្តត្រូវធ្វើការដាស់តឿនឲ្យម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូស ជាបណ្ដោះអាសន្ននៅមុនការចុះបញ្ជីអំពីការរឹបអូស ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជីនៅមុនការចុះបញ្ជីអំពីការរឹបអូស ហើយស្ថាប័ន

[105] មាត្រា ៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦
[106] មាត្រា ៤២០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦
[107] មាត្រា ៤២១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

ដែលមានសមត្ថកិច្ចលើពន្ធដារ ឬអាករសាធារណៈផ្សេង រាយការណ៍ទៅតុលាការអំពីសិទ្ធិរបស់ខ្លួនដែលមានឲ្យបានមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ដើម្បីឲ្យពួកគេទទួលបានប្រាក់ចំណែកដែល បានមកពីការលក់អចលនវត្ថុនោះ ។[108] នៅក្នុងការកំណត់ពេលចុងក្រោយនេះអាចត្រូវបានផ្លាស់ប្តូរ ប្រសិនបើ តុលាការអនុវត្តមិនបានចេញដីកាសម្រេចឲ្យលក់ក្នុងអំឡុងពេល ៣ ខែ គិតចាប់ពីពេលនៃការកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ហើយតុលាការត្រូវធ្វើការប្រកាសជាសាធារណៈអំពីការផ្លាស់ប្តូរនេះ ។[109]

### ៣. នីតិវិធីនៃការលក់

#### ៣.១ លក្ខខណ្ឌនៃការលក់

##### ៣.១.១ ការវាយតម្លៃ

តុលាការអនុវត្តត្រូវធ្វើការជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃអចលនវត្ថុនោះផ្អែកតាមការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ និងទំនាក់ទំនងនៃការកាន់កាប់ ព្រមទាំងស្ថានភាពនាពេលបច្ចុប្បន្ន ។ នៅពេលដែលធ្វើការស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់ទីតាំងនៃអចលនវត្ថុ ឬអាចសាកសួរ និងទាមទារឲ្យបង្ហាញឯកសារពីកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន ហើយក្រោយពីការវាយតម្លៃរួច អ្នកវាយតម្លៃត្រូវដាក់ជូននូវលទ្ធផលនៃការស្រាវជ្រាវអំពីបច្ចុប្បន្នភាពនៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះ ជាលាយលក្ខណ៍អក្សរទៅតុលាការនៃការអនុវត្ត ។[110]

##### ៣.១.២ ដីកាសម្រេចកំណត់តម្លៃលក់

បន្ទាប់ពីការរឹបអូស តុលាការអនុវត្តនឹងធ្វើការលក់អចលនវត្ថុដែលរឹបអូសបាននោះ ហើយមុនពេលលក់ ជាគោលការណ៍ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ។[111] ប៉ុន្តែ ប្រសិនបើយល់ឃើញថា តម្លៃលក់អប្បបរមានៃអចលនវត្ថុក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីរួចហើយគ្មានលទ្ធភាពសេសសល់ទេនោះ តុលាការអនុវត្តត្រូវជូនដំណឹងនេះទៅម្ចាស់បំណុលនៃការអនុវត្ត ។ ប៉ុន្តែប្រសិនបើ ម្ចាស់បំណុលនៃការអនុវត្តបានស្នើសុំទិញដោយខ្លួនឯងក្នុងតម្លៃដែលលើសពីការប៉ាន់ប្រមាណដោយដាក់ប្រាក់ធានាដែលមានតម្លៃស្មើនឹងការស្នើសុំ ក្នុងអំឡុងពេលមួយសប្តាហ៍គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលទទួលបានដំណឹង នោះនីតិវិធីលក់ដោយបង្ខំនៅតែអនុវត្តបន្តដដែល ។[112]

---

108 មាត្រា ៤២២ កថាខណ្ឌទី១ ,ទី២, និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

109 មាត្រា ៤២២ កថាខណ្ឌទី៤ និងទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

110 មាត្រា ៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

111 មាត្រា ៤៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

112 មាត្រា ៤៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ក្រោយពីការកំណត់តម្លៃលក់អប្បបរមារួចហើយ តុលាការអនុវត្តត្រូវរៀបចំឯកសារលំអិតអំពីវត្ថុ ដើម្បីជូន ដំណឹងដល់អ្នកស្នើសុំទិញ អំពីស្ថានភាពនៃវត្ថុ ហើយប្រសិនបើយល់ឃើញថាចាំបាច់ដើម្បីធ្វើឯកសារលំអិត នេះ តុលាការអនុវត្តអាចបង្គាប់ឲ្យអាជ្ញាសាលា ស្រាវជ្រាវស្ថានភាពបច្ចុប្បន្នអំពីវត្ថុ ។[113]

### ៣.២ វិធីលក់

តុលាការត្រូវកំណត់ដោយឆន្ទានុសិទ្ធិអំពីវិធីនៃការលក់ ដែលធ្វើឡើងដោយការលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយស្រោមសំបុត្រ ហើយត្រូវធ្វើការកំណត់កាលបរិច្ឆេទ និងទីកន្លែងនៃការលក់ បន្ទាប់មកតុលាការអនុវត្តត្រូវប្រគល់ឲ្យអាជ្ញាសាលាជាអ្នកអនុវត្តការលក់នោះ ។[114] ដោយឡែកជនដែលបម្រុងនឹងស្នើ សុំទិញ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹង ១០%នសតម្លៃលក់អប្បរមា ឬចំនួនលើសពីនេះ ហើយ អ្នកស្នើសុំទិញត្រូវបានចងដោយពាក្យស្នើសុំទិញនោះ រហូតដល់ពេលដែលមានពាក្យស្នើសុំទិញថ្មីដែលមាន តម្លៃខ្ពស់ជាងមុន ។ ហើយប្រសិនបើ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាត្រូវបានកំណត់ នោះការលក់ ត្រូវបានបិទបញ្ចប់ ហើយតុលាការអនុវត្តត្រូវសងភ្លាមនូវប្រាក់ធានាដែលអ្នកស្នើសុំដទៃទៀតបានដាក់ ។[115]

បន្ទាប់ពីបញ្ចប់ការបរិច្ឆេទនៃការលក់ តុលាការអនុវត្តត្រូវសម្រេចអនុញ្ញាតឲ្យលក់ ឬមិនឲ្យលក់ទៅឲ្យអ្នកស្នើសុំក្នុងតម្លៃអតិបរមា ដែលបានកំណត់ដោយអាជ្ញាសាលានៅក្នុងកាលបរិច្ឆេទនៃការលក់ដោយបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេច ហើយត្រូវធ្វើការជូនដំណឹងអំពីដីកាសម្រេចនោះទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ និងស្តាប់សេចក្តីថ្លែងការណ៍របស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍នោះ ។[116]

### ៣.៣ ដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់

#### ៣.៣.១ ដីកាសម្រេចមិនអនុញ្ញាតឲ្យលក់

តុលាការត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់ដោយឆន្ទានុសិទ្ធិ ឬតាមការថ្លែងការណ៍របស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬដោយយល់ឃើញថាមានមូលហេតុដូចខាងក្រោម៖

**- នីតិវិធីនៃការលក់ដោយបង្ខំមិនត្រូវបានចាប់ផ្តើម ឬបន្ត** : មានន័យថា ក្នុងករណីដែលនីតិវិធីមិនគួរចាប់ផ្តើមតាំងពីដំបូង ដោយមូលហេតុនៃការខ្វះលក្ខខណ្ឌទាមទារសម្រាប់ការចាប់ផ្តើមការលក់ដោយបង្ខំ ករណីដែលមានមូលហេតុនៃការផ្អាក ឬលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬមូលហេតុនៃការផ្អាកមួយរយៈ ឬមានការដកពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ។ លើសពីនេះ ឲ្យតែមានឯកសារចម្លងយថាភូតនៃ

---

[113] មាត្រា ៤៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[114] មាត្រា ៤៣៦ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[115] មាត្រា ៤៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[116] មាត្រា ៤៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

លិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តដែលមានបញ្ជាក់អំពីនត្ថិភាព ឬការរលត់សិទ្ធិទាមទារហើយត្រូវអះអាងក្នុងបណ្តឹងតវ៉ាចំពោះការទាមទារជាការសម្រេច ។

- **អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាពុំមានលក្ខណសម្បត្តិ ឬសមត្ថភាពដើម្បីទិញអចលនវត្ថុ ឬអ្នកតំណាងរបស់អ្នកស្នើសុំពុំមានសិទ្ធិនោះ:** គឺក្នុងករណីដែលអ្នកស្នើសុំទិញតម្លៃអតិបរមានោះ គឺជាកូនបំណុលនៃការអនុវត្ត ឬបុគ្គលដែលធ្លាប់បានក្លាយជាអ្នកទិញ ប៉ុន្តែមិនបានបង់ថ្លៃទិញជាដើម ឬអ្នកស្នើរសុំទិញនោះគឺជាបុគ្គលដែលពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាព ឬត្រូវបានដាក់ដោយអ្នកដែលគ្មានសិទ្ធិតំណាង ។

- **មានសេចក្តីស្នើរសុំកុំឲ្យអនុញ្ញាតការលក់ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា៤៤៥:** ក្នុងករណីដែលអចលនវត្ថុទទួលរងនូវការខូចខាតធ្ងន់ធ្ងរនៅក្រោយពេលធ្វើសំណើរទិញ ដោយសារគ្រោះធម្មជាតិ ឬដោយមូលហេតុផ្សេងទៀតដែលមិនមែនជាបន្ទុករបស់ខ្លួន ។

- **មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា:** ដូចជា ករណីដែលតម្លៃលក់អប្បបរមាត្រូវបានកំណត់ដោយមិនបានផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ ឬករណីដែលអ្នកវាយតម្លៃបានធ្វើការវាយតម្លៃដោយផ្អែកលើការយល់ច្រឡំអំពីលក្ខខណ្ឌនៃការលក់ដែលទាក់ទងទៅនឹងការរលត់ ឬការបន្តអត្ថិភាពនៃបន្ទុកលើអចលនវត្ថុ ហើយតម្លៃលក់អប្បបរមានោះត្រូវបានកំណត់ដោយផ្អែកលើការវាយតម្លៃដោយយល់ច្រឡំនោះ ។

- **មានកំហុសធ្ងន់ធ្ងរនៅក្នុងនីតិវិធីនៃការលក់:** ចំណុចនេះក៏ជាមូលហេតុនៃការមិនអនុញ្ញាតឲ្យលក់ដែរ ដូចជា កំហុសទាក់ទងនឹងកាលបរិច្ឆេទនៃការលក់ កំហុសទាក់ទងនឹងការកំណត់ទីកន្លែង កំហុសទាក់ទងនឹងការផ្សាយជាសាធារណៈ និងកំហុសនៅក្នុងការកំណត់អ្នកស្នើរសុំទិញក្នុងតម្លៃអតិបរមា ។[117]

### ៣.៣.២ ដីកាសម្រេចអនុញ្ញាតឲ្យលក់

ប្រសិនបើ ពុំមានមូលហេតុនៃការមិនអនុញ្ញាតឲ្យលក់ដូចដែលបានរៀបរាប់ខាងលើនេះទេ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់ ។[118] ដីកាសម្រេចអនុញ្ញាឲ្យលក់ត្រូវជូនដំណឹងដោយប្រកាសនូវកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឲ្យលក់[119] ហើយដីកាសម្រេចអនុញ្ញាតឲ្យលក់នោះនឹងពុំមបង្កើតអានុភាពឡើយ ប្រសិនបើពុំទាន់ចូលជាស្ថាពរ ។[120]

[117] មាត្រា ៤៤២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[118] មាត្រា ៤៤២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[119] មាត្រា ៤៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[120] មាត្រា ៤៤៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

## ៤. អានុភាពនៃការលក់

### ៤.១ បង្កើតទំនាក់ទំនងនៃការលក់

នៅពេលដែលដីកាសម្រេចអនុញ្ញាតឲ្យលក់ ត្រូវបានចូលជាស្ថាពរហើយនោះអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានឹងក្លាយជាអ្នកទិញ នាំឲ្យទំនាក់ទំនងគតិយុត្តកើតមានឡើងរវាងអ្នកទិញ និងកូនបំណុលនៃការអនុវត្ត ដូចគ្នានឹងការទិញលក់ធម្មតាដែរ ។

### ៤.២ ការបង់ថ្លៃលក់

នៅពេលដែលទំនាក់ទំនងខាងលើនេះត្រូវបានបង្កើតឡើង នោះអ្នកទិញមានករណីយកិច្ចត្រូវបង់ថ្លៃទៅឲ្យតុលាការអនុវត្តតាមពេលកំណត់របស់តុលាការអនុវត្ត ។ ពេលកំណត់នេះគឺមានស្ថិតនៅក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឲ្យលក់ចូលជាស្ថាពរ ។ ថ្លៃដែលត្រូវបង់គឺសាច់ប្រាក់សុទ្ធទាំងអស់ ហើយចំនួនទឹកប្រាក់ដែលត្រូវបានដាក់ធានាត្រូវគិតបញ្ចូលទៅក្នុងថ្លៃទិញ ។ ប្រសិនបើម្ចាស់ បំណុលនៃការអនុវត្តជាអ្នកទិញវិញ អ្នកទិញនោះត្រូវដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលបានពីការចែកចំណែកនៅមុនកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចលក់ ។[121]ផ្ទុយទៅវិញ ប្រសិនបើអ្នកទិញមិនបង់ថ្ងៃលក់ទៅតាមពេលកំណត់ទេ នោះនាំឲ្យដីកាសម្រេចឲ្យលក់បាត់បង់អានុភាព ហើយអ្នកទិញមិនអាចទាមទារឲ្យសងប្រាក់ដែលខ្លួនបានដាក់ធានាបាននោះទេ ។ ករណីនេះ តុលាការអនុវត្តត្រូវលក់ដោយបង្ខំសារជាថ្មី ហើយអ្នកទិញមុនដែលមិនព្រមបង់ថ្លៃលក់មិនអាចស្នើសុំទិញម្តងទៀតបាននោះទេ ។[122]

### ៤.៣ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ

កម្មសិទ្ធិលើអចលនវត្ថុត្រូវផ្ទេរពីកូនបំណុលនៃការអនុវត្តទៅឲ្យអ្នកទិញ នៅពេលដែលអ្នកទិញបានបង់ថ្លៃលក់ ។[123] នៅពេលនោះ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្តទៅឲ្យអ្នកទិញ ។[124] នៅពេលដែលអ្នកទិញបានបង់ថ្លៃលក់ និងបានធ្វើលទ្ធកម្មរួចហើយ អ្នកទិញនោះអាចធ្វើការទាមទារឲ្យប្រគល់អចលនវត្ថុចំពោះកូនបំណុលនៃការអនុវត្ត ឬចំពោះអ្នកកាន់កាប់ដែលពុំមានសិទ្ធិចំពោះអ្នកទិញតាមច្បាប់សារធាតុបាន ដូច្នេះអ្នកទិញអាចដាក់ពាក្យសុំឲ្យតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលនវត្ថុនោះឲ្យប្រគល់អចលនវត្ថុនោះឲ្យខ្លួន ។[125]

---

[121] មាត្រា ៤៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[122] មាត្រា ៤៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[123] មាត្រា ៤៤៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[124] មាត្រា ៤៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[125] មាត្រា ៤៥០ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

**៤.៤ ការទទួលខុសត្រូវរបស់អ្នកទិញ**

ចំពោះសិទ្ធិប្រាតិភោគដែលនឹងមានអត្ថិភាពក្រោយការលក់ ករណីដែលកូនបំណុលនៃការអនុវត្តជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគទាំងនោះ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការសងនូវសិទ្ធិលើបំណុលនោះ ។ មួយវិញទៀត ប្រសិនបើសិទ្ធិប្រាតិភោគនោះជាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអ្នកទិញត្រូវខុសត្រូវក្នុងកម្រិតអតិបរមា ។[126]

**៤.៥ វិសាលភាពនៃម្ចាស់បំណុលដែលទទួលចំណែក**

ក្រោយពេលលក់អចលនវត្ថុបានរួចរាល់ហើយ ប្រាក់ដែលបានមកនោះគឺត្រូវចែកចំណែកទៅឲ្យម្ចាស់បំណុល ។ ហើយម្ចាស់បំណុលដែលត្រូវបានទទួលចំណែកថ្លៃលក់នោះ ជាអ្នកដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដូចជា ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅ រហូតដល់កំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចំណែក មួយទៀតគឺម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែករហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ហើយជាពិសេសនោះគឺម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន មុនការចុះបញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូង ។[127]

**កថាខណ្ឌទី៣៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល**

**១. អត្ថន័យ**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់របស់ម្ចាស់បំណុលនៃការអនុវត្ត ដោយការរឹបអូសសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ ឬជាការប្រគល់ចលនវត្ថុដែលជារបស់កូនបំណុល ហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ ។[128]លើសពីនេះទៅទៀត ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតក្រៅពីនាវា ចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើបំណុលត្រូវអនុវត្តតាមនីតិវិធីអនុវត្តចំពោះសិទ្ធិលើបំណុលនេះដែរ ។[129]

**២. ការរឹបអូសសិទ្ធិលើបំណុល**

**២.១ ដីកាសម្រេចរឹបអូស**

ការអនុវត្តត្រូវចាប់ផ្តើមឡើងដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត តាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ហើយដីកាសម្រេចនេះត្រូវបានចេញដោយពុំចាំបាច់សួរកូនបំណុល ឬកូនបំណុល

[126] មាត្រា ៤៤៩នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[127] មាត្រា ៤៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[128] មាត្រា ៤០២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

[129] មាត្រា ៤១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ,ឆ្នាំ ២០០៦

ទី៣ នោះទេ ។[130] ហើយនៅពេលដែលដីកាសម្រេចត្រូវបានបញ្ជូន តុលាការអនុវត្តត្រូវដាស់តឿនឲ្យកូនបំណុលទី៣ ធ្វើសេចក្ដីថ្លែងការក្នុងអំឡុងពេល ២ សប្ដាហ៍អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសប្រភេទចំនួនទឹកប្រាក់ និងខ្លឹមសារនៃសិទ្ធិលើបំណុល ។ បើមានឆន្ទៈនឹងសង ទំហំនៃការសង ឬមូលហេតុដែលមិនសង ព្រមទាំងសញ្ញាណនៃជនដែលមានអាទិភាពជាម្ចាស់បំណុលនៃការអនុវត្តចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ និងប្រភេទនៃសិទ្ធិរបស់ជននោះ និងទំហំនៃអាទិភាពបើមាន និងអត្ថិភាព ឬនត្ថិភាពនៃការរឹបអូស ឬការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធជាមួយនឹងម្ចាស់បំណុលផ្សេងទៀត ។ ក្នុងករណីដែលកូនបំណុលទី៣ មិនធ្វើសេចក្ដីថ្លែងការណ៍តាមការដាស់តឿនដោយមានចេតនា ឬដោយសារកំហុសរបស់ខ្លួន ឬធ្វើសេចក្ដីថ្លែងការណ៍ខុសពីការពិត នោះកូនបំណុលទី៣ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដែលបានកើតឡើងនោះ ។[131]

### ២.២ ការរឹបអូស

នៅពេលអនុវត្ត តុលាការអាចរឹបអូសយកសិទ្ធិទាំងអស់របស់កូនបំណុលនៃការអនុវត្តបាន ទោះបីជាសិទ្ធិលើបំណុលដែលបានរឹបអូសនោះ មានតម្លៃលើសពីចំនួនទឹកប្រាក់នៅក្នុងលិខិតអនុវត្តក៏ដោយ ។ ប៉ុន្តែតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូសមានចំនួនលើសតម្លៃក្នុងលិខិតអនុវត្ត នោះតុលាការអនុវត្តមិនត្រូវធ្វើការរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតនោះឡើយ ។[132]

មួយវិញទៀត ចំពោះការរឹបអូសសិទ្ធិលើបំណុលដែលទាក់ទងនឹងប្រាក់បៀវត្ស ឬតាវកាលិកផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តទទួលបន្តបន្ទាប់ដូចជាថ្លៃឈ្នួលដី ថ្លៃឈ្នួលប្រើប្រាស់ ឬការប្រាក់ជាដើម ដែលទៀងទាត់ បើទទួលបានដីកាសម្រេចរឹបអូសម្ដងរួចហើយនោះពុំចាំបាច់ទទួលដីកាសម្រេចរឹបអូសរាល់ពេលកំណត់សងនោះទេ ។[133] លើសពីនេះម្ចាស់បំណុលដែលបានរឹបអូសនូវសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់អាចប្រមូលបំណុលនោះបាន ប្រសើនបើ ១សប្ដាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត ។ ម្យ៉ាងវិញទៀត ប្រសិនបើមានម្ចាស់បំណុលនៃការអនុវត្តផ្សេងទៀត ឬមានម្ចាស់បំណុលដែលទាមទារឲ្យចែកចំណែកផ្សេងទៀត កូនបំណុលទី៣ ត្រូវផ្ញើទុកប្រាក់នៅតុលាការអនុវត្ត ។[134]

---

130 មាត្រា ៤០៣ កថាខណ្ឌទី៤ និងទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

131 មាត្រា ៤០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

132 មាត្រា ៤០៤ កថាខណ្ឌទី១ និងទី២នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

133 មាត្រា ៤០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

134 មាត្រា ៤១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

### ២.៣ អានុភាពនៃការរឹបអូស

ការរឹបអូសសិទ្ធិលើបំណុល ត្រូវបង្កើតអានុភាពនៅពេលដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកាន់កូនបំណុលទី៣ ។ ហើយនៅពេលដែលដីកាសម្រេចរឹបអូសបង្កើតអានុភាព កូនបំណុលនៃការអនុវត្តមិនអាចធ្វើការប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូសនោះទេ ឬទទួលការសង ឬមិនអាចធ្វើការចាត់ចែងផ្សេងទៀតបាននោះទេ និងហាមឃាត់កូនបំណុលទី៣មិនឲ្យសងសិទ្ធិលើបំណុលទៅឲ្យកូនបំណុលនៃការអនុវត្តដូចគ្នាផងដែរ ។[135]

## ៣. ការប្តូរជាប្រាក់នូវសិទ្ធិលើបំណុលដែលបានរឹបអូស

ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសមានលក្ខខណ្ឌ ឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវកាលិក ឬមានមូលហេតុផ្សេងទៀត តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឲ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ ដោយវិធីដែលកំណត់ដោយតុលាការអនុវត្ត ហើយយកប្រាក់ដែលបានមកពីការលក់នោះទៅឲ្យតុលាការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ ដីកាសម្រេចនេះ ហៅថា **ដីកាសម្រេចបង្គាប់ឲ្យលក់** ហើយនីតិវិធីនៃការចេញដីកាបង្គាប់ឲ្យលក់នេះគឺត្រូវអនុលោមតាមការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដូចគ្នាផងដែរ ប៉ុន្តែត្រូវបានហាមឃាត់នូវការអនុវត្ត និងមានវិធានពិសេសមួយចំនួន ដូចជាលក្ខខណ្ឌតតាំងអនុប្បទាន ការផ្ទុកផ្ដាក់ចុះបញ្ជី សិទ្ធិប្រាតិភោគដែលធានា សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ជាអាទិ៍។[136]

## ៤.ការចែកចំណែក

នៅពេលដែលចែកចំណែក ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និងម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារដែលខ្លួនមានឯកសិទ្ធិអាចទាមទារឲ្យចែកចំណែកបាន ។ ហើយនៅពេលដែលមានការទាមទារឲ្យចែកចំណែកតុលាការអនុវត្តត្រូវបញ្ជូនឯកសារដែលបញ្ជាក់អំពីសេចក្តីទាមទារនោះទៅកូនបំណុលទី៣ ។[137] មួយវិញទៀង ម្ចាស់បំណុលដែលត្រូវទទួលចំណែកគឺជាម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ឬទាមទារឲ្យចែកចំណែកមុនពេលដែលកំណត់ ដូចជាពេលដែលកូនបំណុលទី៣បានធ្វើការធ្វើប្រាក់ទុកនៅតុលាការ ឬពេលដែលពាក្យបណ្ដឹងទាមទារប្រមូលបំណុលត្រូវបញ្ជូនទៅកូនបំណុលទី៣ ឬពេលដែលអាជ្ញាសាលាបានទទួលប្រាក់ពីការលក់តាម

[135] មាត្រា ៤០៣ កថាខណ្ឌទី៥ និងទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[136] មាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[137] មាត្រា ៤០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

ដីកាសម្រេចបង្គាប់ឲ្យលក់ ឬពេលដែលអាជ្ញាសាលាទទួលបានការប្រគល់ចលនវត្ថុក្នុងករណីរឹបអូសសិទ្ធិទាមទារឲ្យប្រគល់ចលនវត្ថុ ។[138]

## ផ្នែកទី២៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឲ្យសងជាប្រាក់

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ គឺសំដៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុរូបី ក្រៅពីប្រាក់ (ចលនវត្ថុ និងអចលនវត្ថុ) ជាប្រភេទបំណុលដែលអាចសម្រេចបានដោយការអនុវត្តដោយផ្ទាល់ដោយប្រើអំណាចរបស់ស្ថាប័នអនុវត្ត ។ ការប្រគល់វត្ថុរូបីមានន័យថា ជាការផ្ទេរការកាន់កាប់ដោយផ្ទាល់ (ការគ្រប់គ្រងជាក់ស្តែង) លើវត្ថុឱ្យទៅម្ចាស់បំណុល ឬតតិយជន ។ម្យ៉ាងវិញទៀត ក្រៅពីការទាមទារឱ្យប្រគល់វត្ថុរូបី ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់ សំដៅផងដែរចំពោះករណីឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពអ្វីមួយ ដែលការអនុវត្តចំពោះការករណីកិច្ចបែបនេះត្រូវធ្វើឡើងតាមវិធីអនុវត្តមិនផ្ទាល់ ពោលគឺករណីយកិច្ចធ្វើសកម្មភាពដែលអាចអនុវត្តជំនួសបានត្រូវអនុវត្តតាមវិធីអនុវត្តជំនួស ហើយករណីធ្វើសកម្មភាពដែលមិនអាចអនុវត្តជំនួសបានត្រូវធ្វើតាមវិធានបង្ខំដោយប្រយោល ។

### កថាខណ្ឌទី១៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុរូបី

#### ១.ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុជាអាទិ៍

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍ សំដៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬទីទំនេរណាមួយឱ្យទៅម្ចាស់បំណុល ឬទៅឲ្យតតិយជន ។ វិធីអនុវត្តធ្វើឡើងតាមវិធីដែលអាជ្ញាសាលារំលាយការកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះ ។[139] ប៉ុន្តែ ដើម្បីសម្រេចតាមគោលបំណងនេះអាជ្ញាសាលាត្រូវបង្គាប់កូនបំណុលនៃការអនុវត្តជាអាទិ៍ឱ្យចាកចេញ ហើយពួកប្រសិនបើគេមិនព្រមធ្វើតាមការបង្គាប់ អាជ្ញាសាលាអាចប្រើកម្លាំង ឬសុំជំនួយពីនគរបាល ។[140] ផ្ទុយមកវិញ បើការអនុវត្តចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយឯករាជ្យដាច់ដោយឡែកពីកូនបំណុលនៃការអនុវត្ត ដូចជាអ្នកជួលជាអាទិ៍ ចាំបាច់ត្រូវមានលិខិតអនុវត្តចំពោះបុគ្គលនោះ។ ប៉ុន្តែ ប្រសិនបើកូនបំណុលនៃការអនុវត្តមានសិទ្ធិទាមទារឱ្យប្រគល់ចំពោះតតិយជន ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឱ្យអនុវត្ត

[138] មាត្រា ៥១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ២០០៦

[139] មាត្រា ៥២៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[140] មាត្រា៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

តាមវិធីដូចការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទៅតុលាការអនុវត្ត ដើម្បីទទួលបានដីកាសម្រេចដែលបង្គាប់ឱ្យរឹបអូសសិទ្ធិទាមទារឱ្យប្រគល់នោះដែលអាចបញ្ជាក់ថា អាចទាមទារឱ្យប្រគល់ចំពោះតតិយជនជំនួសកូនបំណុលនៃការអនុវត្ត ។[141] ដោយឡែក បើតតិយជននោះកាន់កាប់អចលនវត្ថុដើម្បីផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្ត ដូចជាអ្នកទទួលបញ្ញើដោយឥតគិតថ្លៃ ឬអ្នកគ្រប់គ្រងជាអាទិ៍ បើផ្អែកលើលិខិតអនុវត្តដូចជា សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកជាអាទិ៍ ម្ចាស់បំណុលអាចទទួលរូបមន្តអនុវត្តហើយអនុវត្តដោយបង្ខំបាន ។

**២.ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ**

ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ កម្មវត្ថុដែលត្រូវប្រគល់នោះ ចាំបាច់ត្រូវតែជាចលនវត្ថុជាក់លាក់ ប៉ុន្តែ មិនសំខាន់ថាតើនោះជាចលនវត្ថុមួយទាំងមូល ឬជាផ្នែកណាមួយនៃចលនវត្ថុដែលរួមគ្នានោះទេ។ ឧទាហរណ៍ ការទាមទារឱ្យប្រគល់ទំនិញនៅក្នុងហាងណាមួយជាដើម ។ ការអនុវត្តឱ្យប្រគល់ចលនវត្ថុ ត្រូវធ្វើឡើងតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដោយធ្វើការដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។[142] ប៉ុន្តែ បើម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងពុំបង្ហាញខ្លួននៅកន្លែងធ្វើការអនុវត្តដោយបង្ខំទេ អាជ្ញាសាលាអាចធ្វើការព្យួរការអនុវត្តដោយបង្ខំនោះបាន បើទទួលស្គាល់ថាពុំអាចជៀសវាងបានដោយពិចារណាអំពីប្រភេទ និងចំនួនជាអាទិ៍នៃចលនវត្ថុដែលពាក់ព័ន្ធ ។[143] ដោយឡែក ទោះបីជាពុំមានវត្តមានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងក៏ដោយបើអាជ្ញាសាលាបានដកយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវគ្រប់គ្រង និងថែរក្សាចលនវត្ថុ ដែលដកហូតនោះ ។[144] ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ គឺជាការអនុវត្តដោយបង្ខំដែលពុំមានគោលបំណងឱ្យសងជាប្រាក់ ហេតុនេះទោះបីជាចលនវត្ថុនោះមានតម្លៃ ឬគ្មានតម្លៃ ឬចលនវត្ថុនោះជាទ្រព្យសម្បត្តិដែលហាមឃាត់មិនឱ្យរឹបអូសក៏ដោយ ក៏ក្លាយជាកម្មវត្ថុនៃការអនុវត្តចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុនេះដែរ ។ ប៉ុន្តែទោះបីជាយ៉ាងណាការអនុវត្តស្រដៀងគ្នានឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ។ ដូចនេះមាត្រា៣៨៤ កថាខណ្ឌទី៦ មាត្រា៣៨៥ កថាខណ្ឌទី២ និងកថាខណ្ឌទី៤ ដល់ទី៦នៃមាត្រា៥២៤ ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរចំពោះការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ ។

---

141 មាត្រា៥២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

142 មាត្រា៥២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

143 មាត្រា៥២៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

144 មាត្រា៥២៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

## កថាខណ្ឌទី២៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើឬមិនឱ្យសកម្មភាពអ្វីមួយ

### ១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពអ្វីមួយ សំដៅលើសិទ្ធិដែលម្ចាស់សិទ្ធិអាចទាមទារឱ្យអ្នកមានករណីយកិច្ចធ្វើសកម្មភាពណាមួយ ហើយបើផ្អែកលើទស្សនទាននៃការអនុវត្តដោយបង្ខំ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែករវាងសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចជំនួសបាន និងសិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលមិនអាចជំនួសបាន ។

- **សិទ្ធិទាមទារឱ្យធ្វើសកម្មភាពអាចជំនួសបាន** សំដៅលើសិទ្ធិទាមទារដែលសកម្មភាពដែលជាខ្លឹមសារនៃតាវកាលិកអាចបំពេញដោយអ្នកផ្សេងបាន ហើយសកម្មភាពដែលបំពេញដោយអ្នកផ្សេងនោះនឹងនាំឱ្យកើតអានុភាពផ្នែកសេដ្ឋកិច្ច និងផ្នែកច្បាប់ដូចគ្នានឹងករណីនៃការធ្វើសកម្មភាពដោយកូនបំណុលនៃការអនុវត្តដោយខ្លួនឯង ដូចជា ការសាងសង់ ការរុះរើអគារ ការដឹកជញ្ជូន ការកាប់ដើមឈើជាអាទិ៍ ។ ការអនុវត្តចំពោះសិទ្ធិទាមទារនេះ ជាគោលការណ៍ ត្រូវធ្វើតាមវិធីនៃការអនុវត្តជំនួស ប៉ុន្តែទោះបីជាសកម្មភាពនោះអាចអនុវត្តជំនួសបានក៏ដោយក៏គេអាចអនុវត្តតាមវិធានបង្ខំដោយប្រយោលបាន ហេតុនេះម្ចាស់បំណុលនៃការអនុវត្តត្រូវជ្រើសរើសវិធីណាមួយក្នុងចំណោមវិធីទាំងនោះនៅពេលដាក់ពាក្យសុំអនុវត្ត ។[145] ការអនុវត្តជំនួសចាប់ផ្ដើមដោយដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្ត ឱ្យតតិយជនបំពេញសកម្មភាពជំនួសតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដីកាសម្រេចនេះ ហៅថា **ដីកាសម្រេចប្រគល់សិទ្ធិ** ។[146] នៅពេលដែលដីកាសម្រេចត្រូវបានចេញ តុលាការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង់សោហ៊ុយដែលត្រូវការចាំបាច់ដើម្បីធ្វើសកម្មភាពដែលកំណត់នៅក្នុងដីកាសម្រេចនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្តជាមុនបានតាមពាក្យសុំ ។[147] ប៉ុន្តែបើកូនបំណុលនៃការអនុវត្តមិនព្រមបង់ទេ ការប្រមូលសោហ៊ុយនោះអាចធ្វើទៅបានតាមរយៈការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ដោយយកដីកាសម្រេចនោះធ្វើជាលិខិតអនុវត្ត ។[148] ដោយឡែក បើពុំមានការបង្គាប់ឱ្យបង់ជាមុន ឬចំនួនទឹកប្រាក់ដែលកំណត់ដោយការបង្គាប់នោះមិនគ្រប់គ្រាន់ ម្ចាស់បំណុលនៃការអនុវត្តអាចចេញសោហ៊ុយនោះជំនួសកូនបំណុលសិន រួចទើបសុំឱ្យមានការកំណត់លំអិតអំពីចំនួនទឹកប្រាក់

145 មាត្រា៣៤៩ កថាខណ្ឌទី២ ចំណុច គ និង ង នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

146 មាត្រា៥២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

147 មាត្រា៥២៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

148 មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

នៃសោហ៊ុយសម្រាប់ការអនុវត្តនៅពេលក្រោយ និងប្រមូលសោហ៊ុយនោះពីកូនបំណុលដោយការយកការចាត់ចែងអំពីការកំណត់ចំនួនប្រាក់ប្រដាប់ក្ដីមកធ្វើជាលិខិតអនុវត្ត ។[149]

**-សិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលមិនអាចជំនួសបាន** សំដៅលើសកម្មភាពដែលគោលបំណងរបស់វានឹងសម្រេចបានលុះត្រាតែត្រូវបានបំពេញដោយបុគ្គលជាក់លាក់ដោយខ្លួនឯង ដូចជា ករណីកិច្ចលេងកុន ឬគូគំនូរ និងសរសេរប្រលោមលោក ជាអាទិ៍ ។ កាតព្វកិច្ចប្រភេទនេះ មិនអាចសម្រេចតាមគោលបំណងបានទេ ប្រសិនបើ ការអនុវត្តមិនផ្អែកលើឆន្ទៈស្ម័គ្រចិត្តរបស់កូនបំណុលនៃការអនុវត្ត ពីព្រោះគេមិនអាចបង្ខំទៅលើកូនបំណុលឱ្យអនុវត្ត ។ ហេតុនេះ ដើម្បីអាចសម្រេចនឹងសិទ្ធិទាមទារនេះបានមានតែធ្វើការបង្ខំដោយប្រយោលប៉ុណ្ណោះ ។ ដើម្បីអនុវត្តវិធានបង្ខំដោយប្រយោលម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចអនុវត្តដោយប្រយោល ដោយផ្អែកលើលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដែលបញ្ជាក់អំពីសិទ្ធិទាមទារឲ្យធ្វើសកម្មភាពណាមួយដែលមិនអាចអនុវត្តជំនួសបាន ។ នៅពេលដែលដីកាសម្រេចត្រូវបានចេញ តុលាការអនុវត្តអាចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ជាកំណត់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តស្របទៅតាមថ្ងៃ ឬខែនៃការយឺតយ៉ាវ ឬបង់នូវចំនួនទឹកប្រាក់ជាកំណត់តែម្ដង ប្រសិនបើ កូនបំណុលមិនធ្វើសកម្មភាពជាក់លាក់នៅក្នុងអំឡុងពេលដែលតុលាការកំណត់ ។[150] ក្រោយពេលដែលដីកាសម្រេចអនុវត្តប្រយោលត្រូវបានចេញ ម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្តអាចសុំឱ្យតុលាការអនុវត្តកែប្រែដីកាសម្រេចបាន ដូចជា ពន្យាអំឡុងពេលនៃការអនុវត្តជាអាទិ៍ ។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលនៃការអនុវត្តមិនព្រមធ្វើសកម្មភាពរបស់ខ្លួនក្នុងអំឡុងពេលដែលកំណត់ទេ ម្ចាស់បំណុលអាចយកដីកាសម្រេចអនុវត្តដោយប្រយោលធ្វើជាលិខិតអនុវត្ត រួចទទួលរូបមន្តអនុវត្តពិសេសលើឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះ ហើយធ្វើការអនុវត្តដោយបង្ខំដើម្បីប្រមូលនូវប្រាក់នោះ ។ ម្យ៉ាងវិញទៀត បើចំនួនទឹកប្រាក់នៃការខូចខាតដែលម្ចាស់បំណុលនៃការអនុវត្ត ទទួលរងដោយសារការមិនធ្វើសកម្មភាពរបស់កូនបំណុលនៃការអនុវត្តលើសពីចំនួនទឹកប្រាក់ដែលត្រូវបានបង្គាប់នៅក្នុងដីកាសម្រេច ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារសំណងនៃការខូចខាតចំពោះចំនួនទឹកប្រាក់ដែលលើសនោះបាន ។[151]

### ២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ

សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយ សំដៅលើសិទ្ធិដែលម្ចាស់សិទ្ធិដែលទាមទារមិនឱ្យអ្នកមានករណីយកិច្ចធ្វើសកម្មភាពណាមួយ ទោះបីជាសិទ្ធិនោះផ្អែកលើសិទ្ធិលើបំណុល ឬសិទ្ធិប្រត្យក្សក៏ដោយ និង

---

[149] មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ង ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[150] មាត្រា៥២៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[151] មាត្រា៥២៨ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ទោះបីកើតឡើងដោយច្បាប់ ឬដោយកិច្ចសន្យាក៏ដោយ ។ ឧទាហរណ៍ ករណីកិច្ចមិនឱ្យសាងសង់អាគារនៅលើដីណាមួយ ករណីកិច្ចមិនបង្កសំឡេងរំខានសិទ្ធិទាមទារឱ្យទប់ស្កាត់ពិសេសត្រូវបានទទួលស្គាល់ដោយច្បាប់សារធាតុតាមមាត្រា ១៥៩ កថាខណ្ឌទី២ និងមាត្រា២៤០ នៃក្រមរដ្ឋប្បវេណី ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពអ្វីមួយអាចធ្វើតាមវិធានបង្ខំដោយប្រយោល តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ។ គោលបំណងនៃការអនុវត្តចំពោះសិទ្ធិទាមទារប្រភេទនេះ គឺទប់ស្កាត់ការបំពាន ឬបញ្ឈប់ការបំពានដែលកំពុងតែកើតមាន ក្នុងករណីបែបនេះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចបង្គាប់ឱ្យបញ្ឈប់ការបំពាននៅក្នុងអំឡុងពេលកំណត់មួយ ឬឱ្យបញ្ឈប់ជាបន្ទាន់ ហើយបង្គាប់ឱ្យបង់ប្រាក់មួយចំនួនស្របទៅតាមអំឡុងពេលយឺតយ៉ាវ ឬឱ្យបង់ភ្លាម ប្រសិនបើមិនបញ្ឈប់ការបំពាននោះ ។[152] ក្នុងករណីអំពើបំពានលើករណីយកិច្ចមិនឱ្យធ្វើសកម្មភាពអ្វីមួយត្រូវបានធ្វើឡើង អំពើបំពានដែលបានធ្វើរួចមិនអាចដកចេញបានទេ ប៉ុន្តែប្រសិនបើ លទ្ធផលនៃអំពើបំពាននោះនៅមានសេសសល់ ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារឱ្យដកចេញនូវលទ្ធផលនៃអំពើបំពាននោះបានតាមវិធីអនុវត្តជំនួសដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្ត[153] ។[154]

**ផ្នែកទី៣៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ**

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគត្រូវបានចាត់ទុកថាជាការអនុវត្តដោយបង្ខំមួយប្រភេទ ដែលជាគោលការណ៍ត្រូវអនុវត្តតាមបញ្ញត្តិទូទៅនៃការអនុវត្តដោយបង្ខំដែលមានចែងនៅក្នុងជំពូកទី១ គន្ថី៦នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូចជាការអនុវត្តដោយបង្ខំត្រូវផ្អែកលើលិខិតអនុវត្តដូចមានចែងនៅក្នុងមាត្រា ៣៥០ ជាអាទិ៍ ប៉ុន្តែ ការអនុវត្តសិទ្ធិប្រាតិភោគត្រូវផ្អែកលើលិខិតអនុវត្ត សាលក្រម ឬសាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (សាលក្រមដែលទទួលស្គាល់ការទាមទារនៃបណ្ដឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃសិទ្ធិប្រាតិភោគ) ឬលិខិតដែលមានអានុភាពដូចសាក្រម ឬសាលដីកាស្ថាពរ កំណត់ហេតុទទួលស្គាល់ការទាមទារចំពោះអត្ថិភាពនៃហ៊ីប៉ូតែក និងលិខិតយថាភូតដែលធ្វើឡើងដោយសារការីដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគកិច្ចសន្យាហ៊ីប៉ូតែក ។[155] ប៉ុន្តែ ទោះបីជាពុំបានដាក់លិខិតអនុវត្តដូចរៀបរាប់ខាងលើក៏ដោយក៏ការអនុវត្តសិទ្ធិប្រាតិភោគអាចចាប់ផ្ដើមបានដែរ ប្រសិនបើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុយល់ព្រមចំពោះការរឹបអូស ។[156] នៅក្នុងនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិ

[152] មាត្រា៥២៨ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[153] មាត្រា៥២៧ កថាខណ្ឌទី៧ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[154] សៀវភៅ នីតិវិធីរដ្ឋប្បវេណី មេធាវី អ៊ឹរ ប៉ូលី

[155] មាត្រា៤៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[156] មាត្រា៥០០ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ភោគគេអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដើម្បីដោះស្រាយវិវាទអំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬទៅលើអត្ថិភាព និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដើម្បីធ្វើឲ្យវិវាទអំពីការបំពេញលក្ខខណ្ឌបង្អង់ ឬការមកដល់នៃពេលកំណត់មិនពិតប្រាដក ឬអំពីហេតុនៃការបន្តសិទ្ធិ ។

នៅក្នុងការអនុវត្តសិទ្ធិប្រាតិភោគដែលជាសិទ្ធិឃាត់ទុក ម្ចាស់សិទ្ធិឃាត់ទុកអាចដាក់ពាក្យសុំឱ្យលក់ដោយបង្ខំនូវវត្ថុដែលជាកម្មវត្ថុនោះបាន ប៉ុន្តែនេះ មិនមែនជាការទាមទារសំណងដោយមានអាទិភាពទេ ពោលគឺគ្រាន់តែជានីតិវិធីនៃការប្តូរជាប្រាក់ដែលមិនអាចចាត់ទុកថា ជាការអនុវត្តសិទ្ធិប្រាតិភោគទេ ពីព្រោះម្ចាស់សិទ្ធិប្រាតិភោគគ្រាន់តែអាចឃាត់ទុកនូវវត្ថុ រហូតដល់ពេលខ្លួនទទួលការសងចំពោះសិទ្ធិលើបំណុលប៉ុណ្ណោះ។[157]

ដូច្នេះ ការលក់ដោយបង្ខំចំពោះសិទ្ធិឃាត់ទុកមិនទាមទារឱ្យមានលិខិតអនុវត្តទេ ប៉ុន្តែដោយសារវាមានចរិកលក្ខណៈដូចការអនុវត្តសិទ្ធិប្រាតិភោគដោយអនុវត្តនីតិវិធីប្តូរជាប្រាក់ដោយបង្ខំតាមរយៈតុលាការ ទើបច្បាប់ចែងថា នីតិវិធីប្តូរជាប្រាក់ត្រូវអនុវត្តទៅតាមបញ្ញត្តិស្តីពីការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ។[158] នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវបានកំណត់ជាក់លាក់តាមប្រភេទនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ រួមមាន ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត រួមទាំងការអនុវត្តសិទ្ធិប្រាតិភោគចំពោះអលនវត្ថុ និងនាវាផងដែរ ។

**កថាខណ្ឌទី១៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ**

តាមក្រមរដ្ឋប្បវេណី សិទ្ធិប្រាតិភោគដែលមានកម្មវត្ថុជាចលនវត្ថុ រួមមានឯកសិទ្ធិទូទៅលើចលនវត្ថុ និងសិទ្ធិលើការបញ្ចាំ ។ នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវចាប់ផ្តើមដោយការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយអាជ្ញាសាលាតាមវិធីដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ (ការលក់ចលនវត្ថុ និងការចែកចំណែកជាអាទិ៍) ។ ប៉ុន្តែចំពោះសិទ្ធិលើការបញ្ចាំចលនវត្ថុ ច្បាប់ចែងពិសេសអំពីនីតិវិធីសាមញ្ញមួយសម្រាប់ការអនុវត្ត ហៅថា **ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប** ។

**១. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុតាមរយៈការលក់ដោយបង្ខំ**

ដើម្បីអនុវត្តសិទ្ធិប្រាតិភោគ ម្ចាស់បំណុលសិទ្ធិប្រាតិភោគត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំជាលាយលក្ខណ៍អក្សរក្នុងនាមជាម្ចាស់បំណុលនៃការអនុវត្ត ទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងទ្រព្យសម្បត្តិពាក់ព័ន្ធនោះស្ថិតនៅ ហើយពាក្យសុំអនុវត្តត្រូវសរសេរនូវចំណុចដូចមានចែងនៅក្នុងមាត្រា ៥០២ ។ ជាគោលការណ៍ ការអនុវត្តសិទ្ធិប្រាតិភោគទាមទារឱ្យមានលិខិតអនុវត្តដូចមានចែងនៅក្នុងមាត្រា៤៩៦

[157] មាត្រា៧៧៣ និង៧៧៤ នៃក្រមរដ្ឋប្បវេណី, ឆ្នាំ២០០៧

[158] មាត្រា៤៩៩ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ហើយលិខិតអនុវត្តនេះ ត្រូវដាក់ជាមួយពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ប៉ុន្តែបើម្ចាស់បំណុលនៃការអនុវត្តបានដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ដូចជា ករណីម្ចាស់ឯកសិទ្ធិទូទៅ ម្ចាស់ឯកសិទ្ធិចំពោះការលក់ចលនវត្ថុ (មាត្រា៧៩៧ នៃក្រមរដ្ឋប្បវេណី) នោះអាជ្ញាសាលាក៏អាចចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគបានដែរ ។ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវចាប់ផ្តើមដោយដីកាសម្រេចរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយអាជ្ញាសាលា តាមវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ ប៉ុន្តែកម្មវត្ថុនៃការរឹបអូសនៅទីនេះ គឺជាចលនវត្ថុជាក់លាក់ ហេតុនេះ បញ្ញត្តិស្តីពីការហាមឃាត់មិនឱ្យរឹបអូស និងការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណមិនត្រូវយកមកអនុវត្តឡើយ ។ ដោយឡែកចំពោះការរឹបអូសដែលជាការអនុវត្តឯកសិទ្ធិទូទៅ គឺជាទ្រព្យសម្បត្តិទូទៅរបស់កូនបំណុល ហេតុនេះ បញ្ញត្តិដែលទាក់ទងនឹងការហាមឃាត់ការរឹបអូសចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

**២.ការអនុវត្តសិទ្ធិប្រាតិភោគដោយការអនុវត្តដោយខ្លួនឯង (ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប)**

ចំពោះសិទ្ធិលើការបញ្ចាំ ច្បាប់ចែងឱ្យមាននីតិវិធីសាមញ្ញសម្រាប់ការអនុវត្ត ដែលជាបញ្ញត្តិពិសេសនៃនីតិវិធីអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ។ ការអនុវត្តសិទ្ធិប្រាតិភោគដោយខ្លួនឯង ជាវិធីអនុវត្តដោយមិនចាំបាច់មានការលក់ដោយបង្ខំ ហើយការអនុវត្តដោយបង្ខំប្រភេទនេះមិនត្រូវការលិខិតអនុវត្តដូចមានចែងនៅក្នុងមាត្រា៤៩៦ នោះទេបើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ។ ការអនុវត្តដោយខ្លួនឯងធ្វើឡើងដោយម្ចាស់សិទ្ធិលើការបញ្ចាំដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុញ្ញាតឱ្យយកវត្ថុបញ្ចាំនោះ មកសងផ្ទាល់តែម្តង ដោយផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ដែលមានចែងនៅក្នុងមាត្រា៨៣២ និងមាត្រា៥០៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។ ក្នុងករណី តុលាការចេញដីកាសម្រេចតាមពាក្យសុំរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ តុលាការត្រូវជ្រើសតាំងអ្នកវាយតម្លៃឱ្យវាយតម្លៃវត្ថុបញ្ចាំជាមុនផ្អែកលើបញ្ញត្តិស្តីពីការអនុវត្តសិទ្ធិលើការបញ្ចាំ ដោយសង្ខេបដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានកំណត់តម្លៃវត្ថុបញ្ចាំដោយការវាយតម្លៃខ្លួនឯង ហើយកម្មសិទ្ធិករនៃវត្ថុបញ្ចាំយល់ព្រម តុលាការមិនចាំបាច់ជ្រើសតាំងអ្នកវាយតម្លៃនោះទេ ។[159] នៅពេលដែលតុលាការចេញដីកាសម្រេចខាងលើ តុលាការត្រូវប្រកាសថាអនុញ្ញាតឱ្យយកវត្ថុបញ្ចាំមកសងដោយផ្ទាល់ក្នុងចំនួនទឹកប្រាក់សរុបនៃកាតព្វកិច្ចដែលត្រូវសង និងសោហ៊ុយសម្រាប់នីតិវិធី ហើយចំពោះចំនួនទឹកប្រាក់ដែលលើសត្រូវសងទៅកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ ។[160] ក្នុងករណី

[159] មាត្រា៥០៤ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[160] មាត្រា៥០៤ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

ម្ចាស់សិទ្ធិលើការបញ្ចាំមិនសងវិញទេ ដីកាសម្រេចនេះត្រូវបានបកស្រាយថាក្លាយជាលិខិតអនុវត្តសម្រាប់កម្មសិទ្ធិករនៃវត្ថុបញ្ចាំចំពោះសិទ្ធិទាមទារឱ្យសងប្រាក់នៅសល់ ។

**កថាខណ្ឌទី២៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត**

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល សំដៅដល់សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ឬឱ្យប្រគល់ចលនវត្ថុ ដូចបានកំណត់នៅក្នុងមាត្រា៤០១ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមានការបញ្ញត្តិពិសេសស្តីពីការអនុវត្តសិទ្ធិលើបំណុលដោយផ្អែកលើឧបាទេសកម្មលើវត្ថុ ។ ការអនុវត្តសិទ្ធិដោយផ្អែកលើឧបាទេសកម្ម មានន័យថាបុគ្គលដែលមានសិទ្ធិប្រាតិភោគ អនុវត្តសិទ្ធិនោះចំពោះប្រាក់ ឬវត្ថុផ្សេងទៀត ដែលកូនបំណុលត្រូវទទួលដោយការលក់ ការជួលជាអាទិ៍ ជំនួសឱ្យកម្មវត្ថុដើមនៃសិទ្ធិប្រាតិភោគ ដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដូចជាមាត្រា៧៨២, ៨១៧, ៨៤៩ ជាអាទិ៍ ។ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងសិទ្ធិឧបាទេសកម្មលើវត្ថុ ត្រូវចាប់ផ្តើមដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្តដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលតាមមាត្រា៤០៣ កថាខណ្ឌទី៤ដែរ មាត្រា៥០៨ ។ ចំពោះនីតិវិធីនៃការប្តូរជាប្រាក់នូវសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងសិទ្ធិឧបាទេសកម្មលើវត្ថុ ត្រូវអនុវត្តទៅតាមនីតិវិធីដូចគ្នានឹងករណីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ប៉ុន្តែសិទ្ធិឧបាទេសកម្មលើវត្ថុ គេអាចអនុវត្តតាមវិធីប្តូរជាប្រាក់នូវសិទ្ធិទាមទារឱ្យប្រគល់ដូចមានចែងនៅក្នុងមាត្រា៤១៤ ឬការបង្គាប់ឱ្យលក់តាម មាត្រា៤១៣ អាស្រ័យទៅតាមប្រភេទនៃសិទ្ធិដែលជាកម្មវត្ថុនៃឧបាទេសកម្មលើវត្ថុនោះ ។

**កថាខណ្ឌទី៣៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ**

**១. ការរឹបអូសអចលនវត្ថុ**

សិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ សំដៅដល់ហ៊ីប៉ូតែក (មាត្រា៨៤៣នៃក្រមរដ្ឋប្បវេណី) សិទ្ធិលើការបញ្ចាំអចលនវត្ថុ (មាត្រា៨៣៤ នៃក្រមរដ្ឋប្បវេណី) ឯកសិទ្ធិលើអចលនវត្ថុ (មាត្រា៧៩៩ នៃក្រមរដ្ឋប្បវេណី) និងឯកសិទ្ធិទូទៅដែលមានអានុភាពលើអចលនវត្ថុ (មាត្រា៧៨៣ នៃក្រមរដ្ឋប្បវេណី) ។ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ត្រូវធ្វើឡើងតាមវិធីលក់ដោយបង្ខំដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះអលចនវត្ថុដែរលើកលែងតែមានបញ្ញត្តិពិសេស ។[161]

[161] មាត្រា៤១៧ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

នៅក្នុងការលក់ដោយបង្ខំនូវអចលនវត្ថុ ប្រសិនបើមានបន្ទុកដូចជា សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផលជាអាទិ៍ ភ្ជាប់ជាមួយនឹងអចលនវត្ថុដែលជាកម្មវត្ថុ បញ្ហានឹងចោទឡើងតើត្រូវធ្វើដូចម្ដេច ។ ក្នុងករណីនេះ សិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រើប្រាស់ និងអាស្រ័យផលជាអាទិ៍ ដែលអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តបានត្រូវបន្តអានុភាពនៅក្រោយការលក់ ។[162] ប៉ុន្តែ ចំពោះសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផលជាអាទិ៍ និងការចាត់ចែងជាបណ្ដោះអាសន្នដែលមិនអាចតតាំងនឹងការរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្តត្រូវរលត់ និងបាត់បង់អានុភាពក្រោយការលក់[163] (ករណីម្ចាស់បំណុលនៃការអនុវត្តរឹបអូសវត្ថុដែលជាប់ប្រាតិភោគ) ។ ចំពោះការអនុវត្តសិទ្ធិប្រាតិភោគ លក្ខខណ្ឌសម្រាប់បន្តអត្ថិភាព ឬបាត់បង់អានុភាពនៃបន្ទុកលើអចលនវត្ថុ ក្រោយការលក់អាស្រ័យទៅលើបន្ទុកទាំងនោះអាចតតាំងជាមួយសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តបានឬទេ ។ ហេតុនេះ នៅក្នុងការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ សិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់អាស្រ័យផលជាអាទិ៍ ដែលមានភ្ជាប់ជាមួយនឹងអចលនវត្ថុ ហើយអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្តបានត្រូវបន្តអត្ថិភាពក្រោយការលក់ ក្រៅពីនេះត្រូវរលត់ដោយការលក់ដោយបង្ខំ ។[164]

**២.ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ**

តាមក្រមរដ្ឋប្បវេណី នៅពេលដែលអចលនវត្ថុណាមួយត្រូវបានរឹបអូស ដើម្បីអនុវត្តសិទ្ធិប្រាតិភោគ អានុភាពនៃសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុនោះ ត្រូវមានទៅលើផលដែលកើតឡើងចាប់ពីពេលរឹបអូសនោះផងដែរ ។[165] ហេតុនេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិអំពីនីតិវិធីបន្ទាប់បន្សំនៃការលក់ដោយបង្ខំ អំពីវិធីដែលម្ចាស់សិទ្ធិប្រាតិភោគអាចសម្រេចនូវអានុភាពនៃសិទ្ធិនោះ។ មានន័យថា ក្នុងករណីអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគត្រូវបានជួល ប្រសិនបើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដើម្បីអនុវត្តសិទ្ធិប្រាតិភោគត្រូវបានចេញ ហើយការរឹបអូសនោះមានអានុភាព ច្បាប់អនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុនោះទៅតុលាការអនុវត្តបានហើយ បើទទួលស្គាល់ពាក្យសុំនោះ តុលាការអនុវត្តត្រូវចេញដីកាសម្រេចរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួល ។[166] នៅក្នុងដីកាសម្រេចនេះ តុលាការអនុវត្ត ត្រូវហាមឃាត់កូនបំណុលនៃការអនុវត្តប្រមូលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យបង់ថ្លៃឈ្នួល ឬធ្វើការចាត់ចែងផ្សេងទៀត និងត្រូវហាមឃាត់បុគ្គលដែលមានករណីកិច្ចបង់ថ្លៃឈ្នួលក្នុងការសងទៅ

[162] មាត្រា៤៣១ កថាខណ្ឌទី១ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[163] មាត្រា៤៣១ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[164] មាត្រា ៥១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[165] មាត្រា៨៤៨ វាក្យខណ្ឌទី២ ៨១៥ និង៨៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[166] មាត្រា៥១៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

កូនបំណុលនៃការអនុវត្តដោយជំនួសមកវិញ ដោយបង្គាប់ឱ្យជននោះត្រូវផ្ញើប្រាក់ដែលស្មើនឹងចំនួនសរុបនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសទុកនៅតុលាការ ។[167] ម្យ៉ាងទៀត នៅក្នុងនីតិវិធីនេះម្ចាស់បំណុលនៃការអនុវត្តមិនអាចប្រមូលដោយផ្ទាល់នូវសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលបាននោះទេ ពោលគឺគ្រាន់តែអាចទាមទារឱ្យបុគ្គលដែលមានករណីកិច្ចបង់ថ្លៃឈ្នួលផ្ញើប្រាក់ថ្លៃឈ្នួលនោះទៅតុលាការអនុវត្តប៉ុណ្ណោះ តែបើអំឡុងពេល ១ សប្តាហ៍បានកន្លងហួស ដោយគិតចាប់ពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅដល់កូនបំណុលនៃការអនុវត្ត ។[168] អានុភាពនៃការរឹបអូសត្រូវមានទៅលើថ្លៃឈ្នួលដែលកូនបំណុលការអនុវត្តត្រូវទទួលរហូតដល់ពេលដែលអ្នកទិញបង់ថ្លៃលក់អចលនវត្ថុនោះ [169]។[170]

## កថាខណ្ឌទី៤៖ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា

### ១. កំណត់សំគាល់ទូទៅ

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាជាគោលការណ៍ ត្រូវធ្វើឡើងតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ (គន្លឹះទី ៦ ជំពូកទី ២ ផ្នែកទី ៥) ។ នាវា គឺសំដៅលើផលយានដែលមានចំណុះសរុបជាតោនស្មើ និងលើសពី២០តោន ទោះជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។[171] ក៏ប៉ុន្តែ តម្លៃរបស់នាវាមានកម្រិតប្រហាក់ប្រហែលទៅនឹងអចលនវត្ថុដែរ ហើយបទប្បញ្ញត្តិច្បាប់ចែងថា ការធ្វើលទ្ធកម្ម ការបាត់បង់ ការផ្លាស់ប្តូរ ជាអាទិ៍ នូវកម្មសិទ្ធិលើនាវាត្រូវប្រកាសជាសាធារណៈដោយការចុះបញ្ជី ។ ហេតុនេះហើយបានជាគេគិតថា ការអនុវត្តចំពោះនាវាតាមវិធីប្រហាក់ប្រហែលគ្នានឹងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុមានភាពប្រសើរជាងធ្វើតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ។ ដោយហេតុនេះ ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធីដូចគ្នានឹងករណីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែរ ។[172] ដោយមូលហេតុដូចគ្នានេះដែរ បញ្ញត្តិស្តីពីការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាចំពោះការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាផងដែរ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស ។[173]

---

[167] មាត្រា៥១៦ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[168] មាត្រា៥១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[169] មាត្រា៥១៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[170] សៀវភៅនីតិវិធីរដ្ឋប្បវេណី លោកមេធាវី អ៊ីវ ប៉ូលី

[171] មាត្រា ៤៥៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[172] មាត្រា ៤៥៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[173] មាត្រា ៥២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

## ២. ការចាប់ផ្តើមការអនុវត្តសិទ្ធិប្រាតិភោគ

នៅក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវាស្ថិតនៅ ហើយនៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំតុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្ត ។[174] ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាត្រូវធ្វើឡើងតាមការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដោយម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ទៅតុលាការអនុវត្ត ( មាត្រា៤៥៥ កថាខណ្ឌទី២ និងទី៣) ។

ពាក្យសុំនោះ ត្រូវសរសេរបញ្ចូលនូវចំណុចដូចតទៅ : (ក) សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃនាវាដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង ។ (ខ) សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា ។ (គ) សញ្ញាណនៃនាវាដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ ។ (ឃ) ទីកន្លែងដែលនាវាស្ថិតនៅ ព្រមទាំងឈ្មោះរបស់មេបញ្ជាការ ឬបរិបាលនាវា និងទីកន្លែងដែលមេបញ្ជាការ ឬបរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន ។ (ង) ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ។[175]

ពាក្យសុំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តសម្រាប់ការអនុវត្តសិទ្ធិប្រាតិភោគ[176] ព្រមទាំងឯកសារដូចតទៅនេះ ដោយអាស្រ័យទៅតាមប្រភេទនៃសិទ្ធិប្រាតិភោគ : (ក) ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ : ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនាវា[177] (ខ) ករណីដែលអនុវត្តឯកសិទ្ធិទូទៅចំពោះនាវាដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនាវា និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្តត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករ គឺឯកសារដែលបញ្ជាក់ថានាវានោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ។ ចំពោះនាវាដែលមិនត្រូវបានចុះបញ្ជី គឺឯកសារដែលបញ្ជាក់ថានាវាជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត[178] ។

## ៣. នីតិវិធីអនុវត្ត

ចំពោះនីតិវិធីវិញ គឺដូចក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាត្រូវធ្វើឡើងតាមពាក្យសុំរបស់ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ ។ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំនូវនាវា និងត្រូវបង្គាប់ឱ្យអាជ្ញាសាលាដកហូតយកលិខិតបញ្ជាក់សញ្ជាតិ

[174] មាត្រា ៤៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[175] មាត្រា ៥២១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[176] មាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[177] មាត្រា ៥២១ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦
[178] មាត្រា ៥២១ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

នាវា ជាអាទិ៍[179] ដែលជាឯកសារចាំបាច់សម្រាប់ឱ្យនាវាធ្វើចរាចរណ៍ដោយស្របច្បាប់ មកប្រគល់ជូនតុលាការអនុវត្ត ។[180] នៅពេលណាដែលលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ត្រូវបានដកហូតហើយ នាវានោះមិនអាចធ្វើចរាចរណ៍ស្របច្បាប់បានទេ ។ ម្យ៉ាងទៀត ក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ទោះបីជានាវានោះកំពុងស្ថិតនៅក្រោមការកាន់កាប់របស់តតិយជនក៏ដោយ ក៏គេអាចចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំដោយស្របច្បាប់បានដែរ ប្រសិនបើតតិយជននោះពុំមានសិទ្ធិជាមូលហេតុគតិយុត្តនៃការកាន់កាប់ដែលអាចតតាំងជាមួយនឹងម្ចាស់សិទ្ធិប្រាតិភោគបាន ។ តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យតតិយជនដែលកំពុងកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ទៅឱ្យអាជ្ញាសាលា តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន[181]។ ចំពោះដីកាសម្រេចអំពីពាក្យសុំនេះអាចប្តឹងជំទាស់បាន ។[182] ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឱ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ដោយយកដីកាសម្រេចបង្គាប់ឱ្យប្រគល់ដែលបានចូលជាស្ថាពរមកធ្វើជាលិខិតអនុវត្តបាន ។[183] ចំពោះដីកាសម្រេចនេះទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ ។[184] ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវាក៏ត្រូវធ្វើឡើងតាមវិធីនៃការលក់ដោយបង្ខំដូចករណីនៃការអនុវត្តដោយបង្ខំចំពោះនាវាដែរ[185]។[186]

---

[179] មាត្រា ៤៥៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[180] មាត្រា ៤៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[181] មាត្រា ៥២១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[182] មាត្រា ៥២១ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[183] មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុចគ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[184] មាត្រា ៥២១ កថាខណ្ឌទី ៥ ក្រនៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[185] មាត្រា ៤៥៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៦

[186] សេចក្តីពន្យល់អំពីនីតិវិធីរដ្ឋប្បវេណី, ភាគទី២

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **នីតិវិធីអនុវត្តដោយបង្ខំ** រួចមក យើងអាចសន្និដ្ឋានបានថា នេះជានីតិវិធីមួយដែលមានគោលបំណងទាមទារសិទ្ធិលើពីកូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តនៅពេលដែលកូនបំណុលនៃការអនុវត្តមិនព្រមអនុវត្តសិទ្ធិលើបំណុល នោះម្ចាស់បំណុលនៃការអនុវត្តអាចធ្វើការអនុវត្តអនុវត្តដោយបង្ខំតាមរយៈការប្រើប្រាស់អំណាចរដ្ឋ ដូចជា តុលាការអនុវត្ត និងអាជ្ញាសាលា ដែលជាស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច ។ នីតិវិធីនៃការអនុវត្តដោយបង្ខំនេះមានបីប្រភេទដែលមានគោលបំណងខុសពីគ្នា ។ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់ គឺជាការអនុវត្តដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលលនៃការអនុវត្តឲ្យសងជាប្រាក់តាមរយៈការរឹបអូស ដែលអនុវត្តទៅលើចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ព្រមទាំងនាវា ។ រីឯការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឲ្យសងជាប្រាក់ សំដៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុរូបី ក្រៅពីប្រាក់ (ចលនវត្ថុ និងអចលនវត្ថុ) ជាប្រភេទបំណុលដែលអាចសម្រេចបានដោយការអនុវត្តដោយផ្ទាល់ និងការអនុវត្តហាមឃាត់មិនឲ្យធ្វើសកម្ម ឬធ្វើសកម្មភាពអ្វីមួយ ។ ចុងក្រោយការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ គឺជាបញ្ញត្តិពិសេសមួយ ដែលធ្វើការអនុវត្តបានតារយៈសាលក្រម ឬសាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ អាចជាលិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដែលអនុវត្តទៅលើចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត និងអនុវត្តចំពោះនាវា ។ នីតិវិធីនេះអនុវត្តទៅបានលុះត្រាតែមានការដាក់ពាក្យសុំអនុវត្ត ពីម្ចាស់បំណុលនៃការអនុវត្តទៅស្ថាប័នអនុវត្ត ដោយភ្ជាប់ជាមួយនូវឯកសារដែលពាក់ព័ន្ធ ទៅតាមប្រភេទ គោលបំណងនៃការដាក់ពាក្យសុំឲ្យអនុវត្ត និងវិធាន ដូចជា វិធានបង្ខំដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និងវិធានបង្ខំដោយជំនួស ជាដើម ។ ហើយស្ថាប័នមានសមត្ថកិច្ចត្រូវទទួល និងពិនិត្យ លើពាក្យសុំនោះ ហើយចេញដីកាសម្រេចឲ្យអនុវត្តតាមពាក្យសុំ ដោយគោលរពនូវគោលការណ៍ និងនីតិវិធីនៃ ការអនុវត្តឲ្យបានត្រឹមត្រូវ និងឬត់ចត់ជាទីបំផុត ។

ជាចុងក្រោយ នីតិវិធីអនុវត្តដោយបង្ខំពិតជាមានអត្ថប្រយោជន៍ដើម្បីសម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុល ហើយជានីតិវិធីមួយដែលមានភាពឆាប់រហ័សតាមរយៈការអនុវត្តដោយប្រើអំណាចរដ្ឋជាជាងម្ចាស់បំណុលធ្វើការអនុវត្តដោយខ្លួនឯង ។ ប៉ុន្តែវាមានលក្ខណៈនិងនីតិវិធីនៃការអនុវត្តស្មុគស្មាញក្នុងដំណើរនៃការអនុវត្តនីតិវិធីដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុល ។

# អនុសាសន៍

យើងបានដឹងហើយថា **នីតិវិធីនៃការអនុវត្តដោយបង្ខំនេះ** ជាប្រធានបទមួយដែលមានសារៈសំខាន់ណាស់សម្រាប់ម្ចាស់បំណុល ហើយវាក៏ជានីតិវិធីឯករាជ្យមួយក្នុងការចាប់ផ្តើមដោយសរសេរពាក្យសុំរបស់ម្ចាស់បំណុលក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគរបស់ខ្លួនទៅលើកូនបំណុលនៃការអនុវត្តដែលសម្រេចតាមផ្លូវតុលាការ ដែលមានកំណត់នៅក្នុងច្បាប់ដែលមានស្ថាប័នអនុវត្តជាដើម ។

ជាការពិតណាស់ ក្នុងនីតិវិធីនេះវាពិតជាមានការស្មុគស្មាញក្នុងការស្វែងយល់ ដោយមានលំហូរនីតិវិធីជាបន្តបន្ទាប់ចាប់តាំងពីភាគីធ្វើការសុំអនុវត្ត ហើយទទួលបានសាលក្រម ឬសាលដីកា ហើយត្រូវយកសាលក្រម ឬសាលដីកាស្ថាពរនោះទៅធ្វើជាមូលដ្ឋាន ឬធ្វើជាលិខិតអនុវត្តសម្រាប់ដាក់ពាក្យសុំអនុវត្តទៅស្ថាប័នអនុវត្តបន្តទៀត វាពិតជាមានភាពស្មុកស្មាញសម្រាប់នីតិវិធីមួយនេះ ដូច្នេះតម្រូវឲ្យការចេញលិខិតអនុវត្តក៏ដូចជារូបមន្តអនុវត្តដែលមានភាពច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់ជាទំនុកចិត្ត និងយុត្តិធម៌ដល់ភាគីអនុវត្តផងដែរ ។ ព្រោះកន្លងមកនីតិវិធីការអនុវត្តដោយបង្ខំនេះ លទ្ធផលនៃការអនុវត្ត និងប្រសិទ្ធិភាពដែលចេញមកគឺនៅមានកម្រិតនៅឡើយ ដូចជាមានការយឺតយ៉ាវពន្យាពេលលើកពេលអនុវត្ត និងមានបញ្ហាខ្លះៗ នៅក្នុងពេលអនុវត្តចំពោះភាគីនិងអ្នកអនុវត្ត វាក៏ជាកត្តាមួយដែលនាំឲ្យខាតបង់ពេលវេលា និងថវិការ ព្រមបាត់បង់ទំនុកចិត្តដល់ភាគីអនុវត្ត ក៏ដូចជាប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានបាត់បង់ជំនឿ និងទំនុកចិត្តក្នុងការពឹងពាក់លើវិស័យយុត្តិធម៌នេះផងដែរ ។ ហេតុនេះហើយតម្រូវឲ្យអ្នកច្បាប់មានដូចជា តុលាការអនុវត្ត ព្រះរាជអាជ្ញា អាជ្ញាសាលា មេធាវី សាការីភាគីអនុវត្ត និងប្រជាពលរដ្ឋគ្រប់រូបគួរតែធ្វើការឈ្វេងយល់បន្ថែមឲ្យកាន់តែស៊ីជម្រៅច្បាស់លាស់ ជាក់លាក់ប្រាកដដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ជាពិសេសអ្នកអនុវត្តច្បាប់តែម្តង កន្លងមកមានការបកស្រាយផ្សេងៗគ្នា និងមិនស្របគ្នាទៀតផងចំពោះនីតិវិធីនេះដោយមានការស្មុកស្មាញច្រើន ។ ដូច្នេះតម្រូវឲ្យការអនុវត្តនេះមានភាពសុក្រិតងាយស្រួល និងសាមញ្ញ ដើម្បីសម្រួលដល់ការអនុវត្តនេះឲ្យប្រព្រឹត្តិទៅបានរលូន និងឆាប់រហ័ស ព្រមទាំងមានទំនុកចិត្តដល់ភាគីអនុវត្តផងដែរ ។

មួយវិញទៀត ស្ថាប័នដែលមានសមត្ថកិច្ចអនុវត្តគួរតែមានការបែងចែកសមត្ថកិច្ចរបស់ខ្លួនឲ្យបានច្បាស់លាស់ តាមនីតិវិធីច្បាប់ជៀសវាងមានការអនុវត្តខុសនីតិវិធី ដោយកន្លងមកការអនុវត្តជាក់ស្តែងគឺនៅមានភាពភាន់ច្រឡំ ឬអនុវត្តខុសសមត្ថកិច្ចរបស់ខ្លួនជាដើម ។ ហេតុដូច្នេះហើយ ក្រសួងយុត្តិធម៌ក៏ដូចជាស្ថាប័នទាក់ទងទៅនឹងវិស័យច្បាប់ គួរតែបន្តពង្រឹង និងពង្រីកការផ្សព្វផ្សាយអំពីប្រពន្ធ័ច្បាប់ជាបន្តបន្ទាប់បន្ថែមទៀតតាមរយៈប្រព័ន្ធបច្ចេកវិទ្យា សោតទស្សន៍ ឬបណ្តាញសង្គមផ្សេងៗទៀត ឬតាមរយៈបង្កើតកម្មវិធីសិក្ខាសាលាក្តីដើម្បីឲ្យប្រពលរដ្ឋគ្រប់រូប ក៏ដូចជាអ្នកច្បាប់គ្រប់គ្នាបានចូលរួមបានយល់ដឹងច្បាស់លាស់ស៊ីជម្រៅបន្ថែមទៀតដើម្បីជាផ្នែកជួយដល់ការពង្រឹងវិស័យយុត្តិធម៌ផងដែរ ។

# ឯកសារយោង

## ១. វចនានុក្រម

- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត
- សទ្ទានុក្រមពាក្យច្បាប់ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី របស់ទីស្ដីការគណរដ្ឋមន្ត្រីបោះពុម្ពលើកទី១ ឆ្នាំ២០០៧

## ២. វិធានច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជជាណាចក្រកម្ពុជា (១៩៩៣ ដល់ បច្ចុប្បន្ន)
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- សេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា លើកទី៣
- ច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១១

## ៣. ប្រកាស និងសេចក្ដីណែនាំ

- ប្រកាសស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- ប្រកាសអន្តរក្រសួង ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
- ប្រកាសអន្តរក្រសួង ស្ដីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

## ៤.សៀវភៅ និងឯកសារផ្សេងៗ

- សៀវភៅសេចក្ដីពន្យល់ ក្រមនីតិវិធីរដ្ឋប្បវេណីភាគ២ ការអនុវត្តដោយបង្ខំ របស់ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៨
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ឆ្នាំ២០០៧
- សៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ អ៊ីវ ប៉ូលី ឆ្នាំ២០១១

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍ភ្នំពេញ

លេខ

## រូបមន្តអនុវត្តពិសេស

យើង................................ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ។

-**បានឃើញ** មាត្រា **៣៥៤** មាត្រា **៣៥៥** មាត្រា **៣៥៦** និងមាត្រា **៣៥៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-**បានឃើញ** សាលដីការដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី.......... ខែ.........ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ។

-**បានឃើញ** លិខិតបញ្ជាក់ការចូលស្ថាពរលេខ .......... ចុះថ្ងៃទី.......... ខែ.........ឆ្នាំ.......... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

-**បានឃើញ** របាយការណ៍បញ្ជាក់អំពីលក្ខខណ្ឌ ឬពេលវេលាមិនពិតប្រាកដ (បញ្ជាក់អំពីលក្ខខណ្ឌដែលបានបំពេញ ឬពេលវេលាបានមកដល់)។

-**បានឃើញ** ពាក្យសុំ ចុះថ្ងៃទី.......... ខែ..........ឆ្នាំ២០..... របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ......................(ចំពោះភាគី ឬបុគ្គលក្រៅពីភាគី) ដែលមានខ្លឹមសារស្នើសុំរូបមន្តអនុវត្តសាលដីការដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី........ ខែ......... ឆ្នាំ២០....... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

-**បានឃើញ** សេចក្តីអនុញ្ញាតិរបស់តុលាការ ដែលក្រឡាបញ្ជីស្ថិតនៅ។

### សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ........................ មានអាសយដ្ឋាន ................................ ............................. អាចអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់(ត្រង់ផ្នែកណាមួយ ឬសេចក្តីសម្រេចទាំងមូល)សាលដីការដ្ឋប្បវេណីលេខ.............. ចុះថ្ងៃទី........ខែ........ឆ្នាំ២០....... របស់សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ.........................មានអាសយដ្ឋាន........................... ..................................................................................................................................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមរូបមន្តអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់។**

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............. ឆ្នាំ.............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

## លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលដីកា

យើង................................ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ

-**បានឃើញ** មាត្រា **១៩៣** មាត្រា **២៥៤** និងមាត្រា **២៧៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ .......... ចុះថ្ងៃទី......... ខែ........ឆ្នាំ......... របស់សាលាឧទ្ធរណ៍ភ្នំពេញ

-**បានឃើញ** សាលដីការដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី......... ខែ.........ឆ្នាំ......... របស់សាលាឧទ្ធរណ៍ភ្នំពេញ

-**បានឃើញ** របាយការណ៍បញ្ជូនសាលដីកា ចុះថ្ងៃទី..........ខែ.........ឆ្នាំ.................... ។

-**បានឃើញ** កាលបរិច្ឆេទដែលភាគីនីមួយៗបានទទួលការបញ្ជូនអនុសារសាលដីកា។

-**បានឃើញ** ពាក្យសុំ ចុះថ្ងៃទី......... ខែ.........ឆ្នាំ......... របស់ឈ្មោះ....................... ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលដីការដ្ឋប្បវេណី លេខ.......... ថ្ងៃទី......... ខែ.......ឆ្នាំ.......... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

### បញ្ជាក់ថា

១.សាលដីការដ្ឋប្បវេណីលេខ ............... ថ្ងៃទី............. ខែ..........ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ បានចូលស្ថាពរ ចាប់ពីថ្ងៃទី .......... ខែ........ ឆ្នាំ.......... រួចហើយ។

២.លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលដីកានេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃ................................ ខែ......... ឆ្នាំ.... ....ស័ក ព.ស.២........

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............. ឆ្នាំ............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

## រូបមន្តអនុវត្តសាលដីកា

យើង................................ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** មាត្រា ៣៥៤ មាត្រា ៣៥៥ **និង**មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**-បានឃើញ** សាលដីការដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី....... ខែ.......ឆ្នាំ......... របស់ សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** លិខិតបញ្ជាក់ការចូលស្ថាពរលេខ ..... ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់ សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី........... ខែ......... ឆ្នាំ.......... របស់ម្ចាស់បំណុលនៃការអនុវត្ត ឈ្មោះ................. ដែលមានខ្លឹមសារ ស្នើសុំរូបមន្តអនុវត្តសាលដីការដ្ឋប្បវេណី លេខ..... ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

### សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ.................... មានអាសយដ្ឋាន....................................... អាចអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់(គ្រង់ផ្នែកណាមួយ ឬសេចក្តីសម្រេចទាំងមូល) សាលដីការដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ..............មានអាសយដ្ឋាន..............................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមរូបមន្តអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់។**

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

**បានឃើញ**

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.............. ឆ្នាំ............

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ក្រឡាបញ្ជី**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

**ម្ចាស់បំណុលនៃការអនុវត្ត** ៖ ឈ្មោះ..............................ភេទ....... អាយុ......ឆ្នាំ សញ្ជាតិ.......
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......... ចុះថ្ងៃទី.......
ខែ....... ឆ្នាំ....... មានអាសយដ្ឋានផ្ទះលេខ .......... ផ្លូវលេខ..........
ភូមិ.......... សង្កាត់.......... ខណ្ឌ.......... រាជធានីភ្នំពេញ។

**កូនបំណុលនៃការអនុវត្ត** ៖ ឈ្មោះ..............................ភេទ....... អាយុ......ឆ្នាំ សញ្ជាតិ.......
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ .......... ចុះថ្ងៃទី.......
ខែ....... ឆ្នាំ....... មានអាសយដ្ឋានផ្ទះលេខ .......... ផ្លូវលេខ..........
ភូមិ.......... សង្កាត់.......... ខណ្ឌ.......... រាជធានីភ្នំពេញ។

## សូមគោរពជូន
## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ សំណើសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដោយផ្អែកតាមសាលក្រមរដ្ឋប្បវេណីស្ថាពរ លេខ.... ចុះថ្ងៃទី.........ខែ..........ឆ្នាំ........របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖ -មាត្រា៤១៧ មាត្រា៣៤៩ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី
-សាលក្រមរដ្ឋប្បវេណីលេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..របស់សាលាដំបូងរាជធានីភ្នំពេញ
-រូបមន្តអនុវត្តលេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..របស់សាលាដំបូងរាជធានីភ្នំពេញ
-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ.......ចុះថ្ងៃទី...ខែ....ឆ្នាំ..

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពនិងជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបនូវសញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឲ្យអនុវត្ត និងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ដូចខាងក្រោម៖

### ១.- សញ្ញាណនៃលិខិតអនុវត្ត

-បានឃើញសំណុំរឿងអនុវត្តលេខ...........................................................

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ..................ចុះថ្ងៃទី.........ខែ.........ឆ្នាំ.....របស់សាលាដំបូង............................។

-បានឃើញលិខិតបញ្ជាក់ការចូលជាស្ថាពរ...............................នៃសាលាដំបូង....

-បានឃើញបមន្ទអនុវត្ត................ របស់ក្រឡាបញ្ជីនៃសាលាដំបូង..................

-បានឃើញពាក្យសុំអនុវត្តសាលក្រមស្ថាពរចុះថ្ងៃទី..........ខែ.........ឆ្នាំ..................របស់ឈ្មោះ.............................................................................................។

-បានឃើញលិខិតតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលនៃការអនុវត្តចុះថ្ងៃទី.........ខែ............ឆ្នាំ...........របស់លោកមេធាវី..........................................................។

## ឃើញថា

សាលក្រមរដ្ឋប្បវេណី.......................................................................................

មានអានុភាពអនុវត្តហើយជាពិសេសត្រង់ចំណុច..........................................................។

– ការអនុវត្តដោយស្ម័គ្រចិត្តចំណេញពេលវេលា និងសោហ៊ុយក្នុងការអនុវត្តរបស់ភាគីនៃការអនុវត្ត ។

## ជម្រាបមក

– កូនបំណុលនៃការអនុវត្តឈ្មោះ.........................................................................

...............................................................................................................

.................................កូនបំណុលនៃការអនុវត្តត្រូវអនុវត្តដោយស្ម័គ្រចិត្តនូវសាលក្រមរដ្ឋប្បវេណីខាងលើនេះ ក្នុង រយៈពេល២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃទទួលលិខិតនេះ។ ក្នុងករណីខកខានមិនអនុវត្តតាម.........................................នេះទេ យើងនឹងចាត់ការតាមនីតិវិធីច្បាប់។

ទទួលបានលិខិតបង្គាប់ឱ្យអនុវត្តដោយស្ម័គ្រចិត្តនេះ កូនបំណុលនៃការអនុវត្តតប្បីអនុវត្ត តាមខ្លឹមសារនៃលិខិតនេះក្នុងស្មារតីទទួលខុសត្រូវនិងប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

................ថ្ងៃទី.....ខែ.........ឆ្នាំ.........

**អាជ្ញាសាលា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាសាលានៃសាលាដំបូង......

## លិខិតលើកចោលពាក្យសុំអនុវត្ត

យើង........................ អាជ្ញាសាលានៃសាលាដំបូង................................។

-បានឃើញមាត្រា៣៤៩មាត្រា៣៨៤ និងមាត្រា៣៧៥ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស.រកម.០៧០៦.០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញសំណុំរឿងអនុវត្តដោយអាជ្ញាសាលាលេខ......................................

-បានឃើញលិខិតបង្គាប់ឱ្យកែតម្រូវពាក្យសុំឱ្យអនុវត្តលេខ..............................

-បានឃើញពាក្យសុំអនុវត្តលេខ...........................................................

ដែលមានម្ចាស់បំណុលនៃការអនុវត្ត÷ឈ្មោះ....................អាយុ...........សញ្ជាតិ.........

កាន់អត្តសញ្ញាណប័ណ្ណលេខ...............អាសយដ្ឋានផ្ទះលេខ........ផ្លូវ..........ភូមិ..............

សង្កាត់/ឃុំ..........ខណ្ឌ/ស្រុក/ក្រុង.....................រាជធានី/ខេត្ត..............មានអ្នកតំណាងដោយអាណត្តិជាមេធាវីឈ្មោះ.........................អត្តលេខ.....................................។

និងកូនបំណុលនៃការអនុវត្ត÷ឈ្មោះ....................អាយុ...........សញ្ជាតិ...............

កាន់អត្តសញ្ញាណប័ណ្ណលេខ...................អាសយដ្ឋានផ្ទះលេខ.......ផ្លូវ..........ភូមិ.......

សង្កាត់/ឃុំ................ខណ្ឌ/ស្រុក/ក្រុង............រាជធានី/ខេត្ត.........................។

ដោយម្ចាស់បំណុលនៃការអនុវត្តមិនព្រម...........................................។

## ហេតុដូច្នេះសម្រេច

លើកចោលពាក្យសុំឱ្យអនុវត្តចុះថ្ងៃទី...... ខែ......... ឆ្នាំ.........របស់ឈ្មោះ....... ................ជាម្ចាស់បំណុលនៃការអនុវត្ត ពីសំណុំរឿងអនុវត្តលេខ......... ចុះថ្ងៃទី......... ខែ........... ឆ្នាំ......... របស់អាជ្ញាសាលានៃសាលាដំបូង.......................................។

ធ្វើនៅ............, ថ្ងៃ......... ខែ......... ឆ្នាំ.......

**អាជ្ញាសាលា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាសាលានៃសាលាដំបូង......

## លិខិតបង្គាប់ឲ្យកែតម្រូវពាក្យសុំអនុវត្ត

យើង........................ អាជ្ញាសាលានៃសាលាដំបូង.................................។

-បានឃើញមាត្រា៣៨៩ និងមាត្រា៣៨៤ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស.រកម.០៧០៦.០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញសំណុំរឿងអនុវត្តដោយអាជ្ញាសាលាលេខ......................................

-បានឃើញពាក្យសុំអនុវត្តលេខ...............................................................

ដែលមានម្ចាស់បំណុលនៃការអនុវត្ត÷ឈ្មោះ....................អាយុ...........សញ្ជាតិ........ កាន់អត្តសញ្ញាណប័ណ្ណលេខ...............អាសយដ្ឋានផ្ទះលេខ.......ផ្លូវ.........ភូមិ.............. សង្កាត់/ឃុំ.........ខណ្ឌ/ស្រុក/ក្រុង......................រាជធានី/ខេត្ត.............មានអ្នកតំណាង ដោយអាណត្តិជាមេធាវីឈ្មោះ..........................អត្តលេខ.................................។ និងកូនបំណុលនៃការអនុវត្ត÷ឈ្មោះ....................អាយុ...........សញ្ជាតិ................ កាន់អត្តសញ្ញាណប័ណ្ណលេខ.................អាសយដ្ឋានផ្ទះលេខ......ផ្លូវ..........ភូមិ...... សង្កាត់/ឃុំ................ខណ្ឌ/ស្រុក/ក្រុង...........រាជធានី/ខេត្ត............................។

## សូមជម្រាបមក

លោក/លោកស្រី..........................ជាម្ចាស់បំណុលនៃការអនុវត្តឱ្យធ្វើការកែតម្រូវពាក្យសុំខាងលើត្រង់ចំណុច............ ក្នុងរយៈពេលសមរម្យ............................

..........................................................................................................

ជាកំណត់ចាប់ពីថ្ងៃទី.......ខែ...........ឆ្នាំ.........ដែលបានទទួលដំណឹងពីលិខិតជូនដំណឹងនេះ។

ធ្វើនៅ...........,ថ្ងៃ.........ខែ.........ឆ្នាំ.......

អាជ្ញាសាលា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

—

អាជ្ញាសាលានៃសាលាដំបូង......

## ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

**ម្ចាស់បំណុលនៃការអនុវត្ត** ÷ ឈ្មោះ.................... អាយុ........... សញ្ជាតិ....................

កាន់អត្តសញ្ញាណប័ណ្ណលេខ............... អាសយដ្ឋានផ្ទះលេខ....... ផ្លូវ......... ភូមិ..............

សង្កាត់/ឃុំ......... ខណ្ឌ/ស្រុក/ក្រុង...................... រាជធានី/ខេត្ត............. មានអ្នកតំណាង

ដោយអាណត្តិជាមេធាវីឈ្មោះ.......................... អត្តលេខ.................................។

**កូនបំណុលនៃការអនុវត្ត** ÷ ឈ្មោះ.................... អាយុ........... សញ្ជាតិ....................

កាន់អត្តសញ្ញាណប័ណ្ណលេខ.................. អាសយដ្ឋានផ្ទះលេខ...... ផ្លូវ.......... ភូមិ......

សង្កាត់/ឃុំ............... ខណ្ឌ/ស្រុក/ក្រុង........... រាជធានី/ខេត្ត.............................។

### សូមគោរពជូន

### លោក/លោកស្រី អាជ្ញាសាលានៃសាលាដំបូង...

**កម្មវត្ថុ** ÷ សំណើសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ.............................................។

**យោង** ÷ សាលក្រម/សាលដីកា/ដីកាសម្រេចលេខ......... ចុះថ្ងៃទី...... ខែ............ ឆ្នាំ....

របស់សាលាដំបូងរាជធានី/ខេត្ត..................................................។

- លិខិតរូបមន្តអនុវត្តលេខ......... ចុះថ្ងៃទី...... ខែ....... ឆ្នាំ.......... របស់សាលា

ដំបូងរាជធានី/ខេត្ត.........................................................។

- លិខិតបញ្ជាក់ការចូលជាស្ថាពរលេខ.............. ចុះថ្ងៃទី....... ខែ...... ឆ្នាំ..........

របស់សាលាដំបូងរាជធានី/ខេត្ត...........................។

**១.សញ្ញាណនៃលិខិតអនុវត្ត÷** សាលក្រម/សាលដីកា/ដីកាសម្រេចលេខ......................នៅក្នុងរឿងក្តីព្រហ្មទណ្ឌ/ រឿងក្តីរដ្ឋប្បវេណីលេខ......................របស់សាលាដំបូងរាជធានី/ ខេត្ត។

**២.សេចក្តីស្នើសុំឲ្យអនុវត្ត÷** ស្នើសុំស្ថាប័នអនុវត្ត ធ្វើការអនុវត្តតាមវិធានបង្ខំដោយផ្ទាល់ចំពោះចលនវត្ថុ÷..........................................................................................

..........................................................................................

..........................................................................................

**៣.សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ÷** សុំរឹបអូសចលនវត្ថុដែលស្ថិតនៅក្នុងទីតាំង..........................................................................................

..........................................................................................

អាស្រ័យដូចជម្រាបជូនខាងលើ **សូមលោក/លោកស្រីអាជ្ញាសាលា** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូមលោក/ លោកស្រីអាជ្ញាសាលាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ..........., ថ្ងៃ......... ខែ.........ឆ្នាំ......

**ស្នាមមេដៃម្ចាស់បំណុល**

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីព្រាង

# ច្បាប់ស្ដីពីអាជ្ញាសាលា

(កែសម្រួលដោយក្រុមប្រឹក្សាអ្នកច្បាប់ និង រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ)

(សេចក្ដីព្រាងលើកទី ៣)

Downloaded from http://www.khmerlaws.org

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព។

**មាត្រា ២.- គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីឋានៈ ការតែងតាំង ការចាត់តែង ការដកហូតពីការអនុវត្តមុខងាររបស់អាជ្ញាសាលា និងចំណុចចាំបាច់ផ្សេងទៀតទាក់ទងនឹងអាជ្ញាសាលា។

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះអាជ្ញាសាលានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី ២

## ការប្រឡងជ្រើសរើស ការតែងតាំងកម្មសិក្សាការី និងការតាំងស៊ប់ក្នុងក្របខ័ណ្ឌ

**មាត្រា ៤ ថ្មី.- លក្ខខណ្ឌចូលរួមប្រឡងជ្រើសរើស**

ត្រូវបានប្រឡងជ្រើសរើសអោយចូល ជាសិស្សអាជ្ញាសាលានូវបេក្ខជនសញ្ជាតិខ្មែរដែលមានកាយសម្បទាមាំមួនទាំងពីរភេទ ដូចខាងក្រោម៖

ក- បេក្ខជនដែលមានបរិញ្ញាបត្រនីតិសាស្ត្រ និងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៣០ (សាមសិប) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

ខ- បេក្ខជនដែលមានបរិញ្ញាបត្រនីតិសាស្ត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ ព្រមទាំងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

គ- បេក្ខជនជាមន្ត្រីរាជការ ដែលមានបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ និងមានអាយុយ៉ាងច្រើនបំផុតត្រឹម ៤០ (សែសិប) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង និងមិនដែលមានទណ្ឌកម្មវិន័យដែលនាំអោយបាត់បង់នីតិសម្បទាវិជ្ជាជីវៈរបស់ខ្លួន។



Downloaded from http://www.khmerlaws.org

ការកំណត់ចំនួនអាជ្ញាសាលាដែលត្រូវជ្រើសរើស ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៥ ថ្មី** *(មាត្រា ៦ ចាស់)*.- **ការជ្រើសរើសអោយចូលរៀនវគ្គវិក្រឹត្យការ**

អាចត្រូវបានជ្រើសរើសអោយចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈអាជ្ញាសាលា ចៅក្រមដែលមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ និងក្រឡាបញ្ជីដែលមានបទពិសោធន៍យ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ និងមិនដែលមានទណ្ឌកម្មវិន័យដែលនាំអោយបាត់បង់នីតិសម្បទាវិជ្ជាជីវៈរបស់ខ្លួន។

ការប្រឡងជ្រើសរើសត្រូវធ្វើ ប្រសិនបេក្ខជនដាក់ពាក្យមានចំនួនលើសពីការកំណត់ដែលធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៦ ថ្មី** *(មាត្រា ៦ ចាស់)* .- **ការតែងតាំងអាជ្ញាសាលាកម្មសិក្សាការី**

ការតែងតាំងកម្មសិក្សាការីត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អាជ្ញាសាលាកម្មសិក្សាការីត្រូវធ្វើកម្មសិក្សា៖

- រយៈពេល ១២ (ដប់ពីរ) ខែ សម្រាប់សិស្សចេញពីសាលាភូមិន្ទអាជ្ញាសាលាដែលមានសញ្ញាបត្រវិជ្ជាជីវៈអាជ្ញាសាលាដែលចេញដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។
- រយៈពេល ៦ (ប្រាំមួយ) ខែ សម្រាប់សិក្ខាកាមដែលទទួលជោគជ័យក្នុងវគ្គវិក្រឹត្យការនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ចំនួនតម្រូវការអាជ្ញាសាលាត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយសហការជិតស្និទ្ធជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

**មាត្រា ៧ ថ្មី** *(មាត្រា ៧ ចាស់)*..- **បែបបទ និងនីតិវិធីនៃការប្រឡងជ្រើសរើស និងរយៈពេលនៃការបណ្តុះបណ្តាល**

បែបបទ នីតិវិធីនៃការប្រឡងជ្រើសរើស និងរយៈពេលនៃការបណ្តុះបណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។



Downloaded from http://www.khmerlaws.org

## ជំពូកទី ៣

## ថ្មី: ការតែងតាំង ការចាត់តាំង របបទទួលកម្រៃ និងការអនុវត្តមុខងារ

**មាត្រា ៨ ថ្មី** *(មាត្រា ៤ ចាស់)*.- **ថ្មី: មុខងារ កន្លែងបំពេញមុខនាទី និងវិសមិតភាព**

អាជ្ញាសាលា គឺជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងយុត្តិធម៌។

អាជ្ញាសាលា ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យទៅបំពេញមុខងារនៅសាលាដំបូង រាជធានី ខេត្ត អនុលោមតាមលទ្ធផលនៃការជ្រើសរើសរបស់សិស្សអាជ្ញាសាលា ឬសិក្ខាកាមវិក្រឹត្យការវិជ្ជាជីវៈអាជ្ញាសាលា ដោយឈរលើគោលការណ៍ឧត្តមភាពនៃលទ្ធផលសិក្សាដែលប្រកាសដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

ក្នុងករណីមានកិច្ចការចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងអាជ្ញាសាលាដែលបំពេញមុខងារនៅសាលាដំបូង ឱ្យទៅបំពេញការងារនៅសាលាឧទ្ធរណ៍ ឬតុលាការកំពូល តាមសំណើរបស់ សាលាឧទ្ធរណ៍ ឬតុលាការកំពូល។

អាជ្ញាសាលា ត្រូវអនុវត្តកិច្ចការខាងក្រោមនេះ៖

ក- កិច្ចការដែលក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ឬបទដ្ឋានគតិយុត្តផ្សេងទៀត កំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

ខ- កិច្ចការពាក់ព័ន្ធនឹងការរក្សា ការគ្រប់គ្រងវត្ថុ ឬសកម្មភាពផ្សេងទៀតដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា។

មុខងារអាជ្ញាសាលា មានវិសមិតភាពជាមួយនឹងមុខងារជាចៅក្រមអយ្យការ ចៅក្រមអាសនៈ សារការី មេធាវី និងអ្នករាជការសាធារណៈផ្សេងទៀត។

**មាត្រា ៩ ថ្មី.- ការតែងតាំងអាជ្ញាសាលា**

ការតាំងស៊ប់អាជ្ញាសាលាពេញសិទ្ធ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យក្នុងឋានន្តរសក្តិ កព-១៤ តាមសំណើពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពីទទួលបានការវាយតម្លៃពីសាលាដំបូងដែលសាមីខ្លួនធ្វើកម្មសិក្សា។

ការតែងតាំង ការតម្លើងថ្នាក់ ឬឋានន្តរសក្តិ ការដាក់វិន័យ ត្រូវអនុវត្តតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លើកលែងតែមានបញ្ញត្តិចែងផ្សេងពីនេះ។



Downloaded from http://www.khmerlaws.org

**មាត្រា ១០ ថ្មី** *(មាត្រា ៥ ចាស់)*.- **ប្រាក់បៀវត្សរ៍ និងកម្រៃ**

អាជ្ញាសាលា ត្រូវទទួលប្រាក់បៀវត្សរ៍ និងមួយផ្នែកនៃកម្រៃដែលត្រូវបង់ចូលជាថវិការដ្ឋ ចំពោះការអនុវត្តមុខងាររបស់ខ្លួន។ កម្រៃមួយផ្នែកដែលអាជ្ញាសាលាត្រូវទទួលបាន ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌។

**មាត្រា ១១ ថ្មី** *(មាត្រា ៨ ចាស់)*.- **ការត្រួតពិនិត្យលើការអនុវត្តមុខងារ**

អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យពីសាលាដំបូង លើមុខងាររបស់ខ្លួន។

ប្រធានសាលាដំបូង ឬចៅក្រមដែលត្រូវបានចាត់តាំងដោយប្រធានសាលាដំបូង អាចធ្វើការ ចាត់ចែងត្រួតពិនិត្យការអនុវត្តមុខងាររបស់អាជ្ញាសាលាដូចខាងក្រោម៖

ក- ពិនិត្យស្រាវជ្រាវមើល កំណត់ហេតុ បញ្ជី ប្រាក់ ឬវត្ថុដែលពាក់ព័ន្ធនឹងការថែរក្សា។ ពិនិត្យស្រាវជ្រាវមើលកំណត់ហេតុ បញ្ជីរបស់អាជ្ញាសាលា ឬការបង្គាប់ឱ្យអាជ្ញាសាលាប្រគល់វត្ថុដែលថែរក្សាទាំងនោះ ។

ខ- ការចូលរួមក្នុងការអនុវត្តមុខងាររបស់អាជ្ញាសាលា និងការសង្កេតមើលការអនុវត្តមុខងារនោះ។

គ- បង្គាប់ឱ្យអាជ្ញាសាលាធ្វើសេចក្តីរាយការណ៍ ដោយកំណត់អំពីចំណុចដែលត្រូវរាយការណ៍។

ឃ- ផ្តល់ការប្រុងប្រយ័ត្នចំពោះអាជ្ញាសាលា អំពីការចាត់ចែងកិច្ចការ និងអាកប្បកិរិយារបស់ភាគីដែលត្រូវទទួលការអនុវត្ត។

ក្នុងករណីមានហេតុការណ៍ចាំបាច់ដែលពាក់ព័ន្ធនឹងការចាត់ចែង ត្រួតពិនិត្យ ប្រធានសាលាដំបូងត្រូវធ្វើសេចក្តីរាយការណ៍អំពីមតិយោបលរបស់ខ្លួន ឬមតិយោបលរបស់ចៅក្រមទទួលបន្ទុក ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងរយៈពេលមួយដែលសមស្រប។

## ជំពូកទី ៤

## ការបំពេញមុខនាទី

**មាត្រា ១២ ថ្មី** *(មាត្រា ៩ ចាស់)*.- **សមត្ថកិច្ចដែនដី**

អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួន នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។ ប៉ុន្តែ ក្នុងករណីដែលមានការអនុញ្ញាតពីតុលាការ អាជ្ញាសាលាអាចបំពេញមុខនាទីរបស់ខ្លួននៅក្រៅសមត្ថកិច្ចដែនដីនោះបាន។



Downloaded from http://www.khmerlaws.org

ការអនុញ្ញាតដែលបានកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវផ្តល់ដោយតុលាការអនុវត្ត ក្នុងករណីអាជ្ញាសាលាបំពេញមុខនាទីរបស់ខ្លួន តាមការបង្គាប់របស់តុលាការអនុវត្ត។ ករណីផ្សេងពីនេះ ការអនុញ្ញាតត្រូវផ្តល់ដោយប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ក្នុងករណីដែលតុលាការផ្តល់ការអនុញ្ញាត ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកម្រិតតែក្នុងករណីដែលបានកំណត់ខាងក្រោមនេះ៖

ក- ករណីដែលត្រូវរឹបអូសចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ខ- ករណីដែលត្រូវរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

គ- ករណីដែលត្រូវអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បំពេញការងារ។

ឃ- ករណីដែលការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឱ្យប្រគល់ចលនវត្ថុច្រើន ហើយដែលចលនវត្ថុខ្លះក្នុងចំណោមចលនវត្ថុទាំងនោះ ស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

ង- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលត្រូវបានរឹបអូសរួចហើយ។

ច- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ។

ឆ- ករណីដែលចាំបាច់ពិសេសដើម្បីថែរក្សាគ្រប់គ្រងចលនវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន។

ជ- ករណីដែលចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ បែរជាទៅស្ថិតនៅក្រៅសមត្ថកិច្ចនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការរឹបអូសក្នុងការបំពេញការងាររបស់ខ្លួន ហើយដែលចាំបាច់ត្រូវយកចលនវត្ថុនោះមកវិញ។

ឈ- ករណីដែលចលនវត្ថុត្រូវបានរឹបអូសជាបណ្តោះអាសន្នរួចហើយ បែរជាទៅស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការរឹបអូសជាបណ្តោះអាសន្នក្នុងការបំពេញការងាររបស់ខ្លួន ហើយដែលមានការចាំបាច់យកចលនវត្ថុនោះវិញ។



Downloaded from http://www.khmerlaws.org

ញ- ករណីដែលចលនវត្ថុជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន បែរទៅជាស្ថិតនៅក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលានោះ បានធ្វើការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្នក្នុងការបំពេញការងារ ហើយដែលមានការចាំបាច់ត្រូវយកវត្ថុនោះមកវិញ។

ដ- ករណីការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះស្ថិតនៅក្រោម និងក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលា បំពេញការងារ។

ឋ- ករណីការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលបង្គាប់ឱ្យប្រគល់ អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ស្ថិតនៅក្រោម និងក្រៅសមត្ថកិច្ចដែនដីនៃសាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ។

ក្រៅពីករណីដែលបានកំណត់នៅក្នុងចំណុចទីមួយ ១ខាងលើនេះក្នុងករណីដែលមានភាពចាំបាច់ក្នុងការបំពេញមុខនាទីក្រៅសមត្ថកិច្ចដែនដី នៃសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

**មាត្រា ១៣ ថ្មី *(មាត្រា ១០ ចាស់)*.- អ្នកអនុវត្តកិច្ចការជំនួស អ្នកជំនួយក្នុងការអនុវត្តកិច្ចការ**

ជាគោលការណ៍ អាជ្ញាសាលាត្រូវអនុវត្តកិច្ចការដោយខ្លួនឯង។ ប៉ុន្តែ ក្នុងករណីដែល ប្រតិបត្តិការបញ្ជូន ដោយយោងតាមកថាខណ្ឌទី ៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយ ឆន្ទានុសិទ្ធិជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានមូលហេតុពិសេសដែលមិនអាចអនុវត្ត កិច្ចការនោះដោយខ្លួនឯង អាជ្ញាសាលាអាចឱ្យអ្នកអនុវត្តកិច្ចការជំនួស អនុវត្តកិច្ចការនោះជំនួសខ្លួន ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ អាជ្ញាសាលាអាចប្រើអ្នកបច្ចេកទេស ឬកម្មករបាន។

ក្នុងករណីដែលមានការចាំបាច់ក្នុងការអនុវត្តកិច្ចការ អាជ្ញាសាលាអាចប្រើអ្នកជំនួយក្នុងការអនុវត្តកិច្ចការ ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ប្រធានសាលាដំបូងអាចលុបចោលនូវការអនុញ្ញាតដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ ខាងលើនេះ នៅពេលណាក៏បាន។

**មាត្រា ១៤ ថ្មី *(មាត្រា ១១ ចាស់)*.- ក្រឡាបញ្ជីដែលចាត់ចែងកិច្ចការរបស់អាជ្ញាសាលា**

ក្នុងករណីដែលមានការចាំបាច់ពិសេសក្នុងការចាត់ចែងការងាររបស់អាជ្ញាសាលា ប្រធានសាលាដំបូងអាចធ្វើការកំណត់ជាមុននូវក្រឡាបញ្ជីដែលបំពេញកិច្ចការរបស់អាជ្ញាសាលា ដោយកម្រិត ឬមិនកម្រិតនូវប្រភេទនៃកិច្ចការនោះ ហើយឱ្យអ្នកនោះបំពេញកិច្ចការរបស់អាជ្ញាសាលាទាំងស្រុង ឬ មួយភាគបាន។



Downloaded from http://www.khmerlaws.org

ក្នុងករណីដែលមានការចាំបាច់បន្ទាន់ ដោយសារអាជ្ញាសាលាមានគ្រោះថ្នាក់ ឬដោយសារមូលហេតុដទៃទៀត ប្រធានសាលាដំបូងអាចឱ្យក្រឡាបញ្ជីដែលពុំបានកំណត់តាមកថាខណ្ឌទី ១ ខាងលើនេះបំពេញការងាររបស់អាជ្ញាសាលា ទាំងស្រុង ឬមួយភាគបាន។

កម្រៃ ព្រមទាំងសោហ៊ុយដែលត្រូវបង់សម្រាប់បំពេញកិច្ចការអាជ្ញាសាលាដែលបានចាត់ចែង ដោយក្រឡាបញ្ជី ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬទី ២ ខាងលើនេះ គឺជាចំណូលរបស់រដ្ឋ។

**មាត្រា ១៥ ថ្មី** *(មាត្រា ១២ ចាស់)*.**- ជំនួយក្នុងការអនុវត្តកិច្ចការ**

ប្រសិនបើមានការលំបាកពិសេសក្នុងការអនុវត្តកិច្ចការដោយខ្លួនឯង ឬមានការចាំបាច់ពិសេសផ្សេងទៀតក្នុងការអនុវត្តកិច្ចការរបស់ខ្លួន អាជ្ញាសាលាអាចស្នើសុំជំនួយពីអាជ្ញាសាលាផ្សេងទៀត ដោយទទួលការអនុញ្ញាតពីប្រធានសាលាដំបូងដែលខ្លួនបំពេញការងារ។

ប្រសិនបើមិនអាចទទួលនូវការអនុញ្ញាតជាមុនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយសារមានភាពចាំបាច់បន្ទាន់ចំពោះរឿងក្ដី អាជ្ញាសាលាត្រូវសុំការអនុញ្ញាតភ្លាមពីប្រធានតុលាការ ក្រោយពីបានស្នើសុំជំនួយពីអាជ្ញាសលាផ្សេងទៀត។

ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ អាជ្ញាសាលានីមួយៗអាចទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ និងការបង់ ឬការសងនូវសោហ៊ុយចាំបាច់ក្នុងការអនុវត្តកិច្ចការរៀងៗខ្លួនពីរដ្ឋ។

**មាត្រា ១៦ ថ្មី** *(មាត្រា ១៣ ចាស់)*.**- ការរក្សាទុកនូវប្រាក់ដែលបានទទួលតាមកិច្ចការ**

អាជ្ញាសាលាត្រូវប្រគល់ប្រាក់ ឬវត្ថុផ្សេងដែលខ្លួនបានរឹបអូស ឬបានទទួលដោយការប្រគល់តាមការអនុវត្តកិច្ចការរបស់ខ្លួនទៅឱ្យអ្នកដែលទទួលប្រាក់ ឬវត្ថុនោះភ្លាម ឬត្រូវប្រគល់ទៅសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ ដើម្បីរក្សាទុកនូវប្រាក់ ឬវត្ថុនោះ លើកលែងតែករណីដែលសាលាដំបូងត្រូវប្រគល់ទៅជនដែលត្រូវទទួលវត្ថុនោះភ្លាមៗ ឬតម្កល់វត្ថុនោះ ឬករណីផ្សេងទៀតដែលច្បាប់បានកំណត់ ។

នៅពេលដែលទទួលប្រាក់ ឬវត្ថុផ្សេងទៀតពីភាគី ឬបុគ្គលផ្សេងទៀត តាមការអនុវត្តកិច្ចការរបស់ខ្លួន អាជ្ញាសាលាត្រូវចេញលិខិតបញ្ជាក់ការទទួលដែលត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ ឬប្រភេទនិងចំនួននៃវត្ថុដែលខ្លួនបានទទួល និងកាលបរិច្ឆេទនៃការទទួលអោយភាគី ឬបុគ្គលផ្សេងទៀតនោះ និងរក្សាទុកនៅក្នុងសំណុំរឿង។



Downloaded from http://www.khmerlaws.org

## ជំពូកទី៥

## ការចាត់ចែងកិច្ចការ និងបណ្តឹងឧបាស្រ័យ

**មាត្រា ១៧ ថ្មី** *(មាត្រា ១៤ ចាស់)*.- **ការចាត់ចែងកិច្ចការ**

អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការតាមពាក្យសុំ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះកិច្ចការដែលតុលាការឱ្យអាជ្ញាសាលាចាត់ចែងដោយផ្ទាល់ ក្នុងនាមជាកិច្ចការដែលជាផ្នែកមួយនៃនីតិវិធីនៃរឿងក្តីដែលតុលាការនោះកំពុងចាត់ការ។

ការបែងចែកកិច្ចការរបស់អាជ្ញាសាលា ត្រូវកំណត់ដោយដីកាសម្រេចរបស់ប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។ ប៉ុន្តែចំពោះកិច្ចការដែលសេចក្តីសម្រេចរបស់តុលាការបានកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលាជាក់លាក់ណាម្នាក់ក្នុងចំណោមកិច្ចការដែលបានកំណត់ នៅក្នុង ចំណុច ខ កថាខណ្ឌទី៣ នៃមាត្រា ៨ (ឋានៈ មុខងារ កន្លែងបំពេញមុខងារ និងវិសមិតភាព) នៃច្បាប់នេះ អាជ្ញាសាលានោះត្រូវចាត់ចែងកិច្ចការដោយផ្ទាល់។

**មាត្រា ១៨ ថ្មី** *(មាត្រា ១៥ ចាស់)*.- **មូលហេតុនៃការដកខ្លួនដោយឯកឯង និងការដកហូតចេញពីការអនុវត្តមុខការ**

អាជ្ញាសាលាអាចស្នើសុំដកខ្លួនដោយឯកឯងបាន ឬត្រូវបានដកហូតពីការអនុវត្តមុខការដោយប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារតាមការស្នើសុំពីភាគី
ក្នុងករណីដែលបានកំណត់នៅក្នុងចំណុច នីមួយៗ ដូចខាងក្រោមនេះ៖

ក- កាលណាអាជ្ញាសាលា ឬសហព័ទ្ធ ឬអតីតសហព័ទ្ធរបស់អាជ្ញាសាលា ជាភាគីណាមួយក្នុងរឿងក្តីឬមានទំនាក់ទំនងនៃសិទ្ធិរួម ឬកាតព្វកិច្ចរួមជាមួយនឹងភាគីណាមួយ។

ខ- កាលណាអាជ្ញាសាលាជាញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៤ រាប់ទាំងថ្នាក់ទី ៤ នេះផងរបស់ភាគីណាមួយ ឬញាតិដែលរស់នៅជាមួយអាជ្ញាសាលានោះជាភាគីណាមួយនៃរឿងក្តី។

គ- កាលណាអាជ្ញាសាលាជាអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ជាភាគីណាមួយ។

ឃ- កាលណាអាជ្ញាសាលាជាអ្នកតំណាងរបស់ភាគីចំពោះកិច្ចការដែលខ្លួនត្រូវចាត់ចែង។

ង- កាលណាអាជ្ញាសាលាទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។



Downloaded from http://www.khmerlaws.org

**មាត្រា ១៩ ថ្មី *(មាត្រា ១៦ ចាស់)*.- ការស្នើសុំដកខ្លួនដោយឯកឯង និងការដកហូតចេញពីការអនុវត្តមុខការ**

ក្នុងករណីដែលបានកំណត់ក្នុងមាត្រា ១៨ (មូលហេតុនៃការដកខ្លួនដោយឯកឯង និងការដកហូតចេញពីមុខការ) ខាងលើនេះ ភាគី ឬអាជ្ញាសាលា អាចស្នើសុំទៅប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារ។

**មាត្រា ២០ ថ្មី.- ការជូនដំណឹងអំពីពាក្យប្តឹង និងរបាយការណ៍របស់អាជ្ញាសាលាពាក់ព័ន្ធនឹងការប្តឹងដកហូតការអនុវត្តមុខការ**

ពាក្យប្តឹងត្រូវជូនដំណឹងដល់អាជ្ញាសាលាដែលគេប្តឹងដកហូតការអនុវត្តមុខការ។

ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃ បន្ទាប់ពីការជូនដំណឹងនេះ អាជ្ញាសាលាដែលគេប្តឹងត្រូវធ្វើរបាយការណ៍ដោយមានសំអាងហេតុថា ខ្លួនយល់ព្រម ឬជំទាស់នឹងការប្តឹងដកហូត ការអនុវត្តមុខការនេះ។ របាយការណ៍នេះត្រូវបញ្ជូនទៅប្រធានសាលាដំបូងដែលខ្លួនបំពេញមុខការ ដើម្បី សម្រេច។ *Silence means approval*

**មាត្រា ២១ ថ្មី.- ការសម្រេចលើពាក្យប្តឹងដកហូតការអនុវត្តមុខការរបស់អាជ្ញាសាលា**

ការសម្រេចលើពាក្យបណ្តឹងដកហូតការអនុវត្តមុខការរបស់អាជ្ញាសាលា ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលពាក្យបណ្តឹង។ ប្រសិនបើ ប្រធានសាលាដំបូងយល់ឃើញថាពាក្យប្តឹងមានមូលហេតុត្រឹមត្រូវ ប្រធានសាលាដំបូងត្រូវចាត់តាំងអាជ្ញាសាលាថ្មីជំនួសអាជ្ញាសាលាដែលគេប្តឹងដកហូត។ ក្នុងករណីពាក្យប្តឹងត្រូវបដិសេធចោល អ្នកប្តឹងអាចត្រូវទទួលពិន័យមិនលើសពី ២០០.០០០ (ពីរសែន) រៀល ដោយមិនទាន់គិតដល់សំណងជម្ងឺចិត្តដែលអាជ្ញាសាលាទាមទារ ។

ការសម្រេចត្រូវធ្វើឡើងដោយដីការបស់ប្រធានសាលាដំបូងដែលអាជ្ញាសាលានោះបំពេញមុខងារ។ ដីកានេះ មិនអាចប្តឹងតវ៉ាបានឡើយ។ ដីកានេះត្រូវជូនដំណឹងភ្លាម ដល់អាជ្ញាសាលាដែលត្រូវគេប្តឹងដកហូត និងដល់អ្នកប្តឹងសុំដកហូត។

**មាត្រា ២២ ថ្មី *(មាត្រា ១៧ ចាស់)*.- បណ្តឹងឧបាស្រ័យ**

បណ្តឹងឧបាស្រ័យចំពោះការគណនាចំនួនកម្រៃឬសោហ៊ុយ ឬការចាត់ចែងផ្សេងទៀតរបស់អាជ្ញាសាលាស្តីពីកិច្ចការដែលត្រូវបានធ្វើឡើងតាមពាក្យប្តឹងសុំ ឬបណ្តឹងឧបាស្រ័យចំពោះកាយឹតយ៉ាវឬការធ្វេសប្រហែសក្នុងការចាត់ចែងកិច្ចការទាំងនោះត្រូវអនុលោមតាមករណីនៃការតវ៉ា ចំពោះការអនុវត្តដែលបានអនុវត្តនៅក្នុងកថាខណ្ឌទី២ នៃមាត្រា៣៤៤ (ការតវ៉ាចំពោះការអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី លើកលែងតែករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។



Downloaded from http://www.khmerlaws.org

**មាត្រា ២៣ ថ្មី** *(មាត្រា ១៨ ចាស់)*.- **របៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ**

ពាក្យសុំចំពោះអាជ្ញាសាលាត្រូវធ្វើជាលាយលក្ខណ៍អក្សរដែលសរសេរបញ្ជាក់ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាង ព្រមទាំងខ្លឹមសារនៃចំណុចដែលសុំនោះ។

ក្នុងករណីដែលពាក្យសុំត្រូវបានដាក់ដោយអ្នកតំណាង ត្រូវភ្ជាប់លិខិតបញ្ជាក់សិទ្ធិតំណាងជាមួយនឹងពាក្យសុំ។

**មាត្រា ២៤ ថ្មី** *(មាត្រា ១៩ ចាស់)*.- **លំដាប់នៃការចាត់ចែងកិច្ចការ**

អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការតាមលំដាប់ដែលខ្លួនបានទទួល លើកលែងតែករណីដែលមានស្ថានភាពពិសេស។

**មាត្រា ២៥ ថ្មី** *(មាត្រា ២០ ចាស់)*.- **ការចាត់ចែងកិច្ចការក្រៅម៉ោងធ្វើការ**

ប្រសិនបើមានភាពចាំបាច់បន្ទាន់ ឬភាពចាំបាច់ពិសេសផ្សេងទៀត អាជ្ញាសាលាត្រូវចាត់ចែងកិច្ចការទោះជាក្រៅម៉ោងធ្វើការក៏ដោយ។

**មាត្រា ២៦ ថ្មី** *(មាត្រា ២១ ចាស់)*.- **ការយកតាមខ្លួននូវអត្តសញ្ញាណបណ្ណ**

នៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលាត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះចំពោះជនដែលទាក់ទងនិងផលប្រយោជន៍ បើជននោះទាមទារ។

**មាត្រា ២៧ ថ្មី** *(មាត្រា ២២ ចាស់)*.- **ចំណុចត្រូវសរសេរនៅក្នុងកំណត់ហេតុ**

អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន។

នៅក្នុងកំណត់ហេតុដែលអាជ្ញាសាលាត្រូវធ្វើ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះហើយត្រូវសរសេរឈ្មោះ និងចុះហត្ថលេខា៖

ក- សញ្ញាណរឿងក្តី។

ខ- ពេលវេលានិងទីកន្លែងបំពេញមុខនាទី។

គ- ខ្លឹមសារនៃកិច្ចការដែលបានចាត់ចែង។

ឃ- កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ។



Downloaded from http://www.khmerlaws.org

# ជំពូកទី៦

## កម្រៃនិងសោហ៊ុយ

**មាត្រា ២៨ ថ្មី** *(មាត្រា ២៣ ចាស់)*.- **ករណីដែលទទួលកម្រៃ**

អាជ្ញាសាលាត្រូវទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ ក្នុងការចាត់ចែងការងារដែលមានចែងក្នុងចំណុចខាងក្រោមនេះ៖

ក- ការបញ្ជូនឯកសារ ដោយយោងតាមកថាខណ្ឌទី៣ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយអន្ទានុសិទ្ធិ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ខ- ជំនួយដោយយោងតាមកថាខណ្ឌទី ២ មាត្រា ៣៣៨ (ការធានាក្នុងការបំពេញមុខនាទីរបស់អាជ្ញាសាលាជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

គ- ការមើលសំណុំរឿងក្ដីឬការថតចម្លងសំណុំរឿង ការសុំឱ្យប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ឬការសុំឱ្យប្រគល់លិខិត បញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងរឿងក្ដី ដោយយោងតាមកថាខណ្ឌទី ២ មាត្រា ៣៧៨ (ការមើល សំណុំរឿងនៃរឿងក្ដីអនុវត្តដោយបង្ខំ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឃ- ការអនុវត្តការរឹបអូសឬការរឹបអូសជាបណ្ដោះអាសន្ននូវចលនវត្ថុ ដោយយោងតាមកថាខណ្ឌទី៣ មាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ) និងកថាខណ្ឌទី១ មាត្រា៥៦៥ (ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ង- ការទទួលសំណាងដោយយោងតាមកថាខណ្ឌទី៦ មាត្រា ៣៨៤ (ការចាប់ផ្ដើមអនុវត្តចំពោះចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ច- កិច្ចការពាក់ព័ន្ធនឹងនីតិវិធី ដោយយោងតាមកថាខណ្ឌទី១ មាត្រា ៣៨៨ (ការរួមបញ្ចូល រឿងក្ដី) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឆ- ការទទួលនូវចលនវត្ថុដើម្បីប្ដូរជាប្រាក់ ដោយយោងតាមកថាខណ្ឌទី១ មាត្រា ៣៩០ (ដីកាសម្រេចបង្គាប់ឱ្យប្រគល់ចលនវត្ថុដែលត្រូវបានរឹបអូស) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ជ- កិច្ចការពាក់ព័ន្ធនឹងការទាមទារឱ្យចែកចំណែក ដោយយោងតាមមាត្រា ៣៩៤ (ការទាមទារឱ្យចែកចំណែកពីអ្នកមានឯកសិទ្ធិជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ឈ- កិច្ចការពាក់ព័ន្ធនឹងការលក់ឬការប្ដូរជាប្រាក់ផ្សេងទៀត ដោយយោងតាមកថាខណ្ឌទី១ នៃមាត្រា៤១៣ (ដីការសម្រេចបង្គាប់ឱ្យលក់) កថាខណ្ឌទី១នៃមាត្រា ៤១៤ (ការអនុវត្ត



Downloaded from http://www.khmerlaws.org

ដីកាសម្រេចរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ) កថាខណ្ឌទី៣ នៃមាត្រា៤៣៦ (វិធីលក់ ជាអាទិ៍)កថាខណ្ឌ ទី២ នៃមាត្រា ៤៦៩ (វិធីលក់ជាអាទិ៍)និងកថាខណ្ឌទី ៦ នៃ មាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យ ប្រគល់អចលនវត្ថុជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ញ- ការអនុវត្តការចែកចំណែក ដោយយោងតាមមាត្រា ៣៩៩ (ការចែកចំណែកដោយអាជ្ញាសាលា) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដ- ការបង្គាប់ឱ្យលះបង់ការកាន់កាប់អចលនវត្ថុ ហើយថែរក្សាអចលនវត្ថុនោះ ដោយយោងតាមកថាខណ្ឌ ទី ១ មាត្រា ៤២៩ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឋ- ការដកហូតនូវលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៤៥៩ (ដីកា សម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់នាវា ជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំ) និងកថាខណ្ឌទី ១ មាត្រា ៥៦៨ (ការអនុវត្តរឹបអូសបណ្ដោះអាសន្នចំពោះនាវា) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឌ- ការថែរក្សានាវា ដោយយោងតាមមាត្រា ៤៦០ (ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រង ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឍ- ការរំលាយនូវការកាន់កាប់អចលវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះពីកូនបំណុល ហើយប្រគល់ការកាន់កាប់នោះទៅឱ្យម្ចាស់បំណុលដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៥២៤ (ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ណ- ការដកយកចលនវត្ថុពីកូនបំណុល ហើយប្រគល់ទៅឱ្យម្ចាស់បំណុលដោយយោងតាម កថាខណ្ឌទី ១ មត្រា ៥២៥ (ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ត- ការអនុវត្តដោយផ្អែកលើដីកាសម្រេចអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៥២៧ (ការអនុវត្តជំនួស) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ថ-ការរក្សាវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬកិច្ចការផ្សេងទៀតដោយយោងតាម មាត្រា ៥៤៩ (វិធីចាត់ចែងជាបណ្ដោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ទ- ការប្រកាសជាសាធារណៈ ដោយយោងតាមកថាខណ្ឌទី ១ មាត្រា ៥៧១ (អានុភាពនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់)នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Downloaded from http://www.khmerlaws.org

ធ- ការពិនិត្យស្ថានភាពនៃការថែរក្សាគ្រប់គ្រងដោយកូនបំណុល ឬអ្នកផ្សេងទៀតនូវចលនវត្ថុ ដែលបានអនុវត្តការរឹបអូស ឬការរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុផ្សេងទៀតដែលអាជ្ញាសាលាកំពុង ថែរក្សាគ្រប់គ្រង ។

ន- កិច្ចការដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ៣ មាត្រា ៤ (មុខងារ ឋានៈ កន្លែង អនុវត្តកិច្ចការ) នៃច្បាប់នេះ ហើយដែលជាកិច្ចការ ក្រៅពីកិច្ចការដែលបានកំណត់ពី ចំណុច ក ដល់ចំណុច ធ ខាងលើនេះ ។

ក្នុងករណីដែលអាជ្ញាសាលាទៅដល់ទីកន្លែងដែលខ្លួនបំពេញកិច្ចការដែលបានកំណត់ នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែអាជ្ញាសាលានោះមិនអាចបំពេញកិច្ចការនោះ ដោយមានមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់ខ្លួន អាជ្ញាសាលានោះត្រូវទទួលកម្រៃមួយផ្នែកដែលត្រូវបានបង់ចូលថវិការដ្ឋ ដែលទាក់ទងនឹងកិច្ចការនោះ ទោះបីជាមុនពេលធ្វើ កិច្ចការនោះក៏ដោយ ។

**មាត្រា ២៩ ថ្មី** *(មាត្រា ២៤ ចាស់)*.- **ចំនួនប្រាក់កម្រៃ**

ចំនួនប្រាក់កម្រៃនៃកិច្ចការដែលបានកំណត់ពីចំណុច ក ដល់ចំណុច ធ នៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយពិចារណាដល់ខ្លឹមសារនៃកិច្ចការផលប្រយោជន៍ដែលភាគីនឹងទទួលស្ថានភាពនៃតម្លៃទំនិញ ស្ថានភាពនៃប្រាក់បៀវត្សរ៍ទូទៅ និង ស្ថានភាពទាំងឡាយផ្សេងទៀត ។

ចំនួនប្រាក់កម្រៃនៃកិច្ចការដែលបានកំណត់នៅក្នុងចំណុច ន នៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាងលើនេះ ត្រូវកំណត់ដោយតុលាការដែលតម្រូវឱ្យអាជ្ញាសាលាបំពេញកិច្ចការនោះក្នុងការសម្រេចសេចក្ដី ឬសាលាដំបូងដែលអាជ្ញាសាលានោះបំពេញការងារដោយគិតពិចារណាដល់ចំនួនប្រាក់កម្រៃនៃកិច្ចការប្រភេទប្រហាក់ប្រហែលគ្នាក្នុងចំណោមកិច្ចការទាំងឡាយដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ នៃមាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) ខាង លើនេះ ។

**មាត្រា ៣០ ថ្មី** *(មាត្រា ២៥ ចាស់)*.- **ពេលវេលាត្រូវទទួលប្រាក់កម្រៃ**

អាជ្ញាសាលាត្រូវទទួលប្រាក់កម្រៃមួយផ្នែកដែលត្រូវបានបង់ចូលជាថវិការដ្ឋ នៅពេលដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ៖

ក- ពេលបានបញ្ចប់កិច្ចការនោះ ។

ខ- ពេលដែលលែងចាំបាច់ធ្វើកិច្ចការនោះបន្តទៀត ។

គ- ពេលដែលលែងអាចបំពេញកិច្ចការនោះបាន ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ២៨ ថ្មី (ករណីដែលទទួលកម្រៃ) នៃច្បាប់នេះ។



Downloaded from http://www.khmerlaws.org

**មាត្រា ៣១ ថ្មី (មាត្រា ២៦ ចាស់).- ប្រភេទនៃសោហ៊ុយ**

អាជ្ញាសាលាត្រូវទទួលការបង់ ឬការសងពីរដ្ឋនូវសោហ៊ុយដែលចាំបាច់ក្នុងការបំពេញកិច្ចការ ។

សោហ៊ុយដែលអាជ្ញាសាលាត្រូវទទួលការបង់ ឬការសងពីរដ្ឋ មានដូចតទៅ ៖

ក- សោហ៊ុយដើម្បីធ្វើការជូនដំណឹង ។

ខ- ប្រាក់ឧបត្ថម្ភ និងសោហ៊ុយធ្វើដំណើររបស់អ្នកសង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ (អ្នកសង្កេតការណ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

គ- ប្រាក់កម្រៃរបស់អ្នកបច្ចេកទេស និងកម្មករ ។

ឃ- សោហ៊ុយសម្រាប់ការដឹកជញ្ជូន ការថែរក្សាគ្រប់គ្រង ការត្រួតពិនិត្យ និងការពារការរក្សាទុក ។

ង- សោហ៊ុយសម្រាប់ការប្រមូលផល ។

ច- សោហ៊ុយសម្រាប់ការទទួលការបញ្ជាក់ពីស្ថាប័នរដ្ឋ ឬអង្គភាពសាធារណៈផ្សេង ទៀត ។

ឆ- សោហ៊ុយសម្រាប់រូបថតដែលថតដើម្បីកំណត់ហេតុស្តីពីស្ថានភាពបច្ចុប្បន្ននៃវត្ថុ ។

ជ- សោហ៊ុយសម្រាប់ការធ្វើលិខិតបញ្ជាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឲ្យលក់)នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឈ- សោហ៊ុយធ្វើដំណើរ និងស្នាក់នៅរបស់អាជ្ញាសាលា ។

ញ- ប្រាក់ឧបត្ថម្ភ សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅ និងកម្រៃរបស់អ្នកវាយតម្លៃ ។

ដ- សោហ៊ុយសម្រាប់ការរាយការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤០០ (ការ ធ្វើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) និងមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឋ- សោហ៊ុយចាំបាច់សម្រាប់ការលក់តាមវិធី ក្រៅពីការលក់ឡាយឡុងដោយដាក់ ស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។

ឌ- សោហ៊ុយក្រៅពីសោហ៊ុយដែលបានកំណត់ពីចំណុច ក ដល់ចំណុច ឋ ខាងលើ នេះ ហើយដែលត្រូវបានកំណត់ដោយច្បាប់ផ្សេង ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣២ ថ្មី (មាត្រា ២៧ ចាស់).- ចំនួនសោហ៊ុយ**

ចំនួនសោហ៊ុយដែលអាជ្ញាសាលាត្រូវទទួលការបង់ ឬសងពីរដ្ឋ មានដូចតទៅ ៖

ក- ចំនួនទឹកប្រាក់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះសោហ៊ុយដែលបានកំណត់នៅក្នុងចំណុច ខ និងពីចំណុច ជ ដល់ចំណុច ឌ កថាខណ្ឌទី ២ នៃមាត្រា មាត្រា ៣១ ថ្មី (ប្រភេទនៃសោហ៊ុយ) ខាងលើនេះ ។



Downloaded from http://www.khmerlaws.org

ខ- ចំនួនទឹកប្រាក់ដែលបានចំណាយចាំបាច់ជាក់ស្តែង ចំពោះសោហ៊ុយដែលបានកំណត់នៅក្នុងចំណុច ក និងពីចំណុច គ ដល់ចំណុច ឆ កថាខណ្ឌទី ២ នៃមាត្រា ៣១ ថ្មី (ប្រភេទនៃសោហ៊ុយ) ខាងលើនេះ ។

**មាត្រា ៣៣ ថ្មី *(មាត្រា ២៨ ចាស់)*.- បុគ្គលដែលមានបន្ទុកត្រូវបង់ថ្លៃកម្រៃ ឬសងសោហ៊ុយ**

បុគ្គលដែលមានបន្ទុកត្រូវបង់កម្រៃដូចមានចែងក្នុងមាត្រា ២៩ ថ្មី (ចំនួនប្រាក់កម្រៃ) និងត្រូវសងសោហ៊ុយដូចមានចែងក្នុងមាត្រា ៣២ ថ្មី (ចំនួនសោហ៊ុយ)គឺ ៖

ក- ចំពោះកិច្ចការដែលអាជ្ញាសាលាចាត់ចែងតាមពាក្យសុំ គឺ អ្នកដាក់ពាក្យសុំអនុវត្ត ។

ខ- ចំពោះកិច្ចការដែលតុលាការបានឱ្យអាជ្ញាសាលាបំពេញដោយផ្ទាល់ គឺ តុលាការ។

ចំពោះករណីដូចមានចែងក្នុងចំណុច ក នៃកថាខណ្ឌទី ១ ខាងលើនេះ កម្រៃ និង សោហ៊ុយត្រូវបង់ទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ ។

**មាត្រា ៣៤ ថ្មី *(មាត្រា ២៩ ចាស់)*.- អាជ្ញាយុកាល**

សិទ្ធិទទួលកម្រៃមួយផ្នែក និងទទួលការសងសោហ៊ុយដែលអាជ្ញាសាលាបានបង់ជំនួសជាមុន នឹងត្រូវរលត់ ដោយអាជ្ញាយុកាល ប្រសិនបើអាជ្ញាសាលាមិនបានអនុវត្តសិទ្ធិនោះក្នុងអំឡុងពេល ៥(ប្រាំ) ឆ្នាំ ។

**មាត្រា ៣៥ ថ្មី *(មាត្រា ៣០ ចាស់)*.- ការបង់ជាមុន**

ចំពោះកិច្ចការដែលអាជ្ញាសាលាត្រូវចាត់ចែង តាមពាក្យសុំ អាជ្ញាសាលានោះអាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ជាមុននូវកម្រៃ និងសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការនោះ តាមចំនួនទឹកប្រាក់ដែលត្រូវបានប៉ាន់ប្រមាណដោយយោងតាមបញ្ញត្តិនៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ឡើយ ចំពោះករណីអ្នកដាក់ពាក្យសុំនោះបានទទួលការ សង្គ្រោះលើបណ្តឹង ។

ការបង់ចំនួនទឹកប្រាក់ប៉ាន់ប្រមាណជាមុនដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាង លើនេះ ត្រូវធ្វើទៅសាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ។

ប្រសិនបើអ្នកដាក់ពាក្យសុំមិនបង់ជាមុននូវចំនួនទឹកប្រាក់ប៉ាន់ប្រមាណដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ខាងលើនេះអាជ្ញាសាលាអាចលើកចោលពាក្យសុំនោះបាន ។

អ្នកដាក់ពាក្យសុំដែលបានបង់ជាមុននូវចំនួនទឹកប្រាក់ប៉ាន់ប្រមាណដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវរួចផុតពីកាតព្វកិច្ចបង់ ឬសងនូវកម្រៃ និងសោហ៊ុយត្រឹមកម្រិតទឹកប្រាក់ដែលខ្លួនបានបង់ពីមុន នោះ ។



Downloaded from http://www.khmerlaws.org

**មាត្រា ៣៦ ថ្មី (មាត្រា ៣១ ចាស់).- ការផ្តល់ជំនួយសង្គ្រោះលើកម្រៃនិងសោហ៊ុយ**

ក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬការអនុវត្តរក្សាការពារដែលអាជ្ញាសាលាជាស្ថាប័នអនុវត្ត ចំពោះបុគ្គលដែលគ្មានលទ្ធភាពទ្រព្យធនក្នុងការបង់ប្រាក់កម្រៃ និងសោហ៊ុយដែលចាំបាច់ដើម្បីចាត់ចែងកិច្ចការរបស់អាជ្ញាសាលា ឬបុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់កម្រៃ និងសោហ៊ុយនេះ សាលាដំបូងដែលអាជ្ញាសាលាបំពេញការងារ អាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់ប្រាក់នេះតាមពាក្យសុំ។ ប៉ុន្តែបញ្ញត្តិនេះ មិនអាចត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែល ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬពាក្យសុំឱ្យអនុវត្តរក្សាការពារ នឹងត្រូវលើកចោលដោយសារពាក្យសុំនេះផ្ទុយនឹងច្បាប់។

ចំពោះហេតុនៃការផ្តល់ជំនួយសង្គ្រោះនេះ ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងដូចដែលមានចែងក្នុង មាត្រា ១៣១ (សេចក្តីបញ្ជាក់ដំបូង) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**មាត្រា ៣៧ ថ្មី (មាត្រា ៣២ ចាស់).- ខ្លឹមសារនៃជំនួយសង្គ្រោះលើកម្រៃនិងសោហ៊ុយ**

ដីកាសម្រេចឱ្យជួយសង្គ្រោះលើកម្រៃនិងសោហ៊ុយ ត្រូវមានអានុភាពទៅតាមការកំណត់ក្នុងដីកាសម្រេចដូចខាងក្រោមនេះ ៖

ក- ការពន្យារពេលបង់ប្រាក់កម្រៃនិងសោហ៊ុយ។

ខ- ការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់កម្រៃ និងសោហ៊ុយ។ ប៉ុន្តែការសម្រេចនេះអាចធ្វើបានចំពោះតែករណីណាដែលតុលាការបានយល់ឃើញថាសមរម្យ ដោយគិតពិចារណាលើលទ្ធភាពទ្រព្យធនរបស់ភាគីជាអាទិ៍ នៅក្រោយពេលដែលការពន្យារពេលនេះ បានរលត់។

ដីកាសម្រេចឱ្យជួយសង្គ្រោះលើកម្រៃនិងសោហ៊ុយនេះ អាចមានអានុភាពទៅលើតែបុគ្គលដែលបានទទួលដីកានោះប៉ុណ្ណោះ។

ក្នុងករណីដែលបុគ្គលដែលបានទទួលដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់ប្រាក់កម្រៃ និងសោហ៊ុយដែលចាំបាច់ដើម្បីចាត់ចែងកិច្ចការរបស់អាជ្ញាសាលាខាងលើ ត្រូវបានរកឃើញថាគ្មានលក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៣៦ ថ្មី (ការផ្តល់ជំនួយសង្គ្រោះលើកម្រៃនិងសោហ៊ុយ) ខាងលើនេះ ឬបុគ្គលនោះបានបាត់បង់លក្ខខណ្ឌទាំងនោះ សាលាដំបូងដែលអាជ្ញាសាលាបំពេញការងារអាចលុបចោលដីកាសម្រេចឱ្យជួយសង្គ្រោះចំពោះការបង់កម្រៃនិងសោហ៊ុយនេះបាន ហើយបង្គាប់ឱ្យបុគ្គលនោះបង់ប្រាក់ដែលតុលាការបាន ពន្យារ ឬអនុគ្រោះមិនឱ្យបង់នៅពេលណាក៏បានតាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹង ផលប្រយោជន៍ ឬដោយឥទ្ធានុសិទ្ធិរបស់ខ្លួនដោយដីកាសម្រេច។

ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា ៣៦ ថ្មី (ការផ្តល់ជំនួយសង្គ្រោះលើកម្រៃ និងសោហ៊ុយ) ខាងលើនេះ និងមាត្រានេះ អាចប្តឹងជំទាស់បាន។



Downloaded from http://www.khmerlaws.org

ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា៣១ (ការផ្ដល់ជំនួយសង្គ្រោះលើកម្រៃ និង សោហ៊ុយ) ខាងលើនេះ និងមាត្រានេះ និងបណ្ដឹងជំទាស់នឹងដីកាសម្រេចនេះ ត្រូវអនុវត្តដោយអនុលោមតាមករណី នៃដីកាសម្រេចនិងបណ្ដឹងជំទាស់ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៣៨ ថ្មី** *(មាត្រា ៣៣ ចាស់)*.- **បញ្ញត្តិពិសេសស្ដីពីបន្ទុករបស់រដ្ឋចំពោះកម្រៃនិងសោហ៊ុយ**

ក្នុងចំណោមកម្រៃនិងសោហ៊ុយចាំបាច់ដើម្បីចាត់ចែងកិច្ចការចំពោះការអនុវត្តដោយបង្ខំ និងការអនុវត្តរក្សាការពារ ដែលអាជ្ញាសាលាត្រូវធ្វើតាមពាក្យសុំរបស់បុគ្គលដែលបានទទួលការសង្គ្រោះលើកម្រៃ និង សោហ៊ុយ ប្រសិនបើមានកម្រៃឬសោហ៊ុយខ្លះដែលរដ្ឋមិនអាចប្រមូលបានពីកូនបំណុលនៃការអនុវត្ត រដ្ឋត្រូវផ្ដល់កម្រៃ ឬសោហ៊ុយនោះ តាមការទាមទាររបស់អាជ្ញាសាលា។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩ ថ្មី** *(មាត្រា ៣៤ ចាស់)*.- **រឿងក្ដីដែលច្បាប់នេះត្រូវអនុវត្ត**

ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្ដីដែលពាក្យសុំត្រូវបានដាក់ទៅអាជ្ញាសាលា ឬតុលាការបង្គាប់ដោយផ្ទាល់ឱ្យអាជ្ញាសាលាចាត់ចែងកិច្ចការ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្តច្បាប់នេះ។ ✓

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះក៏ដោយ ក៏បញ្ញត្តិនៃច្បាប់នេះមិនត្រូវយកមកអនុវត្តចំពោះករណីខាងក្រោម៖

ក- ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុបន្ថែមទៀត នៅទីកន្លែងដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាដែលបានកំណត់នៅក្នុងប្រកាសលេខ ៣០ កយ ប្រក/០៧ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៧ របស់ក្រសួងយុត្តិធម៌ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការ អាជ្ញាសាលា (តទៅហៅថា"មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា") បានរឹបអូស ចលនវត្ថុម្ដងរួចហើយ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៣៨៨ (ការរួមបញ្ចូលរឿងក្ដី) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ខ- ករណីដែលដាក់ពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុដែលមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា បានរឹបអូសជាបណ្ដោះអាសន្ន។ ✓



Downloaded from http://www.khmerlaws.org

**មាត្រា ៤០ ថ្មី ._ កម្មសិក្សា**

អាជ្ញាសាលាកម្មសិក្សាការីជំនាន់ទី ១ ត្រូវបំពេញមុខការរបស់ខ្លួនក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញាអមសាលាដំបូងដែលខ្លួនបំពេញមុខការ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការសាលាដំបូងដែលខ្លួនបំពេញមុខការ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ៤១ ថ្មី** *(មាត្រា ៣៥ ចាស់)*.- **ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាន ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល១ (មួយ)ឆ្នាំ ទើបអនុវត្ត។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ ២០១២ នាសម័យប្រជុំ
រដ្ឋសភាលើកទី នីតិកាលទី ។
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**



Downloaded from http://www.khmerlaws.org